

.9
3
១

895.9323
013932
បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.

# ដែនដី

# សុវណ្ណភូមិ

ប្រលោមលោកផ្សងព្រេងមុនប្រវត្តិសាស្ត្រ

និពន្ធដោយ

នូវ សាវ៉េន

បោះពុម្ពផ្សាយជាថ្មីដោយ

លោក ស្រី ប៊ុនជន

រក្សាសិទ្ធិ

ព.ស ២៥៤៨ គ.ស ២០០៤

# អារម្ភកថា

## ជំរាបសួរមិត្ត !

### មិត្តអ្នកអានជាទីមេត្រី !

ការនិពន្ធរឿងប្រលោមលោកទាក់ទងនឹងប្រវត្តិសាស្ត្រ គឺជាករណីយកិច្ចដ៏ធ្ងន់របស់អ្នកនិពន្ធ ព្រោះត្បិតអ្នកនិពន្ធត្រូវពុះពារប្រកបដោយសេចក្តីព្យាយាមណាស់ ទើបអាចស្រាវជ្រាវប្រមូលយកឯកសារ ដែលជាព្រលឹងដើមនៃប្រវត្តិសាស្ត្រ មកផ្គុំគ្នាតាំងពីផ្នែកតូចៗ អោយកើតជាប្រលោមលោកមួយបាន ។

ជាកុសល ជួនកាលអ្នកនិពន្ធក៏មានភ័ព្វវាសនាអាចខ្វេះកកាយរកឃើញឯកសារប្រវត្តិសាស្ត្រ ដែលជាព្រឹត្តិការណ៍ចាស់កន្លងផុតទៅជាយូរអង្វែងឆ្នាំមកហើយនោះ យកមករៀបរៀងចងក្រងជាខ្សែរឿងមួយ ដែលហាក់ដូចជារស់រានមានរូបសម្ផស្ស និងជីវិតឡើងវិញពិតៗ ។ តែគួរអោយស្តាយកំណត់ហេតុក្នុងរជ្ជកាលខ្លះ ក៏អ្នកនិពន្ធពុំអាចរកឃើញទាល់តែសោះ ។

យ៉ាងណាមិញ ប្រលោមលោកក្រោមចំណងជើងថា ÷ **ដែនដីសុវណ្ណភូមិ** ដែលកំពុងឋិតក្រោមខ្សែចក្ខុនៃមិត្តអ្នកអានក្នុងពេលនេះ គឺជាខ្សែរឿងដែលអ្នកនិពន្ធគ្មានភ័ព្វវាសនា នឹងបានរៀបរៀងទៅតាមគោលសំណៅឯកសារឡើយ ព្រោះថាទីតាំងជាក់លាក់នៃ **ដែនដីសុវណ្ណភូមិ** គេពុំអាចដឹងថានៅត្រង់ណាជាប្រាកដ ។

ក្នុងការស្រាវជ្រាវរកឯកសារ ដែលនិយាយពីប្រវត្តិនៃដែនដីដ៏ធំទូ-លាយនេះ អ្នកនិពន្ធចំណាយពេលយ៉ាងយូរបំផុត តែគ្មានបានទទួលកំណត់អ្វីថែងពីរឿងរ៉ាវនេះ អោយពិស្តារក្រៅពីថែងថា ÷

សុវណ្ណភូមិជាអាណាចក្រមួយ ដែលមានអំណាចគ្រប់គ្រងបរិបូណ៌ពីព្រះមហាវីរក្សត្រដ៏ក្លាហាន ។

រួមសេចក្តីទៅរឿង **ដែនដីសុវណ្ណភូមិ** ពុំអាចសន្មតបានថាជាប្រលោមលោកប្រវត្តិសាស្ត្របានឡើយ គឺជាប្រលោមលោកក្នុងការផ្សងព្រេងមួយបែបដែលដំណើរទូទៅ កើតឡើងពីមនោគតិដ៏សុទ្ធសាធរបស់អ្នកនិពន្ធ ។

លើសពីនេះទៅទៀត អ្នកនិពន្ធមានមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅចង់ផ្ចិតយកការផ្សាយព្រះពុទ្ធសាសនា កាលពីជំនាន់នោះអោយចូលទៅក្នុងសាច់រឿងនេះ ដើម្បីបញ្ជាំងអោយឃើញថា តើព្រះពុទ្ធសាសនាជាសាសនាប្រកបដោយការប្រៀនប្រដៅយ៉ាងត្រឹមត្រូវ មានទស្សនៈយ៉ាងទូលំទូលាយនិងទាក់ទងនៅក្នុងវិទ្យាសាស្ត្របច្ចុប្បន្នយ៉ាងណាខ្លះ ? សូមមិត្តអ្នកអានមេត្តាផ្ចាត់ទំព័រសៀវភៅប្រលោមលោកនេះ អានដោយរីករាយដូចតទៅ ÷

សូមអរគុណ

**នូវ សាផែង**

# ១

# ក្រោមម្លប់ផ្លូក

កាលពីសម័យមុនប្រវត្តិសាស្ត្រសកលលោក ដែនដីនៃនគរសុវណ្ណភូមិ ក្នុងរជ្ជកាលព្រះបាទសុយិន្ទ្រាវ័ន្ន បានលាតសន្ធឹងតេជានុភាពយ៉ាងសម្បើម អស្ចារ្យ ។ គឺជាមហានគរមួយដែលគ្មានប្រទេសណាហ៊ានប្រកាសសង្គ្រាមជាមួយឡើយ ។

ប្រទេសទាំងឡាយ ដែលឋិតនៅជិតខាងនៃនគរសុវណ្ណភូមិនេះ ដូចជាប្រទេសជ្វា, ប្រទេសចម្ប៉ា, ប្រទេសមន និងប្រទេសចិន រាជត្រីស្តជាដើម ដែលជាអតីតបច្ចាមិត្ត ធ្លាប់ធ្វើសឹកសង្គ្រាមនឹងគ្នា ក្នុងរាជក្សត្រមុនៗ ស្លាប់អស់ពលសកលយោធារាប់ម៉ឺននាក់ ក៏បានចាប់ដៃចងមិត្តជាមួយសុវណ្ណភូមិយ៉ាងជិតស្និទ្ធ ។

ពេលវេលាធ្វើដំណើរទៅមុខជាលំដាប់ ដោយទាញកង់ប្រវត្តិសាស្ត្រអោយវិលទៅជាមួយផង ។ អនិច្ចា ! លុះព្រះបាទសុរិយិន្ទ្រាវ័ន្នសោយទីវង្គតទៅដោយព្រះរោគជរាពាធ សភាពអនុត្តានៃតេជានុភាព ដែលជាមហាកំពែងរបស់សុវណ្ណភូមិ ក៏បាក់បែកធ្លុះធ្លាយប្រែពណ៌សម្បុរ ស្ទើរពុំអាចស្មានយល់ ។

ភ្លើងកលិយុគ បណ្តាលមកពីសង្គ្រាមក្នុងស្រុក បានឆាបឆេះសន្ធោសន្ធៅ ដុតរោលជីវិតជាតិអោយក្តៅផ្សា ធ្លាក់ដល់ក្តីមហន្តរាយឥតបរិយាយបាន

ព្រះបាទសាយណ្ណាវ័ន្ទ ព្រះរាជបុត្រព្រះបាទសុឃិន្ទ្រាវ័ន្ទ. បានត្រូវនាម៉ឺនសព្វមុខមន្ត្រី យាងព្រះអង្គអោយឡើងគ្រងរាជ្យសម្បត្តិ តពីព្រះបិតាព្រះអង្គ ។

ព្រះរាជាអង្គនេះទ្រង់នឹកតូចព្រះទ័យយ៉ាងខ្លាំង ចំពោះបឋមរជ្ជកាលរបស់ព្រះអង្គ ដែលពោរពេញដោយការកាប់សម្លាប់អ្នកស្រុក បណ្តាលអោយបាក់បែកសាមគ្គីរវាងគ្នានិងគ្នា ។

ដោយខ្សែព្រះហិតព្រះអង្គជាក្សត្រសឹក ប្រកបដោយជោគជ័យ ព្រះអង្គពុំអាចគង់ស្ងៀមនៅលើបល្ល័ង្គរាជ ទុកអោយសត្រូវកាប់សម្លាប់ប្រជារាស្ត្រព្រះអង្គ តាមអំពើចិត្តបានឡើយ ។

ថ្ងៃនេះ នៅពេលព្រះអាទិត្យរះពេញពន្លឺក្រហមច្រាល ក្រោមបទចម្រៀងជូនពរស្វាគមន៍យ៉ាងខ្សៀវខ្សានៃហ្វូងសត្វបក្សាបក្សី ព្រះអង្គទ្រង់គង់លើព្រះទីនាំងអស្សេតរ នាំវរហ៍ពលសកលយោធា ·បំពេញព្រះរាជបេសកកម្មបោសសំអាតពួកបះបោរនៅតាមឆ្នេរសមុទ្រខាងជើង ជាទីដែលពពួកប្រព្រឹត្តអំពើចោរកម្ម ប្លន់ កាប់សម្លាប់អ្នកស្រុកយ៉ាងសាហាវយង់ឃ្នង ។

ក្បួនទ័ពបោះជំហ៊ានទៅមុខ សន្សឹម១ នៅតាមផ្លូវ ព្រះរាជាទ្រង់ប្រទះតែសំណល់បទឧក្រិដ្ឋ ដែលពួកបះបោរសាងអោយប្រជារាស្ត្រ ។

មើលចុះ ! ផ្ទះសម្បែងបែកបាក់ខ្ទេចខ្ទី មានភ្លើងឆេះរោលរាល ជូនកាលឃើញទាំងសាកសពហើមប៉ោង ស្អុយរលួយគួរអោយសង្វេគផង ។

មកដល់លើផ្នូរខ្សាច់ ទិដ្ឋភាពថ្មីដែលជាគ្រឿងលួងលោមអារម្មណ៍

ពួនបើកវាំងននឡើងយ៉ាងសង្ហា ។

ក្រោមផ្ទៃមេឃពណ៌ខៀវបំព្រង ដ៏ដេរដាសទៅដោយផ្កាំងអម្ពរ ព្រះពាយបក់បោកមករូ ! រូ ធ្វើអោយដើមត្រែង និងដើមស្រល់ ទោរទន់កាយបញ្ចេញក្បាច់នាដកម្មមួយបែបយ៉ាងទន់ភ្លន់ ។ ទឹករលកក្នុងមហាសាគរ រត់រមេញប្រដេញគ្នាពីចម្ងាយ មកបោកកាយ ននាលលេងប្របឆ្នេរខ្សាច់យ៉ាងក្សេមក្សាន្តសប្បាយ ។

តែផ្ទុយទៅវិញ សភាពទាំងនេះពុំបានទាក់ទាញទឹកព្រះទ័យព្រះមហាក្សត្រអោយបានធូរស្បើយ ពីព្រះរាជកង្វល់ក្នុងកិច្ចការផែនដីដែលប្រកបដោយគ្រោះថ្នាក់ឡើយ ។ ព្រះអង្គទ្រង់មានព្រះភ័ក្ត្រស្ងប់ ដោយព្រះវិញ្ញាណចាក់ស្រេះទៅលើសេចក្តីវេទនារបស់ប្រជានុរាស្ត្រដែលត្រូវរាជសត្រូវក្បត់ជាតិរាត-ត្បាតជិះជាន់កាប់សម្លាប់រាល់ថ្ងៃ ។

ក្សិណនោះ ទ្រង់ឆ្មៀងព្រះភ័ក្ត្រទតទៅកណ្តាលមហាកោះ ទ្រង់បានយល់រុក្ខជាតិមួយដើមធំ មានមែកបែកត្រសុំត្រសាយសាខា ប្រកបដោយម្លប់យ៉ាងត្រជាក់ ក៏ទ្រង់ត្រាស់សួរទៅឧកញ៉ាហោរាធិបតីឥសូរភទ្រ ដែលជិះសេះអមព្រះទីនាំងអស្សតរព្រះអង្គថា ÷

- លោកតា តើមានស្គាល់ដើមឈើដ៏ធំនោះទេ ?

លោកតាហោរាធិបតីឥសូរភទ្រ លើកករប្រណម្យចំពោះព្រះភូមិន្ទ្រដ៏ជាកំពូលភព ទើបក្រាបទូលព្រះអង្គថា ÷

- សូមទ្រង់ព្រះមេត្តាប្រោស ព្រឹក្សាដ៏ធំនេះឈ្មោះថាដើមធ្លក ដែល



កាលព្រះសម្មាសម្ពុទ្ធទ្រង់គង់ព្រះជន្មនៅឡើយ ព្រះអង្គបានយាងមកប្រោសសត្វនៅទីនេះម្តង ឃើញសត្វត្រកួតមួយនៅក្រោមដើមធ្លកនេះ ព្រះអង្គទ្រង់បានព្រះព្យាករណ៍ថា កោះនេះនឹងក្លាយទៅជាមហានគរមួយឈ្មោះគោកធ្លក ។ តែលុះក្រោយពីព្រះសម្មាសម្ពុទ្ធទ្រង់យាងចូលនិព្វាន ទៅបានជាងសាមសិបឆ្នាំ មានព្រះមហាក្សត្រមួយអង្គទ្រង់ព្រះនាមព្រះបាទសហមណីរាជ[១] ទ្រង់សោយរាជនៅហង្សាវត្តីបុរី[២] ។ លុះដល់ទ្រង់សោយទីវង្គតទៅបានបីឆ្នាំ ទ្រង់កើតជា

---

(១) ប្រវត្តិព្រះគោព្រះកែវ ស្រាវជ្រាវដោយ អៀ- ធួលុច ។

(១) ទីក្រុងនៅប្រទេសភូមា សម័យបុរាណ ។

សត្វគោបាមួយមកនាំព្រះអនុជអោយស្គាល់ទីជ័យភូមិ ដែលអាចសាងជានគរស្ដេចចក្របាន ។

គោបាននោះបានធ្វើដំណើរមកដល់កោះមួយ ដែលមានដើមធ្លកដុះ ក៏កាយរូងដេកក្រោមដើមធ្លកនោះ អស់វេលា ៧ យប់ ៧ ថ្ងៃ ទើបក្រោកឡើងឈរបែរមុខទៅគ្រប់ទិសទាំង ៨ រួចទើបបន្តដំណើរតទៅទៀត ។

ព្រះអនុជឃើញដូច្នោះ ក៏ទាយទុកថា អំណើះតទៅនឹងកើតជានគរមួយមានកិត្តិសព្ទរុងរឿង ។

ក្រោយមក គោបាក៏ត្រឡប់ទៅកាន់ក្រុងបាឬាវត្តិវិញ ស្រាប់តែត្រូវស្រុតនៅពាក់កណ្ដាលផ្លូវស្លាប់បាត់បង់ជីវិតទៅ ។ គ្រានោះ ព្រះអនុជទ្រង់ឮសូរតូរ្យតន្ត្រីគឹកកងរំពងឮដ៏កាស គួរអោយរំភើបអស្ចារ្យ ។ ព្រះអង្គក៏ទ្រង់ត្រាស់ទៅរាជបរិពារ ដែលហែហមព្រះអង្គថា នេះពិតជាព្រះជេដ្ឋាយើង ស្ដេចយាងមកបង្ហាញទីជ័យភូមិអោយយើងដឹង ហើយព្រះអង្គស្ដេចទៅកើតជាទេវបុត្រឯឋានតុសិតពិតប្រាកដ ។

ព្រះបាទសាយណ្ហាវ័ន្ទទ្រង់ប្លែកក្នុងព្រះរាជហឫទ័យ ចំពោះសេចក្ដីក្រាបទូល របស់ឧកញ៉ាហោរាធិបតីឥស្សូរភទ្រណាស់ ព្រះអង្គទ្រង់ព្រះតម្រិះថាព្រឹក្សានេះមានមូលប់ត្រឈឹងត្រឈៃសមគួរដល់ការគង់ប្រថាប់ ព្រះអង្គក៏ទ្រង់នាំរេហ៍ពលទៅសំចតនៅទីនោះ ដោយទ្រង់ត្រាស់បញ្ជាទៅលោកឧកញ៉ាពិជ័យរថនា ដែលជាសេនាធិបតីកាន់កាប់ខាងកិច្ចការសំណង់ និងការរចនាទាំងពួងថា ៖

- លោកពិជ័យរចនា ! ដល់ត្រឡប់ទៅដល់វាំងវិញ ចូរលោករៀបចំសាងរូបសំណាកគោបាមួយយ៉ាងធំ, ពីមាស ដើម្បីទុកជាសក្ខីភាព នៃអនុស្សាវរីយ៍ចំពោះគោ បានដែលបានមកដល់កោះយើងនេះ ! ........

- ព្រះករុណាថ្លៃវិសេស ! ទូលព្រះបង្គំសូមទទួលតាមព្រះរាជឱង្ការដិកល់លើត្បូងក្រាបទូល !

ខ្យល់ជំនោរបក់មករំភើយៗ ព្រះបាទសាយណ្ហាវ័ន្តគង់លើកម្រាលកម្ទីក្រោមដើមធ្លក ចំណែកពលសេនាទាំងអស់ឆ្លៀតក្នុងឱកាសនេះ នាំគ្នាដឹកសេះយកទៅលាងទឹក ខ្លះទៀតដឹកវាយកទៅអោយស៊ីស្មៅ ។

ថ្លែងពីប្រជាពលរដ្ឋដែលស្ថិតនៅកោះគោកធ្លក កាលបើដឹងថាព្រះប្រិយមហាក្សត្រទ្រង់យាងមកគង់សំចតក្រោមដើមធ្លក ក៏នាំគ្នាពពាក់ពពូនចូលមកក្រាបបង្គំគាល់ព្រះអង្គ ដោយសំដែងស្វាមីភក្តិចំពោះព្រះនរបតី និងទូលព្រះអង្គពីការឈ្លានពានរបស់ពួកបះបោរ ដែលវានាំគ្នាមកប្លន់, កាប់សម្លាប់អ្នកស្រុក ព្រមទាំងដុតបំផ្លាញលំនៅខ្លួនផង ។

ព្រះរាជាមានសេចក្តីខ្លោចផ្សា ចំពោះសេចក្តីទុក្ខរបស់កូនចៅព្រះអង្គជាភិយ្យោភាព ។ ទឹកព្រះភ័ក្ត្រក៏ប្រែក្លាយទៅជាក្រហមទុំ ដោយព្រះពិរោធន៍ក្នុងព្រះហឫទ័យជាអតិបរមា ។

លុះអ្នកស្រុកទាំងនោះត្រឡប់ទៅកាន់ភូមិស្ថានវិញ ព្រះអង្គទ្រង់ត្រាស់ទៅកាន់លោកមេទ័ពតេជោក្លាហាន, លោកវិសេសសេនា, លោកក្រឡាសូ, លោកតាហោរាធិបតី និងលោកពិជ័យរចនា ពីព្រះរាជកង្វល់របស់ព្រះអង្គ

ក្នុងការបង្ក្រាបពួកបះបោរនេះ ។

- តាមពតិមានដែលខ្ញុំបានទទួលថា ពួកក្បត់ជាតិដែលដឹកនាំការបះបោរនេះ មានរាមរាជ្យជាមេ ....... អស់លោក ! ខ្ញុំមានការឈឺចាប់ណាស់ចំពោះរាមរាជ្យ និងបរិវារវាដែលបានបះបោរ វាយបំបែកកម្លាំងសាមគ្គីជាតិឱ្យវិចិរិលវិលទៅជួបសេចក្ដីវិនាស យើងកាលនៅរាជវាំងបានដឹងថាវាមករាត-ត្បាតអ្នកស្រុកកោះគោកធ្លកនេះយ៉ាងខ្លាំង យើងក៏លើកទ័ពមករកជួបមុខវាស្រាប់តែពួកវាគេចទៅណាបាត់អស់ ! ខ្ញុំឆ្ងល់ណាស់ ហេតុដូចម្ដេចបានជាពួកវាដឹងការសម្ងាត់របស់យើង ! ចំពោះរឿងនេះ តើអស់លោកយល់ឃើញដូចម្ដេច ?

ខណៈនេះ តេជោក្លាហានដែលជាមេបញ្ជាការសឹក ក៏បញ្ចេញមតិឡើង ទូលព្រះករុណាជាអម្ចាស់ ។

- ក្រាបទូល ! តាមការដកទ័ពរបស់ពួកបះបោរនេះ តាមទូលបង្គំយល់ គឺជាកលល្បិចរបស់សត្រូវដែលវាចង់វាយគ្នាលបវាយស្ទាក់យើង នៅកន្លែងណាមួយក៏មិនដឹង ហើយម្យ៉ាងទៀត ការដែលវាគេចទៅនេះ បើវាពុំបានចេញមុខមកប្រយុទ្ធនឹងយើងទេ នោះក៏ពុំមានន័យថាវាខ្លាចយើងដែរ ព្រោះបើវាខ្លាចច្បាស់ជាពុំហ៊ានធ្វើការបះបោរឡើយ តែទូលព្រះបង្គំយល់បានទៀតថាវាពិតជាចង់ទុកការរាតត្បាតនេះ អោយមានវេរវេលាយូរអង្វែងតទៅទៀតដើម្បីឱ្យរដ្ឋធ្លាក់ក្នុងរណ្ដៅហាយនភាព ដែលជាការងាយដល់វានឹងស្រវាចាប់ផែនការធំៗដែលវាបានគ្រោងទុកជាស្រេច តាមគោលគំនិតអាថិកំបាំងរបស់វា

- មែន ! លោកតេជោក្លាហាន (ព្រះភូមិន្ទ្រទ្រង់ត្រាស់តបដោយ

សោមនស្ស) ខ្ញុំក៏គិតដូចលោកដែរ ! ចុះអស់លោកឯទៀតៗ យល់ឃើញដូចម្តេចដែរ ? លោកវិសេសសេនា មានប្រសាសន៍ទៅមើល៍ !

- ក្រាបទូល ! ព្រះករុណាថ្លៃវិសេស ! ទូលព្រះបង្គំយល់ស្របតាមយោបល់លោកតេជោក្លាហានទាំងស្រុង តែចំពោះការដែលពួកបះបោរ ចេះតែដឹងជាមុននូវគំរោងការណ៍បោសសំអាតរបស់លួងធូលីព្រះបាទ ទូលបង្គំសង្ស័យថាច្បាស់ជាមានមនុស្សក្បត់ដែលជានុកក្នុងរបស់វា បានបន្លំបង្កប់ខ្លួនក្នុងអង្គ-ការរដ្ឋ លបលួចយកការណ៍សម្ងាត់នេះទៅអោយពួកនោះក្រាបទូល ! បើវាពុំដឹងដើងការណ៍របស់លួងធូលីព្រះបាទទេ ទូលព្រះបង្គំជឿថាព្រះអង្គគង់តែនឹងបានជួបប្រយុទ្ធនឹងពួកវា អោយឃើញសខ្មៅជាមិនខាន ហើយការបោសសំអាតនឹងប្រព្រឹត្តទៅប្រកបដោយជោគជ័យជាប្រាកដ !

- ល្អណាស់លោកវិសេសសេនា លោកមានប្រសាសន៍ត្រឹមត្រូវណាស់ ចុះលោកក្រឡាសួចង់មានប្រសាសន៍ដូចម្តេចដែរ ក៏ដូចជាអន្ទះអន្ទែងម្ល៉េះ ? លោកយល់ឃើញយ៉ាងណាមានប្រសាសន៍មក !

- ក្រាបទូលព្រះករុណាថ្លៃវិសេស តាមទូលព្រះបង្គំយល់ថា ខ្ញុំរាជការទាំងអស់គ្នា គ្មានបានផ្សំគំនិតក្បត់ជាមួយរាមរាជ្យទេ សូមទ្រង់ជ្រាប ! ..... ពិតជាមានទឹកចិត្តស្វាមីភក្តិចំពោះព្រះអង្គគ្រប់គ្នា ..........

- ហ៊ាៗ ! ហ៊ា ! (ព្រះចមពលទ្រង់ព្រះសម្រួល) ម្តេចក៏លោកដឹងជម្រៅចិត្តគេទាំងអស់គ្នាម្ល៉េះ ! ចំពោះខ្ញុំៗ ពិតជាឥតសង្ស័យជានរណាក្បត់ខ្ញុំដែរ តែខ្ញុំក៏មិនទុកចិត្តនរណាក្រៅពីខ្ញុំឡើយ ! ...... តាមពិតច្បាស់ជាមានមនុស្សខ្លះក្បត់

នឹងរាជបល្លង្កទៅទាក់ទងនឹងពួកក្បត់ជាតិ ទើបបានជាផែនការណ៍បោសសំអាតរបស់ខ្ញុំធ្វើឡើងម្តងណាម ក៏ពុំដែលបានសម្រេចសោះ ! ........

ក្រឡាស្ងូ នឹកអៀនខ្មាសយ៉ាងខ្លាំងក្នុងសំដីឥតខ្លឹមសាររបស់គេ ។

ព្រះទសពល ក្រោយដែលទ្រង់ព្រះតម្រិះអស់មួយរយៈ ព្រះអង្គត្រាស់បន្តទៅទៀតថា ÷

- កោះគោកធ្លកយើងនេះ មានប្រជាជនច្រើនកកកុញណាស់ ខ្ញុំគិតថាត្រូវតែយើងរៀបចំ ពង្រីកបន្ទាយចាស់របស់យើងដែលសព្វថ្ងៃបានទ្រុឌទ្រោមបន្តិចទៅហើយ អោយបានធំមាំមួនឡើងវិញ ព្រោះកាលក្នុងរាជ្យព្រះបិតាខ្ញុំនៅពេលច្បាំងនឹងចម្ប៉ា បន្ទាយនេះបានផ្តល់ជោគជ័យយ៉ាងច្រើនលើសលប់ពីលើខ្មាំង ! ដូច្នេះសូមលោកតេជោក្លាហានធ្វើសារមួយទៅប្រាប់លោក ឧកញ៉ាជំនិតភក្តីជាចៅហ្វាយខេត្តកោះគោកធ្លកនេះ អោយរៀបចំជួលជុលបន្ទាយសាជាថ្មីឡើង ចាំយើងបញ្ជូនកងទ័ពទៅជាខាងក្រោយ ។

- សូមទទួលតាមព្រះរាជបញ្ជា !

លោកមេទ័ពតេជោក្លាហាន ក៏ចាប់សរសេរសារលិខិតតាមព្រះរាជឥម្រាស់ ហើយអោយទាហានប្រាំនាក់ នាំយកទៅជូនលោកជំនិតភក្តី ចៅហ្វាយខេត្តគោកធ្លក ។

ក្រោយពីទាហាន ៥នាក់ ចេញទៅបំពេញបេសកកម្មរបស់ខ្លួនផុតទៅបានមួយសន្ទុះ ព្រះករុណាជាអម្ចាស់ជីវិតក៏ទ្រង់នាំរេហ៍ពលសកលយោធា ចាកចេញពីកោះគោកធ្លកមកកាន់ព្រះបរមរាជវាំងវិញ ។

# ២

# ក្លូនក្រញាំពួកអាស្រ

ឧកញ៉ាក្រឡាសួ កាលដង្ហែព្រះករុណាជាអម្ចាស់ជីវិតលើត្បូង មកដល់ខ្លោងទ្វារព្រះបរមរាជវាំងហើយ ក៏លបគេចខ្លួនលួចជិះសេះយ៉ាងរូតរះមកកាន់គេហស្ថាន ។

គ្រាន់តែមកដល់ភ្លាម មន្ត្រីរូបនេះចុះពីលើខ្នងសេះយ៉ាងរហ័សរហួនដោយមិនរវល់នឹងទទួលគោរពអភិវន្ទនាការពីអ្នកយាមទ្វារឡើយ ។ គាត់រត់ត្របោតត្របាបចូលក្នុងបន្ទប់សម្ងាត់ទើបប្រាប់អ្នកយាមម្នាក់ ដែលនៅយាមប្រចាំការក្នុងបន្ទប់នេះថា ÷

- អាស្មោញ ! ឯងទៅប្រាប់អាឆើតអោយនាំគ្នា ១០ នាក់ មកជួបអញជាប្រញាប់ ! ....... អញមានការ ! ........

- ប្របាទ !

អ្នកយាមឆ្លើយយ៉ាងគោរព ទើបបោះជំហានចេញទៅក្រៅយ៉ាងប្រញាប់ ។

នាយឆើតជាយុវជនមួយរូប មានរូបរាងអាក្រក់ មើលមិនយល់ ។ រាងកាយវាខ្មៅគម្រាំង មាឌធំដំបង, ភ្នែកលៀន សក់រួញក្រញាញ់ បះឡើងកន្ទ្រើង ។

នាយឆើត និងសហការីរបស់គេ ១០ នាក់កំពុងឋិតនៅចំពោះមុខលោកក្រឡាសូ ។

កាលបើឃើញនាយមាណពនេះមកដល់, ដោយនាំទាំងគូកនដៃឯកមកជាមួយដូចបំណង, លោកក្រឡាសូ ក៏ញញឹមព្រាយដោយអាការៈត្រេកអរ

- ឆើត ! អាវិសេសសេនា ដឹងការសម្ងាត់យើងហើយ ពេលនេះបើយើងមិនកំចាត់រូបវាទេ ផែនការរបស់យើងនឹងត្រូវបែកក្លាយរលាយជាមិនខាន ដូច្នេះឆើតត្រូវនាំគ្នាទៅចាត់ការស្កាត់ចាប់យកវាអោយបាន នៅពេលដែលវាចេញពីវាំងមកផ្ទះវិញ ។

នាយឆើតឮនាយចៅហ្វាយនិយាយថា វិសេសសេនា ដឹងការសម្ងាត់របស់ពួកគេៗ ក្តៅក្រហាយណាស់ ។ នរៈសង្ឃៀតធ្មេញក្រឹតៗ បញ្ចេញគ្រាប់ភ្នែកល្មៀនថ្លៃ ទើបរំពងសំលេងដូចផ្គរលាន់ថា ÷

- ហ៊ឹះ ! វិសេសសេនាដឹងការសម្ងាត់របស់យើង ! ...... ដាច់ខាត វានឹងត្រូវស្លាប់ក្នុងយប់នេះហើយទានប្រោស ! សូមព្រះតេជគុណ ទុកចិត្តលើរូបខ្ញុំ និងពួកនេះចុះ !

- ខ្ញុំទុកចិត្ត លើឆើតឯងទាំងស្រុង ហើយចូរចាត់ការនេះអោយបានសំរេច ដោយកុំអោយបែកការអោយសោះ ។

- បាទកុំព្រួយព្រះតេជគុណ ! .......

នាយឆើត ! កំពូលអ្នកលេង, បន្ទន់កាយគោរពក្រឡាសូបន្តិច ទើប

នាំសហការីរបស់គេចេញទៅប្រតិបត្តិការណ៍តាមសំណៅ នៃគម្រោងការណ៍របស់គេយ៉ាងស្ងប់ស្ងៀម ។

ពួកនេះបានប្រាកដខ្លួន មកដល់ក្បែរកំពែងព្រះបរមរាជវាំង ហើយវាបានបញ្ចេញអាកប្បកិរិយាដូចជាពួករាត្រីចរ តែកែវភ្នែករបស់ពួកវាគ្រប់ៗ រូបកំពុងធ្វើការរាវរក លោកវិសេសសេនាក្នុងចំណោមនាម៉ឺនទាំងអស់ ដែលកំពុងធ្វើដំណើរចេញពីខ្លោងទ្វារព្រះបរមរាជវាំង មកកាន់គេហស្ថាន. យ៉ាងប៉ិនប្រសប់ ។

នាយឆើតបណ្ដាក់គ្នាតាមដងផ្លូវ ដែលវាសន្មត់ថាជាផ្លូវរបស់លោកវិសេសសេនាធ្លាប់ចេញចូល ។

ថៃដន្យអ្វី ! ជួនជាខណៈនោះ វាចោលភ្នែកមួយខ្វាប់ទៅទិសខាងត្បូង ក៏ប្រទះរូបលោកវិសេសសេនា កំពុងជិះសេះយឺតៗ តាមដងវុក្ខវិថី ។

ត្រេកអរណាស់ នាយនេះហួចមួយឆ្វេកបន្លឺសញ្ញាទៅដល់គូកនរបស់វា អោយចាប់ប្រព្រឹត្តគ្រោងការណ៍ក្បត់មួយរំពេច ។

អាយ៉ង ១០ នាក់ ក៏នាំគ្នាបត់ក្បាលសេះមករកនាយឆើតដែលកំពុងតាមល្បឿនសេះ លោកវិសេសសេនាយ៉ាងស្អិត ។ ចំណែកលោកវិសេសសេនាវិញ ក៏ឃើញពួកនេះជិះសេះពីក្រោយលោកដែរ តែលោកមិនចាប់ភ្ញឹកពីឧបទ្ទវហេតុអ្វីឡើយ ព្រោះតាមធម្មតា នៅកណ្ដាលរាជធានីនេះ ពុំដែលមានចោរប្លន់ឬការលបលួចចាក់ដល់ម្ដងណាសោះ ។ ម្ល៉ោះហើយក៏ពុំអាចសន្មតបានថា ពួក

នេះជាសត្រូវ ដែលកំពុងប៉ុនប៉ងយាយីចាប់រូបលោកឡើយ ។

នៅក្នុងអន្លង់អន្ធការ ប្រាសចាកពន្លឺដួងច័ន្ទ លោកជិះសេះដោយគ្មានទីកព្រីវអែង អំពីគ្រោះថ្នាក់សោះទេ តែលុះមកដល់កន្លែងស្ងាត់មួយស្រាប់តែលោកភ្ញាក់ស្មារតីយ៉ាងខ្លាំង ដោយមានអ្នកជិះសេះមួយរូប ហក់មកអោបរាងកាយលោកពីក្រោយជាប់ ។

ភ័យណាស់ លោកខំរើបំរះពេញទំហឹង ពីកណ្ដាប់ដៃជនចម្លែកនេះ បណ្ដាលអោយខ្លួនលោក និងភេរវជនរបូតពីខ្នងសេះធ្លាក់មកដីទាំងពីរនាក់ ។

នាយឆើត សង្កត់លោកវិសេសសេនាយ៉ាងខ្លាំង តែក្នុងឱកាសនេះលោកបានប្រើល្បិចបម្រះចេញរួចពីរង្វង់ដៃជននេះទាល់តែបាន ។ គាត់អោយរង្វាន់នាយឆើតមួយដៃយ៉ាងដំណំ ទើបស្ទុះក្រោកឡើងស្រវាចាប់ដងដាវនៅចង្កេះ ប្រុងនឹងហូតឡើងប្រល័យជីវិតវា តែឥតប្រយោជន៍សោះ ពេលនេះផ្លែដាវយ៉ាងច្រើនប្រឈមពីគ្រប់ទិស ឃុំខ្លួនលោកជាប់ដោយបញ្ជាជាដាច់ខាតថា ÷

- នៅអោយស្ងៀម ! បើចង់រស់តទៅថ្ងៃស្អែកទៀត ចូរប្រគល់ខ្លួនឱ្យយើងទៅទើបប្រសើរ ! ........

ឧកញ៉ាវិសេសសេនា ធ្លាក់ថ្លើមក្ដុក លោកខាំធ្មេញក្រឹត ។ បើកភ្នែកសម្លឹង មើលមុខបរបក្សយ៉ាងឃ្នាន់ខ្នាញ់ ទើបលួចឆ្លៀតយកឱកាសដ៏តូចនេះដកដាវឡើងតទល់នឹងពួកវា តែពុទ្ធោអើយ ! .....

- ប៉ាំង ! ប្រូស !

- អូយ !

នាយឆើតក្រឡេកទាន់ ក៏លើកដាវទាំងស្រោមសំពងលោកចំលលាដ៏ក្បាលពីក្រោយ បណ្តាលអោយរាងកាយមន្ត្រីស្នេហាជាតិរូបនេះ ទន់ស្រុត ដួលដេកមកលើព្រះធរណីដល់ក្តីវិសញ្ញាណនៅនាទីនោះទៅ ។

- ហាំ ! ហាំ ! នៅឯណាមិនដឹងដៃអាឆើត ! កនយើងវាសន្លប់ហើយ លើកវាដាក់លើខ្នងសេះ នាំវាយកទៅកន្លែងយើងភ្លាម !

រលកសម្លេងរបស់នាយឆើត រលត់ផុតទៅក្នុងអន្លង់តុណ្ហីភាពនៃរាត្រីកាល គេក៏នាំគ្នាចាប់លើកអ្នករងគ្រោះយើងដាក់លើខ្នងសេះ នាំយកមកលំនៅក្រឡាសូយ៉ាងរួសរាន់ ។

ចង្កៀងខ្លាញ់ឆេះបញ្ចេញពន្លឺព្រឹម ៗ បំភ្លឺបន្ទប់មួយក្នុងបណ្តាបន្ទប់ពិសេស១ ជាច្រើននៃលំនៅរបស់ក្រឡាសូ អោយឃើញបុរសម្នាក់ដេកស្តូកស្តឹងនៅលើគ្រែរនាបមួយគ្រឿង ។

នៅក្បែរនោះ ក្រឡាសូរឈរក្រពាត់ដៃ ដោយទឹកមុខញញឹមទៅកាន់សហការីរបស់គាត់ មាននាយឆើតជាមេដែលបានចេញទៅបំពេញបេសកកម្មនេះសម្រេចដូចគោលបំណង ។

- យើងចាប់បានវិសេសសេនាក្នុងពេលនេះ គឺហាក់ដូចជាបានខ្ទាស់ទ្វារផែនការសម្ងាត់យើង អោយបិតក្នុងជម្រៅអាថិកំបាំងដូចធម្មតា ! ..... តែទោះ

បីយ៉ាងនេះ ផែនការយើងនៅមានច្រើនជាន់ថ្នាក់ទៀតណាស់ ដែលសុទ្ធសឹងជាការពិបាក ! ........

ស្អែកនេះ ........ អា ! ........ ក្រឡាសូនិយាយបានតែត្រឹមនេះ ក៏នឹកឃើញរឿងអ្វីម្យ៉ាងដែលគាត់ត្រូវរឹងមាត់ទៅវិញ ។ គាត់ងាកមុខឈរសម្លក់លោកវិសេសសេនាអស់មួយរយៈ ទើបនិយាយទៅកាន់សហការីរបស់គាត់ទាំងអស់ថា ÷

- អ្នករាល់គ្នា ទៅសំរាកកម្លាំងចុះ ! នៅតែឆើតបានហើយ ! .....

ទាហានដែលជាដៃជើងរួមការក្បត់របស់ក្រឡាសូទាំង ១០ នាក់ ក៏នាំគ្នាចេញពីបន្ទប់នេះអស់ទៅ ។ ក្រឡាសូទះស្មាឆើតតិច១ ទើបនិយាយឡើង ÷

- ឆើត ! ចំពោះវិសេសសេនាយើងត្រូវតែឃុំឃាំងវាទុកកន្លែងនេះហើយ ដោយកុំអោយវាឃើញមុខយើងអោយសោះ ! ឥឡូវយើងទៅជំនុំគ្នានៅបន្ទប់ឯណោះវិញ ។

អ្នកទាំងពីរ នាំគ្នាចេញដោយទាញទ្វារបិទយ៉ាងជិត ទើបដើរមកកាន់បន្ទប់មួយទៀត ។

នាយឆើតឃើញចៅហ្វាយនាយរបស់ខ្លួន បញ្ចេញសេចក្ដីរាក់ទាក់ស្និទ្ធស្នាលចំពោះគេខុសពីប្រក្រតី គេតែងនឹកសប្បាយរីករាយក្នុងចិត្តឥតបីបរិយាយព្រោះតាំងពីដើមមក គឺចាប់តាំងពីចូលមកធ្វើការបំរើលោកក្រឡាសូ១ ពុំដែលបញ្ចេញទឹកមុខស្រស់ញញឹមរកគេដល់ម្ដងណាឡើយ ។

ខណៈនេះ, នៅលើកៅអី, ក្រឡាស្វ និងនាយឆើតអង្គុយសន្ទនាគ្នាយ៉ាងស្និទ្ធបំផុត ។ ជាបឋមយើងឮក្រឡាស្វបន្លឺឡើង ។

- ហេតុដែលខ្ញុំប្រាប់មិនអោយឆើតឯងបង្ហាញមុខ អោយវិសេសសេនាឃើញ ព្រោះយើងត្រូវយកកំហុសរបស់យើងទាំងស្រុងទម្លាក់ទៅឱ្យវាទទួលចំពោះមុខតុលាការសឹក !..... តាមពត៌មានដែលខ្ញុំបានដឹង ស្អែកនេះព្រះករុណាទ្រង់ប្រទានមាសយ៉ាងច្រើនទៅអោយលោកពិជ័យរចនា យកទៅធ្វើជារូបសំណាកគោបាមួយយ៉ាងធំ ។ ពេលនេះ ខ្ញុំគិតថាត្រូវប្រគល់អោយឆើតឯងដឹកនាំគម្រោងការណ៍ទី ១ ចំណែកខ្ញុំកាន់កាប់គម្រោងការណ៍ទី ២ ។

- ព្រះតេជគុណ តើគម្រោងការណ៍ទី ១ របស់ខ្ញុំបាទមានដំណើរយ៉ាងណាទានប្រោស !

- ស្អែកនេះ លោកពិជ័យរចនា ត្រូវកាន់ព្រះរាជសារព្រះករុណាទៅបើយកមាសឯឃ្លាំមាស មកធ្វើរូបគោបាតាមព្រះរាជតម្រាស់ ។ នៅពេលដែលពិជ័យរចនាយកមាសបាន ហើយនាំមកឯមន្ទីរធ្វើការរបស់វា ឆើតឯងត្រូវស្ទាត់ចូលទៅប្លន់យកមាសនោះអោយបានណា !

- បាទព្រះតេជគុណ ខ្ញុំបាទនឹងគោរពតាមបញ្ជារបស់ព្រះតេជគុណទាំងអស់ !

- អើ ខ្ញុំសង្ឃឹមយ៉ាងមាំ លើឆើតឯងជាលើកទី ២ ហើយបើឆើតឯងសម្រេចទៅបាន កម្លាំងរបស់យើងច្បាស់ជាជឿនលឿនជាប្រាកដ ! ឯគម្រោង

ការណ៍ទី ២ ស្រេចនៅលើខ្លួនខ្ញុំចុះ !

- ប្របាទ ខ្ញុំនឹងខំអោយអស់ពីសមត្ថភាព ដែលខ្ញុំធ្លាប់បំពេញគ្រប់យ៉ាង ចំពោះអង្គការរបស់ព្រះតេជគុណ ។

- អើ ! យប់ជ្រៅណាស់ហើយ ទៅរកដេករកពួនចុះ ចាំស្អែកសឹមលៃលកទៅទៀត ។

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

# ៣

# អនិច្ចា ! លោកវិសេសសេនា

ព្រឹកនេះ នៅក្នុងអាណាខេត្តនៃលំនៅរបស់ក្រឡាសួ កងទាហានពិសេសរបស់គាត់មានសកម្មភាពប្រព្រឹត្តទៅយ៉ាងប្លែក ខុសពីសព្វដងទាំងអស់

ក្រឡាសួ គាត់តែងកាយដោយគ្រឿងសឹក ចុះពីលំនៅដោយទឹកមុខញញឹមទៅកាន់នាយឆើតដែលដើរត្រុន១ មករកគាត់ ។

- ម៉េចទៅឆើត ! សត្វកណ្ដុរដែលនៅក្នុងទ្រុងយើងយ៉ាងណាទៅហើយ ?

- ប្របាទ វាបែបច្រងេងច្រងាងណាស់ទានប្រោស ! ....... កាលក្នុងវំលងអាធ្រាត្រ ខ្ញុំប្របាទឮសូរក្ដុងក្ដាំងយ៉ាងខ្លាំងនៅក្នុងបន្ទប់ ។ ទ្រាំមិនបាន ខ្ញុំប្របាទក៏បើកទ្វារចូលទៅ ឃើញវាកំពុងតែច្របាច់កអ្នកយាមរបស់យើងម្នាក់ ខ្ញុំប្របាទក៏ប្រដៅវាធ្ងន់ដៃបន្តិច លុះត្រាតែវាសន្លប់ ។

- អើ ! បង្អន់វាយ៉ាងនេះខ្លះទើបបាន ព្រោះអានេះវាធ្លាប់ជាជើងឯកខាងការលោតហក់នេះជាយូរមកហើយ ! ...... តែឥឡូវនេះ ឆើតឯងត្រូវទៅឯភ្នំមាសមុនទៅ !

- ប្របាទ ចុះព្រះតេជគុណអញ្ជើញទៅអង្កាល់ដែរទានប្រោស ?

- ចំណែកខ្ញុំ ទៅក្រោយដំណើរលោកពិជ័យរចនាឯណោះទេ ! ........

ឆើតឯងត្រូវទៅមុន ហើយរកកន្លែងបង្កប់ខ្លួនអោយស្រួលបួលណ៎ា ! អូនៃ ! ប្រយ័ត្នតែខូចជើងការ មុខជាគ្រោះអាសន្នធំហើយ !

- ប្របាទ ! ទោះបីជាយ៉ាងណាក៏ខ្ញុំប្របាទមិនធ្វើការនេះអោយធ្វេសធ្វោយដែរ ទានប្រោស !

នាយឆើតឆ្លើយអះអាង ហើយក៏ត្រលប់មករៀបចំកិច្ចការរបស់វាតាមបញ្ជានៃលោកក្រឡាសួ ដែលខ្សិបប្រាប់វាពីនាទីមុន ។ វានាំសហការីរបស់វាបីនាក់ដើរមកកាន់បន្ទប់លោកវិសេសសេនា ។

ពេលនេះ វិសេសសេនា, ដែលកំពុងអង្គុយសញ្ជប់សញ្ជឹងស្ងឹងស្ងាធីក្នុងបន្ទប់, មានសេចក្ដីងឿងឆ្ងល់ និងឈឺចាប់ក្នុងឱរាយ៉ាងខ្លាំង ចំពោះការដែលជនមិនស្គាល់មុខ ចាប់រូបលោកយកមកធ្វើបាប ។

លោកអង្គុយសំយុងជើងនៅលើគ្រែ គិតយ៉ាងល្អិតល្អន់ពីរឿងនេះ តែលោកនៅតែមិនយល់ថា តើននរណាមួយចាប់រូបលោក ហើយគេយកមកដាក់ទីឃុំឃាំងនេះដើម្បីអ្វី ?

កំពុងតែលង់លក់អារម្មណ៍ទៅក្នុងពិភពគំនិត ដ៏ចង្អៀតចង្អល់នេះ ទ្វារបន្ទប់ក៏របើកឃ្វាំងឡើង ។ លោកវិសេសសេនា ភ្ញាក់វិញ្ញាណចេញពីភវង្គ ស្ទុះក្រោកឡើងបែរមុខផាំង សម្លឹងទៅនាយឆើត និងគូកនរបស់វា ដែលកំពុងបោះជំហានចូលមកយ៉ាងអង់អាច ។

ឃើញប្រត្យក្សនឹងភ្នែកដូច្នេះ ភ្លើងទោសៈដុតរោលពេញផ្ទាំងទ្រូងអ្នកក្លាហានដែលធ្លាប់បូជារូបកាយ និងជីវិតទៅបណ្ដេញខ្មាំងសត្រូវក្នុងមហា

សមរភូមិនារជ្ជកាលព្រះបាទសូរិយិន្ទ្រាវរ្ម័ន ។

ក្តៅណាស់ ! យុទ្ធជនជវាស្ទុះចូលទៅរកនាយឆើតទាំងកម្រោល ។

- ផាច់ ! អឿក !

លោកដាល់នាយឆើត ត្រូវមួយដៃយ៉ាងដំណំ ទើបថែមមួយដៃឆ្វេងទៀត បណ្តាលអោយវាប្រាសចាកស្មានភាព ។ គូកនរបស់ឆើត ឃើញអ្នកជាប់ឃុំរបស់ខ្លួនតំឡើងផ្ទង់ដាក់ឆើត ក៏ព្រួតគ្នាប្រយុទ្ធតបទៅវិញ បណ្តាលឱ្យការច្របូកច្របល់មួយយ៉ាងតូចប្រសូត្រឡើងនៅក្នុងបន្ទប់ ។

វិសេសសេនា កាលផ្តួលនាយឆើតហើយ ក៏ត្រូវរងកាត់នឹងទម្ងន់កញ្ឆប់ដៃ ព្រួតវាយរបស់ជនទាំងបីរូបឯណោះទៀត ។ គូប្រយុទ្ធវាយតប់គ្នាព្រួសប្រាសពេញក្នុងបន្ទប់ ។ នាយឆើតក្តៅនឹងវិសេសសេនាណាស់ គេហូតកាំបិតស្នៀតពីចង្កេះ ស្ទុះក្រោកចូលមកវែកកូនចៅគេទាំងបី បណ្តាច់ចេញពីវិសេសសេនា ទើបចាក់លោកមួយកាំបិតពេញទំហឹងដៃ ។

- ឈិប !

- អួយ ! .......

ផ្លែកាំបិតបានវែកសាច់ ទម្លុះយ៉ាងជ្រៅ ទៅក្នុងកំភួនដៃអ្នករងគ្រោះលោហិតក្រហមរន្ទាលឆ្អិនឆ្អៅស្ទុះចេញមក ដោយនាំនូវសេចក្តីចុកចាប់ពើតក្នុងមនោសញ្ចេតនា ស្នេហាជាតិមកជាមួយផង ។ ខ្លាចាស់បាក់ចង្កូម ទ្រុឌទ្រោមកម្លាំងពុំអាចបន្តការតយុទ្ធទៀតបាន ក៏បណ្តោយប្រាណអោយស្ថិតក្នុងការគម្រាមកំហែងរបស់សត្រូវតាមយថាកម្ម ។

អនិច្ចា ! នាយឆើតចិត្តចោរអន្ធពាល វាយតប់ទាត់ធាក់លោកវិសេសសេនាគ្មានត្រាប្រណី ។ អ្នករងគ្រោះទោះបីរូបកាយត្រូវទ្រម នឹងទម្ងន់ទារុណកម្មយ៉ាងសាហាវយង់ឃ្នងដូច្នេះក៏ដោយ ក៏ពុំត្អូញត្អែរពីការចាប់ពើតដល់បន្តិចឡើយ ។

ស្មារតីដ៏ក្លាហានរឹងប៉ឹងដូចដុំដែក ស្ថិតជាស្ថាពរក្នុងសន្តានចិត្តព្រឹទ្ធជននេះគ្មានរលប់បាត់ ។

- ភឹង ! វិប !

ឆើតទាត់មួយជើងចំឆ្អឹងជំនីរ ។ រាងកាយរបស់លោកក៏ប៉ើងដូចស្លឹកកណ្ដប. រសាត់ទៅប៉ះនឹងគ្រែឮសូរគ្រាំង ។ ក្បាលលោក ដែលទ្រាំទ្រនឹងទម្ងន់ទារុណកម្មជាច្រើនលើក ច្រើនគ្រាមកហើយនោះ ឥឡូវក៏បន្ថែមមកទៀតឥតត្រាប្រណី បែកហូរឈាមរហាមសស្រាក់សស្រាំ រកាំផ្សាក្នុងដួងចិត្តឥតបីប្រៀប ។

លោកវិសេសសេនា ពើតចុកចាប់ពេញឱរា ខំប្រឹងប្រវេប្រវាងើបមុខឡើងខាំធ្មេញ បញ្ចេញទម្ងន់ពាក្យស្នេហាជាតិ ដែលលោកបានជួយគាំទ្រ អស់ពីសមត្ថភាព និងដង្ហែតាមក្រោយព្រះប្រិយមហាក្សត្រដោយសុទ្ធចិត្ត ។

- អាតិរច្ឆាន ! សម្លាប់អញមក អញមិនអោយប្រជាជាតិទាំងមូលស្ថិតនៅក្នុងការបំផ្លិចបំផ្លាញរបស់អាឯងទេ ! ........ ពួកអាឯងជានរណា បានជាចាប់អញមកឃុំឃាំង វាយធ្វើបាបយ៉ាងសោគម្រក់ដូច្នេះ !

- ហ៊ិះ ! ហ៊ិះ ! សោគម្រក់ ! (ឆើតសើចចំអក) ចំពោះយើង ការធ្វើ

ទារុណកម្មប៉ុណ្ណេះ មិនសមនឹងគោលបំណងរបស់យើងទេ ឬមួយក៏ឯងមិនទាន់ពេញចិត្ត ?

- ប៉ុង ! ប្រូស !

វាចាចប់ អាឆើតទះលោកយើងមួយកំផ្លៀងយ៉ាងខ្លាំង បណ្ដាលឱ្យរាងកាយរបស់លោកដួលត្រាំជាលើកទីពីរ ។

លោកវិសេសសេនា ប្រឹងត្រដររើបឡើងម្ដងទៀតយ៉ាងលំបាក ទើបបន្តវាចាចុកចាប់ទៅទៀត ។

- ហ៊ិះ អាតិរច្ឆាន ! អញមើលទៅរង្វង់មុខអាឯង អញយល់ថាជនជាតិសុវណ្ណភូមិរួមត្រកូល ពូជពង្សវង្សាសាសន៍ដូចអញដែរ អាឯងមិនគួរធ្វើបាបអញសោះ ! ......... អាឯងធ្វើទារុណកម្មអញប៉ុណ្ណេះមិនពេញចិត្តអញទេ ! សម្លាប់អញមក ......... បើឯងទុកអញគ្រាន់សម្រាប់ធ្វើបាបយ៉ាងនេះទេ តើប្រាថ្នាអ្វីប្រាប់អញមក ! ........... អាកំសាក ! ..........

ហាស់ ! ហាស់ ! ឆ្លើយ !

ឆើតឈរច្រត់ចង្កេះ មើលទៅអ្នករងគ្រោះដែលកំពុងតែស្ដាបនាឆាកទារុណកម្មក្នុងថ្លុកលោហិត ។ គេស្ដោះទឹកមាត់ដាក់មុខព្រឹទ្ធបុរសនេះ ទើបបន្តវាចាថា ÷

- ឯងចូលចិត្តនិយមតែធ្វើមិនដឹងខ្លួន យ៉ាងនេះហើយ តើដែលយើងមានករណីនឹងរំលាយរូបឯងចោល ! ....... អាកញ្ជាស់ឯងជាជាតិសាសន៍ដូចអញមែន តែអាឯងមានចិត្តថ្លើមមិនដូចអញទេ ! ........ ស្គាល់អញទេ ?

- អញថីក៏មិនស្គាល់ (វិសេសសេនាតប) អាឯងជាពួកចោរប្លន់ ដើរតែកាប់សម្លាប់អ្នកស្រុក បើពុំនោះសោតទេ អាឯងជាបរិវាររបស់អាមេក្បត់ជាតិឈ្មោះរាមរាជ្យ !

- ឈប់និយាយ ! ហ៊ឺះ ! អាសត្វខ្លាបាក់ចង្កូមជាប់ទ្រុងដែកហើយនៅបានសម្តែងទៀត ! ......... អញមិនពឹងអាឯងមកធ្វើហោរាទស្សន៍ទាយរូបអញទេ .......... ហាំ ពួកយើងចាំដល់ណាទៀតលេងមួយជើងម្នាក់អោយវាស្គាល់ដៃទៅមើល ! .........

ស្ទើរមិនទាន់ផុតពីមាត់ ជនអន្ធពាលបីនាក់ទៀត ក៏ស្ទុះរ៉ាវមកទាត់ធាក់លោកវិសេសសេនាទាំងកម្រោល លុះត្រាតែលោកសន្លប់បាត់ស្មារតី ។

ព្រះនភមណី យាងកាត់កណ្តាលពួងអាកាស ឆ្លងរំលងត្រង់ជាក់ទៅហើយ ការធ្វើដំណើរនៃពួកក្បត់ និងបរិវារ ក៏ត្រូវចាកចេញពីលំនៅដ្ឋាន តាមរទេះដំបូលមួយសំដៅទៅភ្នំមាស ។

យើងឆ្ងល់ណាស់ នៅកណ្តាលរទេះ មានបាវមួយចងមាត់ជិត ពុំអាចកាត់បានស្មានត្រូវថា នៅក្នុងបាវនោះ មានវត្ថុអ្វីឡើយ ។

នាយឆើត មិនជិះក្នុងរទេះជាមួយគេទេ នាយជាមគ្គុទេសក៏ ជិះសេះយ៉ាងសង្ហានាំបរិវាររបស់វា ទៅកាន់ទីដៅ ។ តាមដងផ្លូវវាធ្វើការពិនិត្យហ្មត់-ចត់ណាស់ ព្រោះខ្លាចក្រែងកងទ័ពព្រះរាជាទ្រង់ជ្រាបនូវផែនការសម្ងាត់របស់ពួកវា តែជាកុសលដែល គ្រប់ជិហានរបស់ពួកវា គ្មានឧបសគ្គអ្វីមកបៀតបៀនឡើយ ។

នៅតាមផ្លូវលំយ៉ាងចង្អៀតនេះ ការធ្វើដំណើរប្រកបដោយសុវត្ថិភាព ចេះតែខិតទៅមុខបន្តិចម្តងៗ ជាលំដាប់ ទៅតាមពេលវេលាដែលកំពុងទន្រ្ទាន កាត់អង្គសម្ផស្សធម្មជាតិទាំងមូល ។

ព្រះអាទិត្យយាងឆ្ពោងទាបបន្តិចទៅហើយ ។ ក្រោមសីតុណ្ហភាពជាមធ្យមនៃកាំរស្មីព្រះអាទិត្យ រទេះនៃពួកក្បត់ទាំងនេះ បត់ក្បាលសំដៅមហាគិរីដែលឋិតនៅបង្អើយពីមុខពួកវា ។

- ឆ្វេក .........

នេះជាសញ្ញារបស់អាឆើត ដែលបន្លឺឡើងប្រាប់ក្រុមបក្សសម្ព័ន្ធក្បត់ទាំងប៉ុន្មាននាក់ ។

រហ័សដូចចិត្ត ក្រុមក្បត់បត់ក្បាលចូលទៅពួនក្នុងលង្វែកព្រៃមួយរំពេច ព្រោះនៅឯនាយខាងក្រោយ គេឮសូរសទ្ទឹកជើងសេះខ្លាំងណាស់ ។

ពួកយើងត្រូវបត់រទេះចូលពួនក្នុងព្រៃនេះសិន ហើយត្រូវសម្ងំអោយស្ងៀម ស្នូរសទ្ទឹកជើងសេះនេះ ច្បាស់ជាលោកពិជ័យរចនា នាំគ្នាមកយកមាសហើយ ។

ជាភ័ព្វសំណាងរបស់វាដែរ ទើបតែនឹងចូលផុតបន្តិចក្នុងលង្វែកព្រៃរនាម ស្នូរជើងសេះក៏កាន់តែសន្ធាប់ជិតមកៗ ជាលំដាប់ ដរាបដល់កន្លែងនេះមួយរំពេច ។

ឆើតបុកពោះភិបៗ ខ្លាចក្រែងពួកវា ធ្វើអោយលេចឮនូវភេរវស័ព្ទអ្វីម្យ៉ាង ដែលជាហេតុនាំអោយបែកធ្លាយគម្រោងការណ៍នេះ ។ វាងាកមើលទៅ

កូនចៅរបស់វា ទាំងក្រសែភ្នែកព្រួយបារម្ភ ទើបលួចវែកស្លឹកឈើយ៉ាងថ្នមៗ មើលទៅក្បួនដំណើរដែលកំពុងបោះជំហានទៅមុខយ៉ាងស្វាហាប់ ក្រោមការដឹកនាំរបស់លោកពិជ័យរចនា ។

ឆើតនឹកភ្លាមថា ពិតជាលោកពិជ័យរចនា ធ្វើដំណើរទៅយកមាស ដើម្បីធ្វើរូបសំណាកគោបាហើយ ។ វាត្រេកអរណាស់ ក្រោយពេលដែលពួកទាហ៊ានទាំងនេះ ធ្វើដំណើររំលងផុតទៅ វាងាកមកញញឹម វាយចិញ្ចើមម្ខាងព្រើតជាសញ្ញាដាក់សហការីវាទាំងអស់ ដែលកំពុងពួននៅជិតវា ។

- យើងនៅរង់ចាំពួកវាត្រង់កន្លែងនេះចុះ តាមស្មានមើលទៅ ប្រហែលជាមួយស្របក់ធំប៉ុណ្ណោះ វានឹងត្រលប់មកវិញតាមផ្លូវដដែលនេះហើយ ........ ឥឡូវពួកឯងសម្រាកសិនចុះ តែកុំធ្វើអោយលេចឮសូរស័ព្ទអ្វីអោយសោះណ៎ា ..... ចំណែកអញៗ នៅក្រោមដើមពោធិ៍ ។

ចប់ចុងប្រយោគ ឆើតក្រោកដើរចេញពីគម្ពោតព្រៃ នៅបង្កប់ខ្លួនក្នុងសន្លឹកពោធិ៍យ៉ាងស្ងៀមស្ងាត់ ដោយការប្រុងប្រៀបជានិច្ច ។

ព្រះពាយត្រជាក់បក់ធ្លាក់រំភើយៗ បបោសអង្អែលដើមរុក្ខជាតិតូចធំឲ្យរញ្ជួយទោរទន់ទៅវិញទៅមកកណ្ដាលព្រៃស្រោង ក្រោមទេសភាពយាមសាយណ្ហ ដែលរចនាឡើងដោយសម្លេងនាដកម្មនៃពួកម្រឹគីម្រឹគា និងបក្សាបក្សីរំពងពេញអរញ្ញវា ។

នៅលើចុងរុក្ខាឯណោះ ក្រៅពីសម្លេងសត្វរៃ, សត្វចាប, និងមាន់ព្រៃ តែងបន្លឺសូរសៀងពិរោះលន្លង់លន្លោច ហាក់ប្រណាំងប្រជែងនឹងសម្រែកដ៏រស្ដ

ស្រែកសង្ឃកមកម្តង។ គួរអោយព្រឺព្រួច តែចំពោះបក្សពួកអាឆើតវិញ សម្លេងធម្មជាតិទាំងនេះ មិនជាទីភ័យបារម្ភប៉ុន្មានទេ ប្រែជាតន្ត្រីយ៍មួយវង់យ៉ាងជាប់ចិត្តដិតអារម្មណ៍ក្រៃលែង ព្រោះត្បិតក្នុងខ្សែជីវិតវាទាំងអស់គ្នា បានស៊ាំស៊ុបក្នុងបរិយាកាសនេះ ជាយូរយាណាស់មកហើយ ។

ការពួនស្ទាក់ចាំ ផ្តល់នូវសេចក្តីរំខានដល់ក្បួនដឹកនាំមាសចេញពីភ្នំមាស មកកាន់រាជធានីអស់ថិរៈវេលាយូរក្រៃលណាស់មកហើយ តែទោះបីជាយ៉ាងណា ក៏ពួកវានៅតែរក្សាសេចក្តីរៀបរយរបស់វាក្នុងទ្រូងព្រៃ អោយបានល្អប្រពៃជាដរាប ។

សូរជើងសេះក៏ឧបត្តិកឡើងសាជាថ្មីម្តងទៀត ស្ទុះចូលមកន្រ្ទាក់វិញ្ញាណអាឆើត និងក្រុមបក្ស អោយផ្តើមការប្រុងប្រៀបនឹងសម្រេចតាមផែនការរបស់វា ។

គ្រេកអរណាស់, បេះដូងនាយឆើតរីកប៉ោងឡើងដោយត្រូវព្យុះនៃសេចក្តីរីករាយ បញ្ជាក្រុមបក្សរបស់វាអោយក្រោកឈរឡើងកាន់អាវុធ ចូលប្រយុទ្ធនឹងទាហានដែលតាមឆ្កករទេះដឹកមាស ។

ជើងសេះជាច្រើន សន្ធាប់ចូលមកព្ទគុប ! គុប ! កក្រើកផែនធរណីប្រៀបបាននឹងចង្វាក់ស្គរដែលទូងឡើងដាស់សតិពួកទ្រុស្តជាតិ អោយត្រៀមខ្លួនចូលធ្វើការវាយកំចាត់ក្នុងពេលបន្តិចទៀតនេះ ។

អាឆើតក៏បន្លឺទៅកាន់មិត្តរួមកម្លាំងរបស់វា ÷

- នែ អាព្រលួង, អាសុខ អាឆ្មែកែវ អញប្រគល់ភារៈអោយឯងទាំង

បី កាន់កាប់រទេះបិទដំបូល ........ ពេលណាអញចូលទៅវាយលុកសម្រុកពួកទាហានឆ្មករទេះមាសបានបន្តិច ឯងត្រូវតែស្រាយមាត់បាវនេះចេញ ហើយត្រូវប្រព្រឹត្តតាមគ្រោងការណ៍ដែលអញបានប្រាប់រួចមកហើយ ! ឯងត្រូវប្រុងប្រៀបអោយមែនទែនណា ! ឥឡូវទៅចាត់ការភ្លាម១ ទៅ ពួកដឹកមាសមកកាន់តែជិតណាស់ហើយ ។

នាយព្រលូង, ឆ្មៃកែវ, និងសុខ ទទួលបញ្ជាពីឆើតហើយ ក៏ត្រលប់មករទេះបិទដំបូលវិញ ។

ក្បួនដឹកនាំមាសពីភ្នំមាសដែលគេឃើញលឹម១ ពីចម្ងាយពីនាទីមុនបានលូនចូលមកជិតជាលំដាប់ ។ ឆើត និងបរបក្សជាដៃជើង ត្រៀមខ្លួននៅលើខ្នងសេះប្រុងបោលចូលទៅវាយលុកពួកទាហាននេះតែម្តង ។

រទេះមាសចូលមកដល់ហើយ អាក្បត់ទាំងអស់ហូតដាវខ្វាកឡើងព្រមគ្នា ស្រែកបោកព្រៀវខ្សៀវខ្វា ចូលវាយសម្រុកកងទាហាន ដែលកំពុងឋិតនៅក្រោមការដឹកនាំនៃលោកពិជ័យរចនា ។

- ចូល ! កនយើងចូល !

លោកពិជ័យរចនា ឃើញភេរវជនប្រកបដោយគ្នាច្រើនចូលមកយារ-យី ក៏ចេញបញ្ជាអោយទៅទាហានទាំងអស់ដកអាវុធតយុទ្ធតបទៅវិញយ៉ាងអង់អាច ។

- កាត់ក្បាលអាចោរប្លន់អោយអស់ពួកយើង !

ពេលនេះ គូបដិបក្សទាំងសងខាង ក៏ដកអាវុធចូលប្រយុទ្ធគ្នាយ៉ាង

កាចសាហាវ ។

លោកពិជ័យរចនា ពុំបានចេញទៅឯណាឆ្ងាយពីរទេះមាសឡើយ ។ លោកបានបញ្ជាអោយទាហានទាំងអស់ស្ថិតជារបងការពាររទេះនេះ អោយយ៉ាងមុតមាំ ដើម្បីកុំឱ្យភេរវជនចូលមកប្លន់យកមាសពីក្នុងរទេះនេះបាន ។

សភាពច្របូកច្របល់ ដែលបណ្ដាលមកពីការវាយប្រហារនេះបានធ្វើអោយអារញ្ញប្បទេសទាំងមូល ផ្ទុះដោយសម្លេងដាវដែលប៉ះទង្គិចគ្នា ប៉ែស ! ប៉ែស ! លាន់ឮទ្រហឹងអឺងអាប់ សូរសព្ទដូចរន្ទះ ញ៉ាំងទីស្មសានឋានស្ងាត់នេះក្លាយទៅជាផ្ទាំងគំនូរដ៏រស់រវើក ក្រហមច្រាលដាលដោយលោហិត ជិតជាប់ពាសប្រថពី !

លោកពិជ័យរចនា មានការព្រួយបារម្ភច្រើនចំពោះមហាឧបសគ្គទាំងនេះ ដែលពុំបានចាប់ភ្លឹកថាមានភេរវជន លើកគ្នាមកប្លន់យកមាសពីលោកឡើយ ។ ពេលនេះលោកគិតថា សត្រូវវាយយករទេះមាសបាន លោកធ្វើអត្តឃាតកម្មខ្លួនលោកមួយរំពេច ។

- ពួកទាហាន ! ប្រុងប្រយ័ត្នអោយមែនទែន ......... ធ្វើរបងការពាររទេះយើងអោយមាំ កុំអោយអាចោរយង់ឃ្នងចូលមកយាយីបានឱ្យសោះ !

ពោលបណ្ដើរ លោកពិជ័យរចនាញាក់សេះចូលមករកបច្ចាមិត្រដែលកំពុងវាយបណ្ដាក់គ្នាព័ទ្ធជុំវិញកងទាហានរបស់លោក ។

គូប្រយុទ្ធទាំងសងខាង ពុំទាន់ឃើញខាងណាអន់ដៃរបស់ខាងណានៅឡើយទេ តែដោយសេចក្ដីក្លាហានរបស់ទាហានអ្នកស្នេហាជាតិយើង បានរំ-

លាយខ្លួនបច្ចាមិត្រអស់បីនាក់រួចទៅហើយ ។

ទោះបីជាយ៉ាងនេះក៏ដោយ ក្រុមបក្សចោរប្លន់ឥតធ្វើកំហឹងក្រេវក្រោធឡើយ ។ វាវាយនេះគ្រាន់ជាការគម្រាមកំហែង ដើម្បីរង់ចាំទ័ពលោកក្រឡាសូ ចូលមកជួយលោកពិជ័យរចនា គេនឹងអាលដកដៃវត់ប៉ុណ្ណោះ ។

យើងឆ្ងល់ណាស់ ហេតុដូចម្ដេចក៏លោកវិសេសសេនាមកដល់ទីនេះដែរ ។ ខណៈនេះ លោកកំពុងឋិតនៅក្រោមការធ្វើបាបរបស់ក្រុមចោរយ៉ាងសោករន្ធត់ ។

ពេលជាមួយ អាសុខក្រឡេកទៅនាយឃើញទ័ពលោកក្រឡាសូមកដល់ ក៏ក្លែងជាស្រែកប្រាប់ទៅឆ្មៃកែវថា ÷

- នែអាកែវ ទុកវាធ្វើអ្វី ! លេងមួយដាវទៅ ក្រឡាសូលើកមកព័ទ្ធយើងទៀតហើយ !

- ខ្ញាប់ !

ឆ្មៃកែវទម្លាក់ដាវយ៉ាងធ្ងន់ ទៅលើភ្លៅលោកវិសេសសេនា ទើបនាំគ្នារត់ទៅចាប់សេះហក់ផែលឡើងជិះចេញទៅមួយរំពេច ។

អនិច្ចា លោកវិសេសសេនា លោកស្រែកបានតែអូយមួយម៉ាត់ប៉ុណ្ណោះ ក៏ដួលគ្រុបទៅលើព្រះធរណីហើយប្រកាច់រមួលយ៉ាងសែនខ្លោចផ្សា ។

ក្រឡាសូ មានសេចក្ដីត្រេកអរណាស់ កាលបើឃើញបក្សពួករបស់គេ ធ្វើការបានសម្រេចដូចគោលបំណង ។ គេនាំកងពិសេសរបស់គេ ជិះចូលមកកាន់សមរភូមិយ៉ាងលឿន ហាក់ដូចជាភិតភ័យនឹងគ្រោះថ្នាក់របស់កងទា-

បាន ដែលតាមការពាររទេះដឹកមាសណាស់ ។ គេធ្វើជាស្រែកសន្ធាប់ពីនាយ ថា ÷

- កនយើង ! ចូលទៅកាត់ក្បាល ពួកអាចោរប្លន់ដែលចូលមកដណ្តើម ព្រះរាជទ្រព្យ ........ ចូល ...........

នាយឆើតឃើញចៅហ្វាយ មកជិតដល់ណាស់ទៅហើយ ក៏អោយសញ្ញាទៅបក្សពួកគេដកឃ្លាចេញយ៉ាងរហ័សរហួន ។

- ដកឃ្លាថយពួកយើង ! ទាហានមកច្រើនណាស់ !

មិនបានសង្ស័យក្រុមបក្សចោរប្លន់ក៏បត់ក្បាលសេះចេញពីសមប្រយុទ្ធ ជិះដោះខ្លួនយ៉ាងលឿន ។ ក្រឡាសូ ឃើញដូច្នោះក៏ស្រែកបង្អើលពីក្រោយថា ÷

- តាមពួកយើងតាម ! តាមកាត់ក្បាលពួកអាចោរទាំងនេះឱ្យបាន ...

បានដូចចិត្ត កូនទាហានដែលទទួលបង្គាប់ ពីចៅហ្វាយទ្រុស្តជាតិរូច មកហើយ ក៏ធ្វើជាដេញតាមបក្សពួកនាយឆើតយ៉ាងស្វាហាប់ ។ លោកពិជ័យរចនា និងកូនទាហានរបស់លោកទាំងអស់ ត្រេកអរណាស់ដោយឃើញក្រឡាសូ នាំកូនទាហានមួយក្រុមមក ជួយលោកក្នុងពេលមានអាសន្នធំនេះ ។

ក្រឡាសូដេញតាមពួកនាយឆើតបន្តិច ទើបត្រឡប់មករកលោក ពិជ័យរចនាវិញ ។

- ម៉េចទៅលោក មានរបួសកូនទាហាន ឬខូចខាតអ្វីខ្លះ ? (ក្រឡាសូ សួរដោយយកចិត្តទុកដាក់) ។

- បាទគ្មានគ្រោះថ្នាក់អ្វីទេ ! ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ

ចំពោះលោក បើកុំតែបានលោកមកជួយទាន់ ច្បាស់ជាពួកចោរអម្បាញ់មិញ ប្លន់យកមាសក្នុងរទេះនេះ ខ្ទេចខ្ទីជាមិនខាន ! ហើយខ្ញុំក៏ប្រហែលជាពុំបានរស់រានមានអាយុតទៅទៀតដែរ ។

- បាទលោក ! មិនមែនជាគុណស្រ័យអ្វីទេ ! ......... នេះក៏រាប់ថាជាភ័ព្វដ៏ប្រសើររបស់លោកហើយ ម្យ៉ាងវិញទៀតជាករណីយកិច្ចចាំបាច់ដែលខ្ញុំត្រូវជួយគាំទ្រជាតិសាសនា, ព្រះរាជបល្ល័ង្កប៉ុណ្ណោះឯង តែខ្ញុំសូមសរសើរពីជីវិតដ៏ថ្លៃរបស់លោកបណ្ដាលអោយខ្ញុំនឹកបារម្ភនៅធ្វើការមិនកើត ក៏នាំទាហានមកឃ្លាំមើលតាមផ្លូវ ក្រែងហេតុការណ៍មិនស្រួលកើតមានឡើង ឥឡូវស្រាប់តែមានដូចសេចក្ដីស្មាននេះមែន ។

- អូយ ! លោកអើយជួយខ្ញុំផង !

នេះជាចំណុចសំខាន់ ដែលក្រឡាសូកំពុងត្រូវការ ក្រោយពីឮសម្លេងថ្ងូរនេះ អាមេក្បត់ក្រឡេកទៅគម្លោតព្រៃម្ខាង ក៏យល់លោកវិសេសសេនាហើយក្លែងជាសួរទៅលោកពិជ័យរថនាឥតបង្អង់ ÷

យីលោក ! នរណាត្រូវរបួសដេកថ្ងូរ ឯគម្លោតព្រៃឯនោះន៎ ?

- ទេ ! កូនទាហានខ្ញុំគ្មានត្រូវរបួសម្នាក់ទេលោក !

- បើឥចឹងនរណាថ្ងូរ ? លោកស្ដាប់មើល ?

ទាំងអស់គ្នាក៏ផ្ទៀងត្រចៀក ស្ដាប់សម្លេងនេះយ៉ាងពិនិត្យពិច័យតទៅទៀត ។

- នុះ ហ្ន៎ ! អូ ........ មានមនុស្សត្រូវរបួសនៅត្រង់គម្លោតព្រៃឯនោះ

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY

មែនហើយ !

ផុតចុងប្រយោគ ក្រឡាសូញ្ញាក់សេះជិះតម្រង់មកកន្លែងនេះភ្លាម ។ លោកពិជ័យរចនា និងទាហានពីរបីនាក់ ក៏នាំគ្នាជិះសេះតាមក្រោយក្រឡាសូមកកាន់ទីនេះដែរ ។

- យី ! លោកវិសេសសេនាត្រូវរបួស ! ........ លោកពិជ័យជួយលោកផង ..... យី ! ត្រូវរបួសខ្លាំងណាស់ ........ ហេតុដូចម្ដេចក៏បានជាឥចឹង ?

លោកពិជ័យ គ្រាន់តែឃើញលោកវិសេសត្រូវរបួសទម្ងន់ភ្លាម គិតក្នុងចិត្តថា ÷ លោកជាមនុស្សក្បត់ដែលនាំគ្នាមកប្លន់អម្បាញ់មិញនេះឯង ។ លោកមិនទាន់ចេញស្ដីថាដូចម្ដេច តែមួយរយៈក្រោយមក ទើបលោកបញ្ជាទៅកូនទាហាន ÷

- ទាហាន ! នាំគ្នាគ្រាហ៏លោកវិសេសសេនាយកទៅដាក់លើរទេះអញភ្លាម ។

- ព្រួស ! ព្រួស ! ព្រួស !

ទាហាន បីនាក់ហក់ចុះពីខ្នងសេះ នាំគ្នាចាប់គ្រាហ៏ជនរងគ្រោះ យកមករទេះមួយរំពេច ។

លោកវិសេសសេនា កាលបើឃើញក្រឡាសូ និងលោកពិជ័យរចនា មានសេចក្ដីត្រេកអរណាស់ លោកគិតថាពេលនេះជីវិតលោកនឹងបានហែលឆ្លងផុតពីចង្កូមមរណៈហើយ ។ លោកញញឹមមកកាន់ក្រឡាសូ និងលោកពិជ័យរចនា ដោយសម្លេងខ្សាវ់ៗ ថា ÷

- ខ្ញុំសូមថ្លែងអំណរគុណ ចំពោះលោកជាអតិបរមា ! អម្បាញ់មិញនេះខ្ញុំនឹកស្មានថា មិនបានរស់រានមានជីវិត នៅបំរើព្រះប្រិយមហាក្សត្រយើងទៀតទេ !

- មកពីរឿងអ្វី ?

ក្រឡាសូសួរដោយកំបុត ។

- ពួកភេរវជនមួយក្រុម បានចាប់ខ្ញុំទៅធ្វើបាបយ៉ាងវេទនា ហើយវានាំខ្ញុំមកកន្លែងនេះ រកសម្លាប់ខ្ញុំចោលទៀត កុំតែបានលោកមកទាន់ .... អូយ .. ខ្ញុំចុកចាប់ណាស់លោក !

- ហាស់ ! ហាស់ !

ក្រឡាសូអស់សំណើច ធ្វើអោយលោកពិជ័យរចនា និងក្រុមទាហាននឹកឆ្ងល់យ៉ាងខ្លាំង ។

- លោកត្រូវភេរវជនចាប់ ឬក៏លោកនាំភេរវជនមកប្លន់មាសរបស់ព្រះករុណាជាអម្ចាស់ជីវិត ?

- មែនលោកក្រឡាសូ (លោកពិជ័យបន្ថែម) ខ្ញុំដូចជាឆ្ងល់នឹងអាកប្បកិរិយារបស់លោកវិសេសសេនាណាស់ ! ...... ខ្ញុំនឹងទូលព្រះករុណាពីឧបទ្ទវហេតុនេះហើយ ........

លោកពិជ័យសេនា ចាក់សំដីស្របលោកក្រឡាសូ ព្រោះគិតស្មានថាពាក្យសំដីរបស់លោកវិសេសសេនាជាពាក្យ ដែលលោកប្រឌិតឡើងដើម្បីគេចខ្លួនអោយផុតពីគ្រោះថ្នាក់នេះ ។

លោកវិសេសសេនា ឃើញគេនាំគ្នាសង្ស័យលើរូបលោក ក៏ប្រឹងប្រកែកតទៅទៀត ÷

- លោកជឿខ្ញុំចុះ ! ខ្ញុំមិនដែលមានចិត្តក្បត់ជាតិសាសនា និងព្រះរាជបល្ល័ង្កទេ ! ......... តែបើលោកស្មានថាខ្ញុំនាំភេរវជនមកប្លន់នោះ ពិតជាត្រូវបាបហើយ ! ហើយកាយវិការ និងចលនារបស់ខ្ញុំនេះ គឺគ្រាន់តែស្ថិតនៅលើដំណើរមួយដូចសុភាសិតសំដែងថា "អួសសំរាស់ប្រទះពាក្យ" ឬក៏ជាន់លើដានជើងចោរប៉ុណ្ណោះឯង ........ តែការពិតខ្ញុំជាមនុស្សស្លូតត្រង់ស្គាល់បុណ្យ ស្គាល់បាប ឥតបានរួមគំនិតជាមួយភេរវជនទេ មានតែភេរវជនទាំងនោះចាប់ខ្ញុំទៅធ្វើបាបប៉ុណ្ណោះ !

- ខ្ញុំសូមលោកអភ័យទោសទៅចុះ ! (ក្រឡាសូបញ្ចេញយោបល់) ពេលនេះ ទោះបីជាលោកខំដោះសារអោយខ្ញុំជឿយ៉ាងណា ក៏ខ្ញុំមិនជឿជាដាច់ខាត ព្រោះហេតុការណ៍វាកើតឡើងមានដំណើរស្របគ្នាណាស់ ! ក្នុងឋានៈខ្ញុំជាមេទ័ពរង ខ្ញុំសូមលោកអនុញ្ញាតអោយខ្ញុំធ្វើការឆែកឆេរទៅលើខ្លួនលោកបន្តិចសិន !

- សូមលោកឆែកឆេរទៅចុះ បើរកឃើញភស្តុតាងអ្វីបញ្ជាក់ថាខ្ញុំជាមនុស្សក្បត់ សូមលោកកាត់ក្បាលខ្ញុំភ្លាមចុះលោក !

- ហេះ ! ហេះ ! អរគុណណាស់លោក តែខ្ញុំគ្មានសិទ្ធិនឹងកាត់ក្បាលលោកទេ ទោះបីជារកឃើញភស្តុតាងថាលោកក្បត់ក៏ដោយ !

ផុតវាចា ក្រឡាសូ ក៏លូកស្ទាបសញ្ចៀកកាយលោកវិសេសសេនា ។

ពេលនេះហត្ថាគេប្រទះនឹងវត្ថុអ្វីមួយដុំ គេក៏ទាញយកមក រួចនិយាយថា÷

- ស្អីនេះ លោកវិសេសសេនា ?

ធ្លាក់ថ្លើមក្តុក លោកវិសេសសេនា បើកភ្នែកមើលទៅបំពង់មួយ រាងមូលទ្រវែងរំលេចដោយក្បាច់យ៉ាងប្រណិត ។

- យី ! ចុះលោកយកក្លាក់សារពីណាមកបន្លំ ចោទខ្ញុំយ៉ាងនេះ ?

- នៅអោយស្ងៀម ! (ក្រឡាសូគម្រាម)

លោកពីជ័យរចនា ឃើញបំពង់ក្លាក់សារ ក្នុងចិត្តចង់ដឹងណាស់ថាតើក្នុងក្លាក់នេះមានអ្វីទៅ ?

- លោក ! បើកទៅមើល តើមានអ្វីនៅក្នុងក្លាក់នេះ ! ....... តាមខ្ញុំយល់ថា គ្មានអ្វីក្រៅពីសំបុត្រទេ !

- ខ្ញុំក៏យល់ដូចលោកដែរ ! តែយើងពុំអាចបើកមើលបានទេ យើងទុកថ្វាយព្រះករុណាវិញ !

លោកវិសេសសេនា សែនតក់ស្លុតរន្ធត់ញាប់ញ័រអស់អង្គប្រាណ ចំ-ពោះអាកប្បកិរិយារបស់លោកក្រឡាសូ និងលោកពិជ័យរចនា ។

- បរពិត្រព្រះម្ចាស់ស្ងួតិ សូមជួយរូបខ្ញុំម្ចាស់ផង ! ....... តើខ្ញុំមានបាបរឿងអ្វី ក៏មានទុក្ខយ៉ាងនេះ ! ....... ឱក្លាក់សារ តើសំបុត្រនៅក្នុងនោះមានសេចក្តីថាដូចម្តេចទៅ ! ឬមួយក៏គេចោទខ្ញុំថាខ្ញុំក្បត់រាជបល្លង្ក ? .... ទេ ! ទេ ! ខ្ញុំស្រលាញ់ជាតិខ្ញុំណាស់ ម្តេចក៏ព្រះជាម្ចាស់ដាក់ទារុណកម្មខ្ញុំដូច្នេះទៅវិញ ! ... ព្រះប្រិយមហាក្សត្រ តើព្រះអង្គជឿថាខ្ញុំក្បត់ព្រះអង្គដែរឬ ?

អាណិតណាស់, ព្រឹទ្ធជនដែលមានសេចក្តីស្វាមីភក្តិចំពោះជាតិ និងរាជបល្លង្ក, បង្ហូតដង្ហើមយ៉ាងវែងដើម្បីនិទេសកងទុក្ខសោកសៅ ឱ្យរសាត់ទៅតាមខ្សែព្រះពាយ ហាក់ដូចជាកំពុងដង្ហោយហៅវត្ថុដ៏សក្តិសិទ្ធិគ្រប់យ៉ាងអោយចុះមកជួយលោក ព្រោះលោកក៏មានគុណលើជាតិ ពុំដែលមានចិត្តប្រទុស្តរាយនឹងជាតិឡើយ ។ គិតចុះគិតឡើង គ្មានអ្វីដោះស្រាយក្រៅពីការបណ្តោយតាមយថាកម្មទៅចុះ ចំពោះជីវិតលោកមួយ លោកមិនស្តាយទេ តែលោកនៅនឹកបារម្ភទៅដល់វាសនា នៃអនាគតសុវណ្ណភូមិ តើប្រែជាដូចម្តេចទៅវិញ ។

ខណៈនេះ លោកក្រឡាសូនិយាយឡើង ÷

- លោកពិជ័យរចនា ! ខ្ញុំសូមអោយលោកនាំលោកវិសេសសេនាយកទៅទុកដាក់អោយស្រួលបួល ចំណែកខ្ញុំត្រូវយកក្លាក់សារនេះទៅថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ! ........

- បាទ ! អញ្ជើញទៅមុនចុះ ! ពួកយើង បន្តដំណើរទៅមុខទៀត !

គ្រានោះរទេះក៏ចាប់លូនចេញពីជើងភ្នំមាស ក្រោមការឃ្លាំយាមយ៉ាងហ្មត់ចត់នៃកងទាហានរបស់ក្រឡាសូ និងកងទាហានឆ្មកររបស់លោកពិជ័យរចនា ។

# ៤

# មហន្តរាយនៅគោកធ្លក

រសៀលក្នុងថ្ងៃដដែលនេះ   នៅពេលដែលព្រះអាទិត្យយាងទាបគង មាត់ភ្នំទៅហើយ គេបានបញ្ជូនខ្លួនលោកវិសេសសេនា មកថ្វាយចំពោះព្រះភ័ក្ត្រ ព្រះរាជាជាអម្ចាស់ជីវិតលើត្បូង ។

ព្រះបាទសាយណ្ណាវ័ន្ត   ទ្រង់ព្រះសណ្ដាប់នូវសេចក្ដីរាយការណ៍របស់ លោកឧកញ៉ាពិជ័យរចនា  និងសេចក្ដីបន្ថែមខ្លះរបស់ក្រឡាសួ  ដោយបង្ហំទូល ថ្វាយនូវលិខិតក្លែងក្លាយមួយសន្លឹក ដែលមានក្នុងក្លាក់សារនោះផង ព្រះអង្គក៏ ទ្រង់ព្រះពិរោធនឹងផែនការនេះយ៉ាងខ្លាំង ។

គណៈរដ្ឋមន្ត្រី សេនាបតីទាំងអស់ ដែលបានចូលមកក្នុងកិច្ចពិភាក្សា នេះដែរ មានសេចក្ដីតក់ស្លុតរន្ធត់នឹងរឿងនេះគ្រប់ៗ គ្នា ។ បរិយាកាសនៅក្នុង ព្រះរាជវាំង គ្របដណ្ដប់ទៅដោយសភាពចង្អៀតចង្អល់មហិមា ។

អនិច្ចា ! លោកវិសេសសេនាជាប់ចោទក្នុងរឿងនេះក៏មិនខុសពីសត្វ ពពែ និងស្វាដែរ ។ រាងកាយទ្រម ប្រឡាក់ឈាមពាសពេញសំលៀកបំពាក់ ។ ជនជាប់ចោទប្រឹងបើកប្រអប់មាត់ ទូលព្រះករុណានូវសេចក្ដីស្វាមីភក្តិរបស់ខ្លួន

- បពិត្រព្រះសម្មតិទេពដ៏ជាកំពូល   តើអាណាចក្រសុវណ្ណភូមិទាំង មូល ! តាមពិតតាំងពីព្រះបង្គំចាកចេញពីរាជវាំងមកកាន់លំនៅរបស់ទូលព្រះ

បង្គំ កាលពីយប់ដែលដង្ហែព្រះអង្គយាងនិវត្តន៍ពីគោកធ្លកមកវិញ, ត្រូវជនមិនស្គាល់មុខបីនាក់ ស្ទាក់វាយយ៉ាងដំណំ លុះត្រាតែសន្លប់បាត់ស្មារតី ហើយវាយករូបទូលព្រះបង្គំទៅឃុំឃាំងក្នុងបន្ទប់ពិសេសមួយ ដែលជាកន្លែងសម្ងាត់របស់ពួកវា ! ទូលព្រះបង្គំត្រូវឋិតនៅយ៉ាងសែនវេទនាក្នុងទីឃុំឃាំងអស់មួយយប់ លុះព្រឹកឡើងវានាំគ្នាទៅធ្វើបាបរូបទូលព្រះបង្គំម្តងទៀត ! ដោយពុំអាចតបតនឹងពួកវាបាន, នៅពេលដែលដឹងខ្លួនពីសន្លប់បាត់ស្មារតី, ក៏ស្រាប់តែទូលព្រះបង្គំត្រូវឋិតនៅក្នុងបាវមួយចងមាត់ជិត មិនអាចមើលឃើញអ្វីទាំងអស់ តែគ្រាន់តែដឹងថា វាយកទូលព្រះបង្គំដាក់លើរទេះមួយ ហើយបរចេញមកទិសខាងជើង ។

- ឈប់ (ក្រឡាសូនិយាយកាត់) បើខ្លួនលោកត្រូវជនមិនស្គាល់មុខចាប់ តើនរណាទៅវាយស្ទាក់លោកពិជ័យរចនា កាលដែលទើបនឹងដឹកមាសចេញពីភ្នំមាសនោះ មិនខ្លួនលោកទេឬ ? សឹងមានរបួសយ៉ាងទម្ងន់ជាភស្តុតាងស្រាប់ដែលទ័ពលោកពិជ័យអោយរង្វាន់ដល់ខ្លួនលោក !

ពាក្យរបស់លោកក្រឡាសូ ជាការសមហេតុសមផលមួយផ្នែក ដែលគួរអោយព្រះភូមិន្ទ្រយកជាការពិតបានខ្លះ ក្នុងរឿងដែលថាលោកវិសេសសេនាមានគំនិតក្បត់ប្រទូស្តរាយនឹងព្រះអង្គ ។ ព្រះនរបតីដកព្រះបស្សាសៈយ៉ាងវែង រម្ងាប់ព្រះហឫទ័យក្រេវក្រោធទៅអស់មួយខណៈ ទើបព្រះអង្គមានព្រះសូរសីហនាទ សួរទៅឧកញ៉ាពិជ័យរចនាថា ÷

- មើល៍លោកឧកញ៉ាពិជ័យរចនា តាមការពិតដែលខ្លួនលោកបានប្រាកដយ៉ាងច្បាស់លាស់នឹងភ្នែក តើមានដំណើរដើមទងយ៉ាងណា ? បើរកទៅឃើញថា លោកវិសេសសេនាក្បត់នឹងខ្ញុំមែន ខ្ញុំនឹងត្រូវដាក់ទោសប្រហារជីវិតក្នុងយប់នេះភ្លាមឥតបង្អង់ !

- ព្រះករុណាថ្លៃវិសេស ទូលព្រះបង្គំសូមក្រាបបង្គំទូលថ្វាយដោយត្រង់ ឥតមានបង្អាក់ត្រកូលមូលទ្រមាក់លោកវិសេសសេនាទេ ព្រោះលោកក៏មិនដែលមានចិត្តសៅហ្មងនឹងទូលព្រះបង្គំដែរ មានតែចាប់ដៃចងជាមិត្តទៀតផង ! តាមការយល់ឃើញច្បាស់របស់ទូលព្រះបង្គំ នៅពេលដែលមានមនុស្សចូលទៅប្លន់យកមាស កងទ័ពខាងទូលព្រះបង្គំបានវាយប្រហារយ៉ាងអង់អាចតែក្នុងពេលកំពុងប្រហារនោះគ្មានបានឃើញលោកវិសេសសេនាទេ លុះនៅពេលដែលឃើញលោកក្រឡាសូមកពីចម្ងាយ ពួកឧទ្ទាមនោះក៏រត់ខ្ចាត់ខ្ចាយទៅអស់ ស្រាប់តែឃើញរូបលោកវិសេសសេនា ត្រូវរបួសជាទម្ងន់នៅនឹងកន្លែងតែម្តងក្រាបទូល ! ការយល់ឃើញរបស់ទូលព្រះបង្គំអស់តែប៉ុណ្ណេះ !

- ការយល់ឃើញរបស់លោក ក៏មិនខុសប៉ុន្មានពីលោកក្រឡាសូដែរ !

- ព្រះករុណាថ្លៃវិសេស (ក្រឡាសូបង្គំទូល) ការធ្វើអំពើទុច្ចរិត មិនអាចបំបិទភ្នែកអ្នកស្នេហាជាតិបានទេ គ្មានច្រកណាដែលបង្ហាញអោយដឹងថាលោកវិសេសសេនា ស្មោះត្រង់នឹងរាជបល្លង្កបានឡើយ ព្រោះសឹងមានភស្តុតាងជាគីស្រាប់ ដូចជាក្លាក់សារជាដើម ទូលព្រះបង្គំ និងឧកញ៉ាពិជ័យរចនា បានឆែកឆេរឃើញទាំងពីរនាក់ ! ម្យ៉ាងទៀតត្រង់ការដែលលោកវិសេសសេនា

ដោះសារចំពោះព្រះភ័ក្ត្រព្រះអង្គអម្បាញ់មិញនេះ សឹងចាត់ទុកបានថាជាការមិនពិតឡើយ គួរព្រះអង្គធ្វើទោសដូចម្ដេចតាមព្រះមាត្រាច្បាប់ទៅក្រាបទូល !

ព្រះបាទសាយណ្ហាវ័ន្ទ កាលបើជ្រួតជ្រាបនូវសេចក្ដីក្រាបបង្គំទូលរបស់នាម៉ឺនទាំងពីររូបនេះមក ព្រះអង្គទ្រង់ព្រះតម្រិះក្នុងព្រះបញ្ញាញាណអស់ឋិរៈវេលាដ៏យូរ ទើបព្រះអង្គសម្រេចក្នុងព្រះរាជហឫទ័យថា ត្រូវតែយករូបលោកវិសេសសេនា ទៅធ្វើទោសតាមមាត្រាច្បាប់សម្រាប់រដ្ឋ គឺត្រូវប្រហារជីវិតបង់ ។

គ្រាន់តែឮដូច្នេះ, លោកវិសេសសេនាស្រាលខ្លួនស្ទើកដូចធ្លាក់ពីលើចុងឈើ. លោកអស់ក្ដីរំពឹងនឹងបង្គំទូលថ្វាយព្រះរាជា នូវសេចក្ដីស្មោះត្រង់របស់លោក ដែលលោកមានចិត្តស្វាមីភក្តិចំពោះព្រះអង្គ និងអាណាចក្រសុវណ្ណភូមិទាំងមូល ជាយូរយាណាស់មកហើយ ។

តែជាកុសល ! ពេលជាមួយនោះលោកតាហោរាធិបតីឥសូរភទ្រ. ដែលបានអង្គុយស្ដាប់រឿងនេះដោយហ្មត់ចត់បានក្រោកឡើង បង្គំទូលជំទាស់ជាបន្ទាន់ថា ÷

- បពិត្រព្រះសម្មតិទេព ការនេះបើតាមទូលព្រះបង្គំដែលបានអង្គុយស្ដាប់ដោយហ្មត់ចត់ សូមព្រះអង្គកុំទ្រង់ព្រះពិរោធន៏ខ្លាំងពេក ព្រោះថាកិច្ចការអ្វីៗ ដែលពុំទាន់ឃើញដោយល្អិតល្អន់ ក៏សូមព្រះអង្គ កុំទាន់អាលសម្រេចតាមព្រះរាជហឫទ័យក្រាបទូល !

- ម៉េចបានជាលោកតា ហ៊ានអារកាត់យ៉ាងនេះ ឬមួយក៏លោកតាដឹង

ច្បាស់ពីរឿងនេះដែរ ? បើភស្តុតាងដែលបង្ហាញអោយដឹងថា លោកវិសេស-សេនាក្បត់ សឹងមានគ្រប់គ្រាន់ តើលោកតាមានមធ្យោបាយអ្វី ដែលអាចវិនិច្ឆ័យអោយស្រួលជាងនេះទៅទៀត សូមមានប្រសាសន៍មកមើល ?

- ក្រាបទូលក្រោមលម្អងធូលីព្រះបាទ រឿងនេះមានដំណើរហេតុទៅវែងឆ្ងាយណាស់ ពុំអាចសម្រេចថាខាងណាខុសខាងណាត្រូវឡើយ ដូចជារឿងស្វាដែលសម្លាប់ពពែដូច្នោះ !

- មើល៍លោកតា មានប្រសាសន៍ពីរឿងនេះបន្តិចទៅមើល៍ !

- ព្រះករុណាថ្លៃវិសេស រឿងនេះមានដំណាលថាមានព្រានប្រមាញ់ម្នាក់ចិញ្ចឹមសត្វស្វា និងពពែ ព្រាននេះស្រលាញ់សត្វទាំងពីរស្មើៗ គ្នា ថ្ងៃមួយនៅពេលដែលព្រានចេញទៅបរបាញ់សត្វ ក៏បានយកស្វានិងពពែទៅជាមួយផងលុះដល់ថ្ងៃត្រង់ជាក់ ព្រាននឹកឃ្លានបាយ ក៏ឈប់សម្រាកនៅក្រោមដើមឈើមួយបំរុងស្រោះស្រូបអាហារ តែព្រានមិនទាន់បរិភោគភ្លាមៗ ទេ ក៏យកបាយសំណុំទៅព្យួរនឹងមែកឈើ ដោយរវល់ទៅដងទឹកត្រពាំងនៅក្បែរនោះ សត្វស្វាកំហូច កាលបើឃើញម្ចាស់ទៅបាត់ក៏ឡើងទៅស្រាយ សំណុំបាយស៊ីអស់ដោយឥតក្រែងរអែងដល់ម្ចាស់តិចតួចឡើយ ។ ដើម្បីបំបិទការនេះកុំឱ្យម្ចាស់ដឹងថាខ្លួនមានគំនិតខូច អាសត្វស្វាចង្រៃ ក៏យកសំណល់បាយដែលជាប់នឹងកញ្ចប់ទៅជូតនឹងមាត់ពពែប្រឡាក់ប្រឡូសពាសពេញមាត់ច្រមុះ ។ លុះដល់ម្ចាស់ត្រឡប់ពីដងទឹកវិញ ក្រឡេកទៅបាយអស់ពីសំណុំ ហើយឃើញប្រឡាក់នៅមាត់ពពែដោយស្មានថាពពែស៊ី, ក៏វាយសំពងគ្នាលុះត្រាស្លាប់នៅពេលនោះទៅ !

- យើ ! លោកតា ! (ក្រឡាសូត៌ហាក) លោកតាស្មានខ្ញុំមានគំនិតខូច ដូចអាសត្វស្វាចង្រៃនេះឬ ?

- កុំអាលច្រឡោតខឹងលោក ! ខ្ញុំមិនមែនចោទលោកថាមានគំនិតខូច ដូចសត្វស្វាក្នុងរឿងនេះទេ ខ្ញុំគ្រាន់តែបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង អោយព្រះអង្គទ្រង់ជ្រាបពីរឿងព្រេងនិទាននេះ ដើម្បីយកមកវិនិច្ឆ័យក្នុងរឿងនេះផង ព្រោះរឿងក្បត់ជាតិមួយៗ មិនមែនជារឿងតូចតាចទេ ដូចអាសត្វស្វាវាក្បត់ម្ចាស់ ទៅទម្លាក់ទោសដាក់ពពែដែលជាសត្វស្លូតត្រង់នោះ ទីបំផុតសត្វស្លូតត្រង់ ដែលមានភស្តុតាងគ្រប់គ្រាន់នៅជាប់នឹងមាត់ ក៏ទទួលទោសដល់ជីវិត ! ..... រឿងនេះមានដំណើរកាលតែប៉ុណ្ណេះទេ ក្រាបទូល !

ព្រះនរបតី កាលព្រះអង្គទ្រង់ស្តាប់រឿងព្រេងនិទានរបស់លោកតាហោរាធិបតីឥស្សូរភទ្ររួចមក ព្រះអង្គទ្រង់គង់ប្រថាប់ក្នុងសភាពស្ងប់ស្ងៀមហាក់ដូចជាទ្រង់ព្រះចិន្តាក្នុងពិភពគំនិតចង្អៀតចង្អល់ ។ ទឹកព្រះភ័ក្ត្រក៏ប្រែក្លាយទៅជាក្រៀមស្រពោន បញ្ជាក់អោយដឹងថា ព្រះអង្គទ្រង់ព្រះកង្វល់ក្នុងព្រះរាជហឫទ័យពីរឿងនេះណាស់ ។

មួយសន្ទុះធំក្រោយមក ក្រោយពីព្រះអង្គបន្ទូរព្រះបស្សាសៈអោយស្រាលពីព្រះឱរា ស្តេចទ្រង់ទម្លាក់ខ្សែព្រះនេត្រទៅកណ្តាលអង្គប្រជុំ ហើយបន្លឺព្រះសូរសីហនាទថា ÷

- ឥឡូវបើមានលោកតាហោរាធិបតី ជំទាស់ក្នុងការវិនិច្ឆ័យទោសនេះ យើងត្រូវលើកកិច្ចពិភាក្សាទៅថ្ងៃណា ដែលយើងធ្វើការស៊ើបអង្កេត អោយ

បានច្បាស់ណាស់សិន ខ្លាចក្រែងធ្វើទៅពុំសមហេតុសមផល ដូចព្រានប្រមាញ់សម្លាប់ពពែ ក្នុងរឿងព្រេងនិទានដែលលោកតាអធិប្បាយអម្បាញមិញនេះ ។

ម្តងនេះគ្មាននាម៉ឺនណា ហ៊ានជំទាស់នឹងព្រះករុណាឡើយ គេទាំងអស់គ្នា ក៏រង់ចាំមកស្តាប់ការនៅថ្ងៃស្អែកទៀត ។

លោកវិសេសសេនា ក៏ត្រូវគេយកទៅទុកនៅក្នុងទីឃុំឃាំងដ៏សមគួរ ។

ល្ងាចនេះ នៅពេលត្រលប់មកដល់លំនៅវិញ, ក្រឡាសូបានធ្វើលិខិតមួយច្បាប់ ប្រើអ្នកនាំសារម្នាក់យកទៅអោយអារាមរាជ្យចមជនក្បត់ ដែលសព្វថ្ងៃបានតាំងមូលដ្ឋានសឹកដ៏រឹងប៉ឹងនៅក្នុងខេត្តកោះកែវ ។

ក្នុងលិខិតនេះ ក្រឡាសូបានគូសដៅប្រាប់រាមរាជ្យពីជោគជ័យរបស់ផែនការគេ និងគម្រោងការណ៍ព្រះករុណា ក្នុងការពង្រីក និងពង្រឹងបន្ទាយគោកធ្លកអោយបានមាំមួន ដើម្បីជាគុណប្រយោជន៍រាំងរាការវាយលុករបស់សត្រូវក្នុងស្រុក និងការពារអំពើឈ្លានពាននៃជនបរទេស ។

រាត្រីនោះ, កាលដែលបានទទួលសំបុត្រភ្លាម រាមរាជ្យមានសេចក្តីរីករាយយ៉ាងខ្លាំងចំពោះដំណឹងដែលក្រឡាសូ ប្រមូលនូវស្រមោលអាកប្បកិរិ-យាក្បត់ជាតិ ទម្លាក់ទៅលើលោកវិសេសសេនា ។ ចំពោះរឿងបន្ទាយគោកធ្លកវិញ រាមរាជ្យ បានអនុមិតថា ត្រូវតែវាយបំបែកក្នុងរាត្រីនេះអោយបាន ដើម្បីបង្អន់ថាមភាពរបស់ព្រះករុណាក្នុងករណីការពារជាតិ ដែលស្ថិតក្រោមព្រះមា-តាព្រះអង្គ ។ រាមរាជ្យយល់ម្យ៉ាងទៀតថា បើបន្ទាយគោកធ្លកត្រូវបានគេវាយអោយខ្ទេចទៅជាផេះ សមបំណងនោះ គេជឿជាក់ថា ព្រះបាទសាយណ្ហា-

វ៉ែន ច្បាស់ជាទន់ខ្សោយខាងផ្លូវមូលដ្ឋានសឹកជាប្រាកដ ហើយផែនការរំលំព្រះបល្ល័ង្គរាជ្យ ដែលគេបានគ្រោងទុកនោះនឹងមានប្រសិទ្ធិភាពជាប្រាកដ ។

ដូងព្រះចន្ទ្រានាពេលយាមបី អើតវង់ភ័ក្រ្តមូលក្រឡង់ចេញពីសមុទ្រពពកខ្មៅ ជម្រុះលំអងប្រាក់មកលើស្លឹករុក្ខជាតិដោយប្រឹងសម្លឹងសម្លក់មើលមកកងទ័ពដីរ, ទ័ពសេះ និងទ័ពថ្មើរជើងដ៏ច្រើនរបស់រាមរាជ្យ ដែលកំពុងលើកព្យុហយាត្រាគគ្រឹកគគ្រេង ចេញពីកោះកែវសំដៅបន្ទាយគោកធ្លក ។

ពេលថ្មើរណោះ សព្វសត្វនៅក្នុងដងព្រៃដែលត្រូវសម្ងំក្នុងពេលរាត្រីនិងមនុស្សម្នាដែលស្ថិតនៅតាមដងផ្លូវ ខណៈដែលកំពុងនិទ្រាលក់យ៉ាងសុខសាន្ត ក៏ភ្ញាក់ផ្អើលច្រួលច្របល់ ភិតភ័យរិតក្តមា នឹងស្នូរសន្ធឹកលាន់ឮគ្រូកគ្រាក់ហាក់ស្មើរនឹងភ្លូកភ្លឹកផែនប្រថពី ។

លុះមកដល់គោកធ្លក អ្នកស្រុកប្រុសស្រីក្មេងចាស់ កម្លោះក្រមុំ ដែលធ្លាប់តែបាក់ស្បាតនឹងកម្លាំងដៃយ៉ាងកាចសាហាវរបស់រាមរាជ្យ ជាច្រើនលើកច្រើនគ្រាមកហើយ ក៏នាំកូនជញ្ជូនចៅរត់ចោលគេហស្ថានចូលទៅពួនក្នុងព្រៃបាត់អស់ នៅសល់តែពលសេនាឧកញ៉ារក្សាខ័ណ្ឌជិតនិតភក្តិប៉ុណ្ណោះ ដែលកំពុងត្រៀមខ្លួនយ៉ាងមុតមាំការពារបន្ទាយ និងចាំវាយប្រហារទៅពួកក្បត់ជាតិឥតត្រាប្រណី ។

កងទ័ពរបស់រាមរាជ្យ លើកចូលមកកាន់តែជិតដល់បន្ទាយណាស់ទៅហើយ សន្ធឹកកងទ័ពដែលរត់សម្រុកចូលមក លាន់ឮឡើងដូចមហាគិរីបព្វតាណាមួយរលំដូច្នោះ ......... ។ ស្នូរសព្ទជ័យឃោសន៏ដ៏កងរំពង ក៏បានស្ទុះឡើង

ធ្វើអោយទីគោកធ្លកទាំងមូលកក្រើករំពើកញ្ជាប់ញ័រជាអនេក ។

ខុកញ៉ារក្សាខ័ណ្ឌជំនិតភក្តី ឡើងលើកំពែងក្រឡេកមើលទៅឃើញទ័ពសត្រូវលើកចូលមកយ៉ាងក្រាស់ក្រែលដូច្នេះ ក៏បញ្ជាអោយទាហានបិទទ្វារបន្ទាយគ្រប់ទិសយ៉ាងមាំ ព្រមទាំងចាត់អោយកងកម្លាំងពិសេស នៅត្រៀមចាំការពារទ្វារទាំងនោះកុំអោយសត្រូវរំលាយចូលមកបាន ។

បន្ទាយមានសភាពស្ងប់ស្ងាត់ កងទ័ពរបស់យើងកាន់ក្តាប់អាវុធនៅដៃយ៉ាងណែន សង្កៀតធ្មេញ ផ្តោតចិត្តយ៉ាងប្តូរផ្តាច់ថានឹងតស៊ូចំពោះទ្រុស្តជាតិអោយត្រាតែដល់ដំណក់ឈាមជាចុងក្រោយបំផុត ។

ព្យុហពលមីរដេរដាសដូចហ្វូងស្រមោច សន្ធាប់ចូលមកយ៉ាងគឃ្លើន ។

លោកជំនិតភក្តី កាលបើយល់ថាការវាយតបទៅខ្លាំងល្មមដល់ការគួរហើយ ក៏ចេញបញ្ជាយ៉ាងអង់អាចថា ÷

- បាញ់កនយើង ! បាញ់វាអោយខ្ទេច !

ចប់កន្ទុយប្រយោគ កូនសរប្រៀបបាននឹងគ្រាប់ភ្លៀង បានហើរប្រសាចចេញពីកំពែងបន្ទាយ ទៅដោតចោះទម្លុះទម្លាយសរីរាង្គកាយបច្ចាមិត្រ ឱ្យដួលស្លាប់ដេរដាសលើកម្រាលលោហិតក្រហមច្រាល ។ តែទោះបីជាពួកវាស្លាប់ដូចគេហាលយ៉ាងនេះក៏ដោយ ក៏ពួកវានៅតែបោលសម្រុកចូលមកបន្ទាយឥតរាថយ ។

អស្ចារ្យណាស់ មកដល់បន្ទាយហើយពួកទ្រុស្តជាតិ ខំប្រួតកម្លាំងគ្នាវាយលុកទម្លុះទ្វារចូលទៅយ៉ាងអង់អាច ។ កងទ័ពបន្ទាយដោយមានគ្នាតិច

ពេក ពុំអាចខ្ទប់ទ្វារបានតទៅទៀតឡើយ ។ ម្ល៉ោះហើយទ្វារខាងត្បូង និងខាងលិចបានរបើកឡើង កងទ័ពរាមរាជ្យក៏លុកចូលទៅដូចស្រមោច ។

ឧកញ៉ារក្សាខ័ណ្ឌជំនិតភក្តិ ឃើញដូច្នោះ ក៏លោតចុះពីលើប៉មមកទំលើខ្នងពាជី ចូលមកជួយប្រយុទ្ធកូនទាហានយ៉ាងខ្សៀវក្លា ។ បន្ទាយគោកធ្លកទាំងមូល ក៏ក្លាយទៅជាទីលានសមរភូមិ ផ្ទុកដោយសាកសពត្រៀបត្រាលើសមុទ្រឈាម ។

កងទ័ពរាមរាជ្យ ដែលមានគ្នាច្រើនទ្វេភាគលើអ្នកក្លាហានយើង បានរុញច្រានយើង អោយធ្លាក់ក្នុងបរាជ័យបន្តិចម្តងៗ ក្រោមមុខអាវុធដ៏ក្រខ្វក់របស់ពួកវា ។

ឧកញ៉ារក្សាខ័ណ្ឌយល់ថា កំលាំងសឹកខាងសត្រូវគ្របសង្កត់លើការតស៊ូរបស់កងទាហានស្នេហាជាតិខ្លាំងណាស់ ក៏ស្រែកបញ្ជាអោយកងពលទាំងអស់វាយដកខ្លួនចេញពីបន្ទាយ តែអនិច្ចា ! ....... នៅគ្រប់ច្រកទាំងអស់ បច្ចាមិត្របានវាយធ្លាយខ្ទេចខ្ទីហើយនាំគ្នាមកព័ទ្ធយើងជិតជុំ ។

ពុទ្ធោ ! បន្ទាយទាំងឡាយ ត្រូវសត្រូវដុតបំផ្លាញឆេះសន្ធោសន្ធៅ ហើយស្រែកហ៊ោកញ្ជ្រៀវ ចូលមកកាប់សម្លាប់អ្នកស្នេហាជាតិយ៉ាងសោករន្ធត់

អ្នកឧកញ៉ា នឹកអាណិតកងទាហានរបស់លោកខ្លាំងណាស់ ដែលកំពុងលង់ខ្លួនចូលក្នុងការឡោមព័ទ្ធរបស់សត្រូវ ពុំអាចរើខ្លួនទៅណាបានឡើយ ។ វាបរបក្សឃើញដូច្នោះ ក៏ស្រែកបញ្ជាអោយអ្នកស្នេហាជាតិទម្លាក់អាវុធចុះចាញ់ តែឥតប្រយោជន៍គ្មាននរណាមួយធ្វើតាមបង្គាប់ពួកវាឡើយ ។ ក្តៅចិត្តណាស់

លោកឧកញ៉ាបង្អើរសម្លេងតបទៅវិញថា ÷

- យើងសុខចិត្តតែពីស្លាប់នៅក្នុងបន្ទាយនេះ ! .......... មិនព្រមចុះចាញ់ពួកអាឯង ដែលជាមនុស្សក្បត់ជាដាច់ខាត ! .........

- ឈិប ! ......... អឿក ! .........

រលកវាចានេះ រលត់ផុតភ្លាម លំពែងរបស់អាមេក្បត់រាមរាជ្យបាន ហើរមកដោតជាប់លង្វែកទ្រូង លោកឧកញ៉ារក្សាខ័ណ្ឌជំនិតភក្តី ។ លោហិតក្រហមឆ្អៅស្ទុះស្នៅចេញមកភល១ បែកពពុះស្កុល ។ ជាមួយគ្នារាងកាយរបស់លោកក៏ដួលទៅលើផែនពសុធា ធ្វើអោយកូនទាហានទាំងប៉ុន្មាន ដែលកំពុងប្រយុទ្ធនឹងខ្មាំងតក់ស្លុតរន្ធត់ញាប់ញ័រយ៉ាងខ្លាំង ។

ចោរបហនេយ្យំ ស្រែកជយោ ! ជយោ ! កងរំពងព្រមជាមួយវានាំគ្នាឡោមព័ទ្ធទាហានទាំងអស់ ដោយប្រើផ្លែលំពែង និងដាវ កាប់ចាក់ឥតត្រាប្រណី ។

មេកងម្នាក់ ឃើញមេទ័ពខ្លួនត្រូវនឹងលំពែង ក៏ស្ទុះចូលទៅដកលំពែងចេញ ទើបលើកដាក់លើខ្នងសេះចេញពីទីនោះមួយរំពេច ។

- លោកឪពុក ! លោកឪពុកទ្រាំបន្តិចទៅជិតដល់ផ្ទះយើងហើយលោកឪពុក !

មេកងនេះ និយាយទៅកាន់អ្នកឧកញ៉ារក្សាខ័ណ្ឌជំនិតភក្តី ដោយបង្ហូរជលនេត្រសស្រាក់ ស្រោចស្រប់ហូរហៀរពេញរង្វង់មុខ ។ អ្នកឪបប្រាណបិតាជិះសេះបោះពួយចេញពីសមរភូមិមកកាន់លំនៅយ៉ាងលឿន ។

- ឆន្ទោកូន ! ទុកពុកនៅត្រង់នេះហើយ ! អូយឆន្ទោកូនមាសឪពុក ! ពុកពុំអាចរស់នៅឃើញមុខកូនតទៅទៀតបានទេ ! អូយ !

ឆន្ទោឮឪពុកនិយាយដូច្នោះ ក៏ទាញបង្ហៀរសេះអោយឈប់ ។ មកដល់ដីអ្នកផ្តេកក្បាលអ្នកមានគុណអោយកើយលើភ្លៅអ្នក ។

- ពុក ! ........ ជិតដល់ផ្ទះយើងហើយ ម៉េចក៏ពុកឱ្យកូនដាក់កន្លែងនេះវិញ !

- ទេកូនប្រុសសំលាញ់ពុក ! ពុកច្បាស់ជាត្រូវស្លាប់ក្នុងគ្រាឥឡូវនេះ ហើយ ! ........ អូយ ........ ! កូន ........ ប្រុសពុក បើអត់ពីពុកទៅត្រូវថៃទាំម្តាយនិងកេសររង្សីប្អូនឯងអោយមុតមាំណាំ ! ....... កូនត្រូវតែស្មោះត្រង់នឹង ជាតិសាសនា ព្រះរាជបល្ល័ង្ក ហើយត្រូវបូជាជីវិតបំរើព្រះមហាក្សត្រ ! ..... ពុកគ្មានអ្វីចែកកូនទុកជាកេរ្តិ៍មរតកទេ ! ....... តែកូនត្រូវទៅយកដាវមរតករបស់ជីតាឯងដែលកប់ទុកនៅក្រោមព្រះបាទឆ្វេង នៃព្រះរូបសំណាកដ៏ធំរបស់ព្រះបាទសុរិន្ទ្រាវ៉ន្ន នាកំពូលភ្នំមាសកុំខានអោយសោះ ។ ដាវនេះជាដាវជ័យសិទ្ធិអាចឱ្យកូនធ្វើការបំរើជាតិ រំដោះជាតិឱ្យផុតពីកលិយុគបានដោយជោគជ័យ ។

ដាវនោះមានពីរ មួយសម្រាប់កូនឯង និងមួយទៀតសម្រាប់កេសររង្សីប្អូនរបស់ឯង ។ បានដាវនេះហើយត្រូវកូននាំប្អូន ចូលទៅថ្វាយខ្លួនបំរើជាតិចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូងភ្លាម កុំបង្អង់ឱ្យសោះណាំកូនណាំ ! និយាយដល់ត្រឹមនេះ រលកសម្លេងនៃវរជនយើងក៏ចុះ ថាមពលខ្សោយទៅៗ ជាលំដាប់ ។ នាយឆន្ទោក្រសោបរាងកាយឪពុក បង្ហូរទឹកភ្នែក



តក់ៗ ប្រឹងសម្លឹងមុខអ្នកមានគុណឥតប៉ព្រិច ។

- ពុក ! កូនមិនភ្លេចបណ្ដាំពុកទេ ! កូននឹងថ្វាយខ្លួនចំពោះព្រះមហាក្សត្រ បូជាជីវិតបម្រើជាតិ ឱ្យសមនាទីជាកុលបុត្រដ៏ក្លាហានមួយរូបទុកជាតំណាងពុក !

ពេញចិត្តណាស់, ចំពោះសំដីកូន លោកជំនិតភក្តិខំប្រឹងញញឹម ! ញញឹមទាំងក្តីចុកចាប់ ។

- ពុកសប្បាយនឹងសំដីរបស់កូនណាស់ ! អូយឆន្នោ ! ឆន្នោកូនសំលាញ់ពុក ! ឆន្នោឯណាកេសរវង្សី ឆន្នោអូយ ....... ពុក ..... លា ......ហើយ !

មច្ចុរាជឥតធម៌មេត្តា, ហាក់បានលក់ចិន្តាទៅអោយរាមរាជ្យចមជនក្បត់ជាតិ, បានកញ្ឆក់យកទងព្រលឹងលោកឧកញ៉ារក្សាខ័ណ្ឌជំនិតភក្តិ កោះគោកធ្លាកទៅបរលោកមួយរំពេច ។

ឆន្នោយំបោកខ្លួន ខ្សឹកខ្សួលរមួលប្រាណ ឱបសាកសពឪពុក ដែលបានរលត់ក្ខន្ធចាកលោកនេះទៅ អោយអ្នកនៅកំព្រាលើពិភពអនត្តាប្រកបដោយការបង្ខូរឈាម, ប្រវញ្ច, ឈ្នានីស, ជិះជាន់យ៉ាងគួរខ្ពើមរអើម ។

ពេលនេះនៅឯបន្ទាយឯណោះ ទាហានខេត្តទាំងឡាយត្រូវពួកក្បត់សម្លាប់បានទាំងអស់, គេនៅរាតត្បាតរហូតដល់ព្រលឹមស្រាងៗ ទើបវាំរំពងសម្លេង ជ័យឃោសន៍ឮកក្រើកព្រះធរណី ។

សម្រែកដ៏ខ្លាំងក្លានេះ បានកន្ត្រាក់វិញ្ញាណនាយឆន្នោ អោយងើបពីមរណៈទុក្ខ ។ នរៈដាក់សាកសពបិតាពីភ្លៅ មកលើព្រះធរណីទើបហូតដាវជីកដីកប់សពឪពុក រួចកាប់មែកឈើយកមកគ្របយ៉ាងស្រួល ។ គេថ្វាយបង្គំសាកសពគម្រប់ ៣ដង ទើបលើកហត្ថប្រណម្យនិយាយថា ÷

- លោកឪពុក ! សូមលោកឪពុកនៅកន្លែងនេះសិនចុះ អ្នកម្តាយ និងអូនកេសរវង្សី មិនដឹងជាយ៉ាងដូចម្តេចទេ កូនសូមលាទៅផ្ទះសិនហើយ !

ចប់វាចា មិត្រយើងស្ទុះភ្លែតផែលលើខ្នងសេះ ជិះមកកាន់គេហស្ថានយ៉ាងលឿន ។

អស្ចារ្យណាស់ ! បុត្រខ្មោចលោកជំនិតភក្តីស្លូតរន្ធត់ក្នុងចិត្តឥតបីថ្លែងនុ៎ះ ! អ្នកយាមលំនៅប្រាំនាក់ ដេកស្លាប់ស្តូកស្តឹងគរជើងលើគ្នាក្នុងថ្លុកលោហិតនរៈហូតដាវមកកាន់ ហក់ចុះពីខ្នងអស្សពាហ៍ រត់ឡើងលើគេហស្ថានដោយទ្រូងញ័ររណ្តំ ។

នៅក្នុងល្វែងទទួលភ្ញៀវ ប្រឡាក់សុទ្ធតែឈាម ស្រីម្នាក់ដេកស្តូកស្តឹងដោយមានជាប់កាំបិតស្នៀតមួយនៅត្រង់ពោះ ។ ឆន្នោឃើញសាកសពនេះភ្លាម អ្នកអួលអាក់ចុកណែនក្នុងទ្រូងពន់ប្រមាណ ។ គឺជាសាកសពមាតាអ្នកនរៈធ្លាក់ដាវពីដៃខ្លួនញ័រចំប្រប់ ទើបសម្រុតកាយឱបមាតាទំនួញសោកាយ៉ាងគួរអាណិត ។

- អ្នកម្តាយ ! អ្នកម្តាយ ! ពុទ្ធោ ! ........ អ្នកម្តាយស្លាប់ចោលកូនទៅទៀតហើយ ! ........ ពីថ្ងៃនេះទៅខ្ញុំជាកូនកំព្រាអនាគតហើយ ! ....... អូនកេសរវង្សីអូននៅឯណា ? ឬមួយគេសម្លាប់អូនទៅហើយ ។

កម្លោះលារង្វង់ដៃពីម្តាយរកប្អូនស្រីពេញលំនៅ តែគ្មានឃើញសោះ ។

ពេលនេះ យើងពុំអាចថ្លែងនូវទំហំទុក្ខរបស់ឆន្នោបានឡើយ គេអស់សង្ឃឹមគ្រប់យ៉ាងក្នុងឆាកជីវិតសោកសៅដោតដៅក្នុងទ្រូងរកាំផ្សាដួងចិត្តឥតបីបរិយាយ ។

មួយស្របក់ក្រោយមក ដោយឃើញពួកទាហានរាមរាជ្យ នាំគ្នាចេញ

ពីបន្ទាយ ដើរប្អូនរាតត្បាតលំនៅអ្នកស្រុក គេក៏ប្រញាប់ជិះសេះគេចខ្លួនភៀស ចេញពីក្រញ៉ាំពួកអាតិរច្ឆានទាំងនេះ ។

ព្រះទិនករ ប្រឹងបន្តព្រះរាជដំណើរសន្សឹមៗ ទៅកាន់ទិសបស្ចឹម ។ ក្រោមព្រះសូរ្យសែងដ៏ត្រកាល នាយឆន្ទោបំផាយសេះ បោះពួយកាត់ជ្រោះជ្រលងដងអូរ ព្រៃព្រឹក្សាបុព្វតាគីរីជាទីសមសាន្តឋានស្ងាត់ មកកាន់ភ្នំមាស ដើម្បីរកដាវមរតក តាមបណ្ដាំលោកឧកញ៉ារក្សាខ័ណ្ឌជំនិតភក្ដីជាបិតា ។

សេះបោលលាន់ឮកុប ! កុប ! ហុយដីទ្រលោម នាំដំណើរយុវជនកំព្រាទៅកាន់គោលដៅ ដោយឥតត្អូញត្អែរចំពោះកាតព្វកិច្ចនេះឡើយ ។ នរៈមិនស្គាល់ផ្លូវទៅកាន់ភ្នំមាសទេ ដូច្នេះការធ្វើដំណើររបស់គេ គឺស្ថិតនៅលើការផ្សងព្រេងទាំងស្រុង ។

មិត្តយើងចេញពីកោះគោកធ្លក មកឆ្ងាយណាស់ហើយ គ្រប់ចង្វាក់ដង្ហើមដកចេញចូល ក្រៅពីពាក្យបណ្ដាំរបស់ខ្មោចឪពុក ឆន្ទោនឹកគិតទៅដល់កេសររង្សី ដែលមិនដឹងជាបាត់ខ្លួនរសាត់ទៅកាន់ទីណា ។

ឪពុកស្លាប់ ! .......... ម្ដាយស្លាប់ ! ........ ប្អូនស្រីបណ្ដូលចិត្តបាត់បង់ទៅទៀត ប្រការទាំងនេះ នរៈពុំអាចអត់ទ្រាំទប់ជលនេត្រ មិនហូរហៀរមកលើទីលានវង្ងង់មុខបានឡើយ ។

# ៥
# សម្រេកគោមាស

សូមបែរមកឯរាជធានីវិញ ! ........

ឧកញ៉ាពិជ័យរចនា កាលដែលនាំមាសមកដល់កន្លែងធ្វើការហើយ ក៏ចាប់ផ្តើមចាត់ការរៀបចំ សាងរូបសំណាកគោបាតាមព្រះរាជតម្រាស់ព្រះបាទសាយណ្ហាវ័ន្ន ។

កិច្ចការនេះ ប្រព្រឹត្តទៅប្រកបដោយការពិនិត្យពិច័យហ្មត់ចត់ណាស់ ព្រោះត្បិតក្នុងមួយជីវិតសិល្បករ អ្នកឧកញ៉ាយើងពុំដែលបានធ្វើរូបសំណាកអ្វីយ៉ាងធំអំពីមាស ដូចម្តងនេះឡើយ ។

ថ្ងៃមួយលោកពិជ័យរចនាគិតថា ÷ គួរណាស់តែ បញ្ចុះយ័ន្តគាថា មន្តអាគមមហាសក្តិសិទ្ធិនៅក្នុងសាច់មាស ដើម្បីញ៉ាំងរូបសំណាកនេះ អោយទៅជាអច្ឆរិយវត្ថុជាទីស្ញប់ស្ញែងសម្រាប់នគរ ។

សិល្បករដែងឯក សប្បាយចិត្តក្រៃលែង កាលបើនឹកឃើញដូច្នេះ គេត្រូវតែសម្រេចធ្វើយ៉ាងនេះ ឱ្យសមតាមគោលបំណង ដែលគេគ្រោងទុក ។

រាត្រីមួយ, ពេលដែលកូនជាងទាំងអស់របស់លោក លង់លក់ក្នុងដំណេកដ៏សុខក្សេមក្សាន្ត លោកបានប្រមូលមាសទាំងអស់ ទៅបញ្ចុះយ័ន្តគាថាមន្តអាគមយ៉ាងពូកែសក្តិសិទ្ធិ ។

ទិវានិងរាត្រី ធ្វើដំណើរស្រូតទៅមុខជាលំដាប់ មួយខែកន្លងមក គោបាមាសមួយយ៉ាងធំ បានប្រាកដរូបរាងឡើងយ៉ាងសង្ហាក្រោមស្នាដៃរបស់លោកពិជ័យរចនា និងសហការីរួមផង ។ លោកសប្បាយរីករាយណាស់ក្រោយដែលធ្វើហើយស្រេចដោយសុវត្ថិភាព បាននាំគោបានេះទៅថ្វាយចំពោះព្រះភ័ក្ត្រព្រះបាទសាយណ្ណាវ័ន្ន នៅឯព្រះរាជដំណាក់របស់ព្រះអង្គ ។

ព្រះចមពល កាលទ្រង់ទតយល់រូបសំណាកគោបានេះភ្លាម ទ្រង់សព្វព្រះរាជហឫទ័យជាអតិបរមា ។ ទ្រង់ត្រាស់សរសើរលោកពិជ័យរចនាយ៉ាងខ្លាំង ហើយទ្រង់បញ្ជាក់ ប្រាប់ទៅនាម៉ឺនសព្វមុខមន្ត្រី. លោកតាហោរាធិបតី ដែលបានមកគាល់ព្រះអង្គនៅពេលនេះដែរថា ÷

- យើងពេញចិត្ត នឹងរូបសំណាកនេះជាអភិយេ្យាភាព ! ដូច្នេះមួយអាទិត្យទៀត យើងត្រូវរៀបចំ ដង្ហែគោបាមាសនេះ ទៅតម្កល់ទុកនៅក្រោមម្លប់ដើមពោធិ៍ ត្រង់មាត់ច្រកភ្នំមាសដោយធ្វើពិធីអភិសេកជាមហោឡារិកផង !

- ព្រះករុណាថ្លៃវិសេស ទូលព្រះបង្គំក៏ពេញចិត្តណាស់ដែរ ហើយយល់ស្របតាមព្រះរាជហឫទ័យរបស់ព្រះអង្គទាំងអស់ ។

កុំសូម្បីតែលោកតាហោរាធបតី ឯនាម៉ឺនសព្វមុខមន្ត្រីទាំងអស់ ក៏ឥតហ៊ានទូលជំទាស់ថាដូចម្តេចឡើយ ព្រោះតាំងពីកើតមក មិនដែលឃើញរូបសំណាកអ្វីល្អដូចរូបគោបានេះទេ ។

មួយអាទិត្យកន្លងមក ........ ការរៀបចំអភិសេកគោបាមាស. ទៅតាមតម្រាយព្រហ្មញ្ញសាសនា. បានចាប់បើកឆាកឡើងយ៉ាងមហោឡារិក

ក្រោម ព្រះរាជធិបតីភាពនៃព្រះបាទសាយណ្ណាវ័ន្ន ។

គ្រានោះ ព្រះប្រិយមហាក្សត្រដោយមានសេនាសព្វមុខមន្ត្រី និងព្រះរាជវង្សវ័ក្សហែហាំមជាព្រះរាជបរិវារ បានដង្ហែព្រះគោបាមាសយកមកតម្កល់នៅក្រោមម្លប់ពោធិ៍ព្រឹក្ស ដែលជាកន្លែងប្រារព្ធ ពិធីអភិសេកនេះ ។

អស្ចារ្យណាស់ ក្រោយពេលដែលអ្នកឧកញ៉ាហោរាធិបតីឥសូរភទ្រ, ព្រាហ្មណ៍, បាគូ បរោហិត, អាចារ្យរាជគ្រូទាំងអស់បានចាប់ផ្តើមធ្វើការបួងសួងតាមលំដាប់លំដោយ នៃប្រពៃណីផ្នែកព្រហ្មញ្ញសាសនា និម្មិតហេតុមួយ, ដែលគ្មាននរណាម្នាក់នឹកស្មានដឹងបានក្រៅពីលោកឧកញ៉ាពិជ័យរចនា, ក៏កើតឡើងធ្វើអោយព្រះករុណា នាម៉ឺនសព្វមុខមន្ត្រី និងប្រជាពលរដ្ឋទាំងអស់ កោតស្ញប់ស្ញែងព្រឺព្រួច វិតក្កមា, បើកភ្នែកធំៗ ចាំប្រុងមើលឧបទ្ទវហេតុនោះ ........

គោបាមាស ដែលយើងដឹងច្បាស់ថាជារូបសំណាកឥតវិញ្ញាណ ស្រាប់តែចេះធ្វើកាយវិការ បើកភ្នែកចុះឡើង បក់កន្ទុយហាក់ដូចជាមានជីវិតពិតៗ ។ មិនតែប៉ុណ្ណោះគោបាមាសនេះ បានបើកប្រអប់មាត់ស្រែករោទ៍លាន់ឮខ្ទរខ្ទា ជាតម្រូប់បីដង រួចហើយបង្វែរខ្លួន បែរងើយមើលទៅព្រះរូបព្រះបាទសុនិន្ទ្រាវ័ន្នជាព្រះអយ្យកោព្រះបាទសាយណ្ណាវ័ន្ន ដែលគេបានសាងព្រះរូបព្រះអង្គ គង់ប្រដាប់បែរព្រះភ័ក្ត្រឆ្ពោះទៅទិសបូព៌ ។

ប្រជារាស្ត្រទាំងអស់ ដែលនាំគ្នាឈរមីរដេរដាស ណែនណាន់តាន់តាប់ជុំវិញកន្លែងប្រារព្ធពិធី បាននាំគ្នាបន្ទន់កាយក្រាបថ្វាយបង្គំរូបសំណាកនោះមួយរំពេច ។

ព្រះបាទសាយណ្ហាវ័ន្ន ទ្រង់យាងចុះពីព្រះសុវណ្ណកោច្ឆៈយាងចូលទៅជិតព្រះរូបសំណាក ទ្រង់លុតព្រះជង្គង់លើកអញ្ជលីករប្រណម្យ ដោយបន្លឺព្រះសូរសីហនាទថា ÷

- ព្រះគោដ៏មានរិទ្ធិ សូមអ្នកផ្សព្វផ្សាយតេជៈបារមី ជួយគាំពារសន្តិភាព និងសំបូរណភាពនៃដែនដីសុវណ្ណភូមិផង ! ....... ភ្នំមាសជាដែនតំបន់ស្ថានស្ថិតដ៏ត្រកាលរបស់អ្នកហើយ ចូរអ្នកថែរក្សាដោយសិទ្ធិអំណាចផ្ទាល់ចុះ ! .....

ព្រះសូរសៀងបន្លឺដល់ត្រឹមនេះ គោបាមាស ក៏ប៉ព្រិចភ្នែក បង្ហូរអស្សុជលនេត្រធ្លាក់តក់ៗ មក ធ្វើអោយយើងទាំងអស់គ្នាមានការងឿងឆ្ងល់យ៉ាងខ្លាំង ។ ព្រះករុណាទ្រង់ពុំអាចសម្រេចព្រះទ័យ កាត់យល់ចំពោះនិម្មិតហេតុនេះដូចម្តេចឡើយ ។ ទ្រង់មានព្រះវរភ័ក្ត្រស្រពាប់ស្រពោន ដោយកំសួលទុក្ខមករាតត្បាតព្រះអារម្មណ៍ព្រះអង្គ ។

ព្រះនរបតី ទ្រង់បែរមើលមុខលោកតាហោរាធិបតី ហៀបនឹងត្រាស់សួរទៅគាត់ ស្រាប់តែពន្លឺឆព្វណ្ណរង្សីដ៏បវរ បានជះឡើងភ្លឺរន្ទាលពីព្រះរូបសំណាក ចាំងឆ្ពុះទៅយ៉ាងឆ្ងាយ អស់រយៈពេលមួយស្របក់ ទើបរលត់បន្តិចម្តងទៅវិញ ។

ព្រះប្រជាភិបាល ទ្រង់ត្រាស់សួរភ្លាមទៅលោកឧកញ៉ាហោរាធិបតីផសួរភទ្រ ÷

- លោកតា ! ...... និម្មិតហេតុនេះ បានន័យដូចម្តេច ក៏អស្ចារ្យម្ល៉េះ ?

- ក្រាបទូល ! កលិយុគពិតជាកើតមានឡើងក្នុងព្រះនគរជាប្រាកដ

ក្រាបទូល ! តែគង់នឹងវិនាសទៅវិញជាមិនខាន ដោយព្រះរាជពោធិសម្ភារបារមីរបស់ព្រះអង្គ ! .....

គ្រាន់តែឮដូច្នោះ ព្រះភូមិន្ទ្រទ្រង់ព្រួយក្នុងព្រះរាជហឫទ័យអស់មួយខណៈ ដោយទ្រង់មិនចង់យល់ឃើញសោះនូវភ្លើងសង្គ្រាម តែព្រះអង្គជាវង្សក្សត្រសឹក ទ្រង់ក៏មិនព្រឺខ្លាចបន្តិចឡើយ ហើយទ្រង់តាំងព្រះទ័យអោយស្ងប់ស្ងាត់ទៅវិញ ។

ព្រះនភមណីរះខ្ពស់ណាស់ទៅហើយ រាជពិធីអភិសេកព្រះគោបាមាសដែលប្រតិស្ឋានតម្កល់ជាប់នៅជើងភ្នំមាសបានចប់ជាស្ថាពរ ។ ព្រះរាជបរិពារនិងព្រះរាជង្គរ័ក្សហែហាមអមព្រះរាជដំណើរនិវត្តិ មកព្រះបរមរាជវាំងវិញ ។ ចំណែកប្រជាពលរដ្ឋទាំងអស់ ក្នុងពេលដែលត្រលប់មកនិវេសនដ្ឋានវិញ បាននាំយកនូវសេចក្តីកោតស្ញប់ស្ញែង ចំពោះនិម្មិតហេតុដ៏អស្ចារ្យដក់ជាប់ក្នុងអារម្មណ៍គ្មានពេលរលប់បាត់ ។

# ៦

# រដ្ឋប្រហារ

ពេញមួយថ្ងៃនេះ ព្រះបាទសាយណ្ណាវ័ន្តពុំបានធូរស្បើយពីព្រះរាជកង្វល់សោះ ដោយទ្រង់ចងចាំនូវសេចក្ដីក្រាបបង្គំទូល របស់លោកតាហោរាធិបតីឥស្សរភទ្រដែលថា ព្រះនគរនឹងកើតមានកលិយុគជាដាច់ខាត ។ សេចក្ដីនេះបានកើតជាចំណោទមួយដ៏ធំ ចងព្រះចិន្ដាព្រះអង្គឱ្យកើតព្រះវិតក្កចំពោះវាសនានគរយ៉ាងខ្លាំង ។

.......................................................................................

ព្រះអាទិត្យចូលអស្ដង្គត រលត់រស្មីបាត់ទៅយូរក្រៃលណាស់ហើយ រាត្រីកាលក្រោមការដឹកនាំនៃដួងអង្គព្រះចន្ទ្រាក៏បានលាតសន្ធឹង បាំងពិដានមេឃនៃលោកទាំងមូល ។ ព្រះពាយបក់មកស្រាល១ បញ្ជូនបុប្ផជាតិនានាក្នុងឧទ្យាន បង្ហើរគន្ធរសក្រអូបឈ្ងុយឈ្ងប់ ចូលទៅក្នុងព្រះរាជដំណាក់បាក់ដូចចង់ប្រលោមព្រះទ័យព្រះនរបតី អោយបានធូរស្បើយពីព្រះកង្វល់ ។ តែគ្មានប្រយោជន៏សោះ, ព្រះភូមិន្ទ្រ រិតតែវិលវល់ព្រះអារម្មណ៏ខ្លាំងឡើង១ ជាលំដាប់ ។

មើលហ្ន៎ ! ព្រះអង្គកំពុងគង់សញ្ជប់សញ្ជឹងស្ញឹងស្ញាធីនៅមុខព្រះតំណាក់ ទតទៅឆ្ងាយដោយឥតគោលដៅជាក់លាក់, បន្ទាយខ្សែអារម្មណ៏ទៅកាន់ការដោះស្រាយមួយ ដែលមានបញ្ហាចោទឡើងស្មុគ្រស្មាញចាក់កណ្ដាញ់រកមុខ

មិនឃើញ ។

រាត្រីដ៏យោងយន់ ចេះតែសន្សឹមហោះរំលងទៅមុខឥតអាក់ តាមចង្វាក់កង់ប្រវត្តិសាស្ត្រ ធាតុត្រជាក់, ដែលកើតមកពីសសៃទឹកសន្សើម, ក៏ចាប់ផ្តើមផ្សព្វផ្សាយឥទ្ធិពលរបស់ខ្លួនបន្តិចម្តងៗ ទៅដែរ ។

យប់ជ្រៅណាស់ទៅហើយ សភាពស្ងាត់ជ្រងំក៏ទន្ទ្រានមកគ្របដណ្តប់រាជធានីទាំងមូល ។ នៅគ្រប់ក្លោងទ្វារមហាប្រាសាទ, ក្លោងទ្វារព្រះបរមរាជវាំង, អ្នកយាមល្បាតដើរចុះដើរឡើង ក្នុងអន្លង់អន្ធកាលព្ធស្ងួរស្រីបៗ ឥតដាច់រយៈ ហាក់ប្រុងប្រៀបជានិច្ចក្នុងករណីយកិច្ចរបស់ខ្លួន ដែលត្រូវបំពេញក្នុងការបម្រើជាតិ ។

ទឹកសន្សើមទម្លាក់ប្រាណរ៉ុយៗ តាមរលកធាតុអាកាសមកលើធម្មជាតិ អោយមានជីវិតស្រស់បំព្រងឡើងវិញ ។

បក្សាបក្សីរាត្រីចរ, ហិចហើរច្រវាត់កាត់លំហអាកាសវេហាសី, ស្វែងរកភត្តាហារ ហាក់គ្មានគិតព្រួយបារម្ភ ក្នុងគ្រោះភ័យនៃដំណើរជីវិតបន្តិចសោះ

ខ្លែងស្រាកស្រែកខ្វាក លាន់ឮពេញផ្ទៃអាកាស ធ្វើអោយព្រះករុណាភ្ញាក់ព្រះវិញ្ញាណចេញពីភវង្គ ។ ព្រះអង្គបង្ហួតខ្សែអស្សាសៈបស្សាសៈយ៉ាងវែងបន្ទូរគំនរទុក្ខអោយរសាត់ចេញពីព្រះហឫទ័យចង្អៀតចង្អល់ ។

- ព្រិប ! ព្រិប ! ព្រិប !

នេះជាសំណួរជើងមនុស្សដើរ ព្រះប្រជាភិបាលបង្វិលកែវព្រះនេត្រយ៉ាងរហ័ស ទតត្រង់ទៅក្លោងទ្វារ ដែលជាកន្លែងភេរវសព្ទអម្បាញមិញនេះ

បានឧប្បត្តិកឡើងពីនាទីមុន ។

សេនាម្នាក់ ដើរចូលមកបង្គំគាល់ដោយអាការៈត្រហេបត្រហប ។

- មានការអ្វី នាយឆ្មាំ ? អីក៏ដូចជាស្លន់ម្ល៉េះ ?

ព្រះរាជាត្រាស់សួរភ្លាមឥតបង្អង់ ។ នាយឆ្មាំដែលយាមក្លោងទ្វារប្រញាប់ក្រាបបង្គំទូលថ្វាយ តាមដំណើរការដែលខ្លួនដឹង ។

- ក្រាបទូល ! តាមអ្នកយាមល្បាតដែលប្រចាំការនៅជាយរាជធានីផ្នែកទិសឧត្តរអោយការណ៍មកថា : កងទ័ពរបស់រាមរាជ្យលើកគ្នាសម្រុកលុកចូលមកក្នុងទីក្រុង បម្រុងវាយដណ្តើមយកព្រះរាជបល្ល័ង្កឥឡូវនេះហើយក្រាបទូល !

- យី ! ចុះលោកមេទ័ពតេជោក្លាហាន លោកពិជ័យរចនា, លោកហោរាធិបតី, លោកក្រឡាស្វ, សេនាមន្ត្រី និងកងទ័ពទាំងអស់ដឹងរឿងនេះទេ?

- ក្រាបទូល ! អស់លោកមេទ័ព, សេនាមន្ត្រី និងកងទ័ពទាំងអស់ប្រហែលជាពុំទាន់ដឹងទេមើលទៅក្រាបទូល !

- បើដូច្នោះឯងចាត់ការអោយគេទៅប្រាប់លោកមេទ័ពតេជោក្លាហាន និងលោកហោរាធិបតីអោយដឹងភ្លាមទៅទើបបាន !

- ទទួលតាមព្រះរាជឱង្ការតម្កល់លើត្បូង !

សេនាមាត្យនេះទទួលព្រះរាជបញ្ជាដូច្នេះហើយ ក៏រត់ចេញពីព្រះមហាដំណាក់មកវិញ ដើម្បីចាត់ការអោយបានរហ័សទៅតាមព្រះរាជតម្រាស់ ។

ក្រោយពីឮដំណឹងនេះ ព្រះចមពលទ្រង់ញាប់ញ័ររន្ធត់ ក្នុងព្រះរាជ

ហឫទ័យយ៉ាងខ្លាំង ដោយមិនចាប់ភ្លឹកសោះថា មានសត្រូវមកដណ្តើមរាជបល្ល័ង្កពីព្រះអង្គ ។

លុះទ្រង់ព្រះវាចា ក្នុងព្រះរាជយោបល់អស់មួយរយៈមក ស្តេចទ្រង់ចេញពីទីនោះភ្លាម ដោយព្រះហឫទ័យដ៏មោះមុតចង់រំលាយអាក្បត់អោយផុតពីដែនដី ។ តែរំពេចនោះទ្រង់ទតឃើញក្រឡាស្ងបញ្ចេញខ្លួនពីទីកំបាំងមក ពាក់ជាប់នូវទឹកមុខយ៉ាងកាចសាហាវ ។ ព្រះរាជា ទ្រង់មិនបាច់ព្រះសង្កាពីអាកប្ប-កិរិយាដ៏ប្លែករបស់មន្ត្រីរូបនេះឡើយ ព្រះអង្គហូតព្រះទម្រង់អសិ (១) ចេញពីស្រោម ក្តាប់យ៉ាងណែន ចង្អុលសួរទៅថា ÷

- ក្រឡាស្ង ! មានបំណងដូចម្តេចខ្លះចំពោះយើងនៅពេលនេះ ! ...... លោកចេញពីកន្លែងណា ? ប្រាប់មក ! .........

ក្នុងកាលៈទេសៈដែលមិនបានប្រុងប្រៀប លោកក្រឡាស្ងស្លន់ពន់ប្រមាណ. វាត្រលប់ជាឈរទ្រឹង ដោយចាញ់បារមីព្រះអង្គក៏មិនដឹង ។

ដោយអាការៈអេះអុញរបស់វា ធ្វើអោយព្រះរាជាយល់បានភ្លាមក្នុងព្រះយោបល់ ទើបទ្រង់លើកដាវឡើងកាប់វាផាំង ! ....... វាគេចផុត ដោយយកដាវរបស់វា រងនឹងមុខអាវុធរបស់ព្រះអង្គវិញ ។

ពេលជាបន្ទាន់ ទាហានទាំងប៉ុន្មានដែលជាព្រះរាជអង្គរ័ក្ស ស្ទុះចូលមកពីគ្រប់ទិសប្រដាប់ដោយអាវុធគ្រប់ដៃ ជួយការពារព្រះវរកាយព្រះប្រជាភិ-បាលអោយផុតពីគ្រោះថ្នាក់ ។

---

(១) ដាវ ។

ក្រឡាសូ ឃើញដូច្នេះភ្លាម ក៏គេចខ្លួនដាក់មេផាយវាយកែងជូនលោកបាតជើងសព្រាតបាត់មួយរំពេច ។ ព្រះនរបតីបញ្ជាភ្លាមទៅកាន់ទាហានដែលទើបមកដល់ ។

- ដេញចាប់ អាចោរថ្មើមពាសមេឃនេះអោយបានទាហាន !

យើងទាំងអស់ នាំគ្នារត់ប្រដេញតាមក្រឡាសូ តែអនិច្ចាកងទ័ពពួកក្បត់មិនដឹងពេចចេញពីតំបន់ណា រត់ចូលមកតាមក្លោងទ្វារ ។ ពួកអង្គរ័ក្ស ក៏ជួបប្រយុទ្ធជាមួយពួកនេះយ៉ាងខ្លាំងក្លាបំផុត ។

ធន់ទ្រាំម្ដេចបាន បើពួកអាក្បត់ច្រើនមហិមា បណ្ដាលអោយកងទ័ពព្រះរាជអង្គរ័ក្សទាំងប៉ុន្មានធ្វើមរណកាល. នៅក្នុងក្លោងទ្វារទាំងអស់គ្នា. ដោយពាំនាំទៅជាមួយនូវសេចក្ដីគំនុំគំគួនគ្មានពេលរលប់ៗ បាត់ ជាងរយជាតិទៅមុខទៀត ។

- កនយើង ឡោមចាប់ស្ដេចអោយបាន !

ក្រឡាសូ បញ្ជាទៅទាហានក្បត់របស់វា តែព្រះអង្គប្រញាប់ឆ្លើយតបទៅវិញ ÷

- ក្រឡាសូ ទីបំផុតឯងទេដែលជាមេក្បត់បង្កប់ខ្លួននៅក្នុងបល្ល័ង្ករាជ្យ! អាឯងនឹងត្រូវស្លាប់ ដោយអំពើទ្រុស្ដជាតិដ៏ក្រខ្វក់ ! .......

ព្រះទសពល ពិតមែនតែទ្រង់ឋិតនៅតែមួយព្រះអង្គគត់ក្នុងចំណោមពួកក្បត់ ក៏ទ្រង់ពុំតក់ស្លុតអ្វីឡើយ ។ ទ្រង់យាងឡើងគង់លើព្រះទីនាំងអស្សតរគ្រវីព្រះខ័នប្រហារសត្រូវ ដែលកំពុងចោមរោមជុំជិតព្រះវរកាយ ។

- ឈិប ! អូយ !

បរបក្ស ត្រូវនឹងមុខព្រះខ័ន ស្លាប់ដេរដាសគរជើងលើគ្នា. ស្រែកថ្ងូរទាំងក្តីឈឺចាប់ លើកម្រាលលោហិតក្រហមទែង ។

- ចូល ! កនយើងចូលឡោមព័ទ្ធចាប់អោយបាន ! .......

ក្រឡាសូ ស្រែកបណ្តើរ ជិះសេះជ្រែកហ្វូងពាហនៈចូលមករកព្រះរាជាតាមគោលបំណង ។

- អ្ហ៎ា ! យើងជួបគ្នាហើយតើ ក្រឡាសូ ! ពេលនេះយើងត្រូវកាត់ក្បាលអាឯងអោយបាន ដើម្បីលាងមុខរបួសជំងឺចិត្តរបស់យើង និងស្មាមបាបដែលឯងដើរចោទប្រកាន់មួលបង្កាច់គេ ។

- ហាស់ ! ហាស់ ! ព្រះអង្គទេដែលត្រូវសុគតក្នុងពេលនេះ សូមព្រះអង្គទ្រង់ជ្រាបថា អត់ពីព្រះអង្គទៅ សុវណ្ណភូមិទាំងមូលនឹងធ្លាក់មកនៅក្រោមការត្រួតត្រារបស់ទូលបង្គំទាំងស្រុង !

ផុតចុងប្រយោគ ក្រឡាសូលើកដាវឡើង ក៏កាប់ផាំងទៅលើព្រះយុវ-ក្សត្រ តែទ្រង់រងជាប់ ទើបតបទៅវិញយ៉ាងរហ័ស ។

ការវាយប្រយុទ្ធ យ៉ាងស្អុតរន្ធត់ក៏ប្រព្រឹត្តទៅទាំងក្តីឈឺចាប់គ្រប់ៗ គ្នាក្នុងអន្លង់រាត្រីល្វឹងល្វើយ ដែលឮសូរតែរន្ទះផ្លែដាវលាន់រំពង ។

ពេលជាមួយ នៅតំបន់ទាំងអស់ក្នុងព្រះបរមវាំង រាមរាជ្យបានវាយលុកសម្រុកចូលគ្រប់កន្លែង ។ កងទ័ពជាតិត្រូវពួកក្បត់ប្រហារស្លាប់ដេរដាសចំណែកបន្ទាយធំៗ ក៏ត្រូវពួកវាដុតបំផ្លាញឥតស្តាយស្រណោះ ។ ទាហានណា

ដែលនៅក្នុងបន្ទាយរកផ្លូវចេញមិនទាន់ ក៏បានជាចំណីព្រះអគ្គីយ៉ាងសែនវេទនា

លោកតេជោក្លាហាន. លោកពិជ័យរថនា និងលោកតាហោរាធិបតី កាលដែលដឹងថារាមរាជ្យលើកទ័ពចូលវាយដណ្ដើមយកព្រះរាជវាំង ក៏ជិះសេះហក់ចូលមកសមរភូមិយ៉ាងក្លាហាន ។ តែជាអកុសល ពេលដែលគាត់ទាំងបីមកដល់រាជវាំងបានត្រូវសត្រូវកាន់កាប់ ប្រកាសជោគជ័យដោយបញ្ចេញសំ-ណួរជ័យឃោសន៍យ៉ាងខ្ទរខ្ទាទៅហើយ ។

ភ័យណាស់ ! វរជនយើងទាំងបី នាំគ្នាជិះសេះតាមផ្លូវសម្ងាត់ ចូលមករកព្រះករុណាឯព្រះដំណាក់ ។

សូមណែនាំមិត្តអ្នកអាន ទៅមើលព្រះករុណាជាអម្ចាស់ជីវិតនៃដែនសុវណ្ណភូមិម្ដងវិញ ។

ព្រះបាទសាយណ្ហវ័ន្ត ព្រះអង្គកំពុងឋិតនៅកណ្ដាលនៃការឡោមព័ទ្ធរបស់ខ្មាំង ដែលមានគ្នាដ៏ច្រើនសន្ធឹកសន្ធាប់នេះ ព្រះអង្គពុំអាចប្រើភ្លេងអាវុធរំដោះព្រះវរកាយចេញផុតពីក្រញាំពួកវាឡើយ ។

ខំណាស់ ! ញើសបែកចេញមកជោគជាំព្រះកាយ ព្រះចមពលអស់ពីវាយសម្រុកខ្មាំង ក៏ត្រឹមតែលើកព្រះខ័ន រងនឹងមុខអាវុធរបស់ខ្មាំងដែលចោមរោមជុំវិញព្រះអង្គ ហាក់ដូចជាកំពុងស្រេកឃ្លានព្រះជន្មព្រះអង្គជាចំណីរបស់វា

នាទីនេះ ព្រះករុណាជាអម្ចាស់ ទ្រង់ឈ្វេងយល់ថា ព្រះអង្គនឹងរំលាងខន្ធក្នុងសមរភូមិជាមិនខាន ព្រោះទ្រង់ទុព្វលភាពក្នុងព្រះកាយណាស់ទៅហើយ

ក្រឡាស្ទូ ឃើញក្បាច់អាវុធរបស់ព្រះអង្គកាន់តែចុះថយឥទ្ធិពលជា

លំដាប់ ក៏ញញឹមត្រេកអរ បោះសំដីស៊កសៀតថា ÷

- ម៉េចព្រះអង្គ លុមចុះញ៉មក្រោមអំណាចទូលបង្គំទៅ ! .......

សំដីផ្លែផ្ការរបស់វា ធ្វើឱ្យព្រះទ្រង់រិទ្ធឆួលក្នុងព្រះទ័យជាអនេកស្តេចទ្រង់សង្កៀតព្រះទន្តដោយអាការៈខ្ញាញ់ ស្ទើរហក់ទៅទម្លាយជីវិតវាឱ្យផុតពូជទ្រាំមិនបានទ្រង់បង្ហើបព្រះឱស្ឋបន្ទឹព្រះវាចាតបទៅវា តែទ្រង់ក៏អាក់ទៅវិញព្រោះពេលជាមួយនោះ លេចនារីមួយរូបជិះសេះជ្រែកហ្វូងទាហានរបស់ក្រឡាសូយ៉ាងក្លាហានអង់អាច សំដៅមកព្រះអង្គ ។

កាលបើតរុណីគ្រវីដាវឡើង ដាវនាងមានពន្លឺរស្មីចិញ្ចាច ដូចផ្លេកបន្ទោរ ញ៉ាំងព្រះរាជាឱ្យទ្រង់ចាប់អារម្មណ៍ពន់ប្រមាណ ។ ចំណែកឯក្រឡាសូនិងកងទ័ពខ្លួន ក៏ដូច្នោះដែរ កែវភ្នែកទាំងអស់ត្របាញ់ទៅលើរូបនាងទាំងស្រុង

ស្រស់ស្រី ពុះពារមហាឧបសគ្គ កាប់សម្លាប់ខ្មាំងស្លាប់ជាច្រើននាក់វាតមុខផ្លូវរបស់នាង លុះត្រាចូលមកដល់ព្រះនរបតីដោយសុវត្ថិភាព ។

នារី មិនទាន់ក្រាបទូលព្រះនរបីថាដូចម្តេចឡើយ គ្រាន់តែសម្រួមទឹកមុខដ៏ស្រស់បំព្រង អោយទៅជាស្រពោនអស់មួយខណៈ ហាក់ដូចជាសុំសេចក្តីអនុញ្ញាតពីព្រះអង្គ ទើបនាងបែរមុខទៅរកក្រឡាសូវិញ ។

- នែ អាចោរក្បត់ជាតិអប្បលក្ខណ៍ ! ឯងស្លាប់ទៅ រស់នៅនាំតែទម្ងន់ផែនដី !

ចប់កន្ទុយពាក្យ មាណវីក៏វាត់ដាវឡើងកាប់ទៅលើក្រឡាសូយ៉ាងអង់អាច ។ ជនអសិរិទ្ធមិនបានប្រុងប្រៀបជាមុន ដោយរវល់ភាំងនឹងលំអរបស់នាង

ក៏ត្រូវរងនឹងផ្លែដាវចំកណ្តៀតទឹក បណ្តាលអោយធ្លាក់ពីលើខ្នងសេះ ទទួលគ្រោះថ្នាក់យ៉ាងអាម៉ាស់ចំពោះមុខក្រុមបក្សរបស់វា ។

ជោគជ័យសម្រេចដូចគោលបំណងហើយ យុវតីក៏បែរមកក្រាបបង្គំព្រះករុណា ទៀបព្រះបាទាព្រះអង្គ ។

- ព្រះករុណាជាអម្ចាស់ សូមទ្រង់យាងឡើងគង់លើខ្នងសេះខ្ញុំម្ចាស់មកក្រាបទូល ! ខ្ញុំម្ចាស់នឹងយាងព្រះអង្គអោយផុតពីមហន្តរាយ ។

ព្រះរាជាដូចជាពុំទាន់ជឿស៊ប់ នឹងសំដីរបស់នារីចម្លែកនេះ ហើយដោយភាំងនឹងលំអតតពីររបស់នារីផង ទ្រង់ក៏ត្រឡប់ជាគង់ស្ងៀមទៅវិញ ។

- ឆាប់ឡើងក្រាបទូល (នាងទូលបន្ថែម) សត្រូវវាយធ្លាយព្រះបរម-រាជវាំង ប្រកាសជ័យជំនះលើកងទ័ពជាតិទៅហើយ ! ....... យាងមកក្រាបទូល ឱកាសល្អសល់តិចណាស់ ។

មិនទាន់តែសម្រេចព្រះហឬទ័យថាដូចម្តេចផង ស្រាប់តែឃើញកងទ័ពដំរីជាច្រើន ចូលមកក្នុងផ្ទៃព្រះបរមរាជវាំង ។ ក្រុមទាហានក្បត់ ក្រឡេកឃើញបុរសម្នាក់តាក់តែងកាយដ៏បវរ. ឈរនៅលើខ្នងដំរី. លើកដាវឡើងលើក៏នាំគ្នាលុតជង្គង់ទៀបនឹងដី ។

ស្ថានការណ៍ដ៏ចង្អៀតកៀកចូលមកកាន់តែជិតណាស់ ហើយតរុណីចម្លែកនេះ តឿនព្រះអង្គដោយសម្លេងញ័រៗ ទៀតថា ÷

- យាងមកព្រះអង្គ ! រាមរាជ្យចូលមកដល់ហើយក្រាបទូល !

ព្រះរាជា ទតទៅឃើញចមជនក្បត់ដូចនាងមែន ក៏ដាច់ព្រះទ័យយាង

ឡើងគង់លើខ្នងសេះពីក្រោយនាង ។ ស្រស់ស្រីត្រេកអរណាស់ នាងញញឹមតប ទៅព្រះអង្គទើបទូលថា ÷

- ព្រះអង្គគង់អោយជាប់ ! ទុកព្រះទ័យលើខ្ញុំម្ចាស់ចុះ សត្រូវមិនអាច ដណ្ដើមព្រះអង្គពីខ្ញុំម្ចាស់បានឡើយ !

ពោលចប់ យុវនារីញាក់បង្ហៀរសេះ អោយចាប់ធ្វើដំណើរទើបនាង គ្រវីដាវឡើងយ៉ាងស្វាហាប់ ។

អស្ចារ្យណាស់ តាមចង្វាក់នៃផ្លែដាវរបស់នាង ដែលកំពុងវាសជ្រែក បរិយាកាសចុះឡើង ឆព្វណ្ណរង្សីក៏ភ្លឺរន្ទាលរះពេញសមរភូមិ ធ្វើឱ្យជនក្បត់និង បរិវារព្រិលភ្នែកស្រវាំងមើលអ្វីៗ លែងច្បាស់ទាំងអស់ ។

រាមរាជ្យ ឆ្ងល់ណាស់ វាក្រឡេកមួយភ្លែត ឃើញនារីយើងនាំព្រះរាជា ជ្រែកទ័ពរកច្រកចេញក៏ស្រែកថា ÷

- កនយើង ចូលទៅកាត់សិរសាស្ដេចក្មេងឈាមរាវនិងក្មេងក្រមុំនេះ អោយបាន ! នរណាធ្វើការនេះបានសម្រេច អញតាំងអោយធ្វើជាមហាឧបរាជ របស់អញ !

មេទ័ពជំនិតរបស់រាមរាជ្យប្រាំនាក់ឮបញ្ជានេះភ្លាម ក៏គ្រវីដាវសស្ទាច បំផាយសេះសំដៅ ជីវិតទាំងពីរយ៉ាងអង់អាច ។

- ប៉ាំង ! ប្រាវ !

ការជួបប្រយុទ្ធគ្នាក្នុងមួយប៉ព្រិចភ្នែកនេះ បានប្រព្រឹត្តទៅគួរអោយ ព្រឺព្រួចយ៉ាងខ្លាំង ។ ពេលជាបន្ទាប់ ផ្លែដាវទាំងប្រាំបានធ្លាក់ចុះព្រមគ្នា ទៅលើ

ព្រះវរកាយព្រះបាទសាយណ្ណវង្ស និងមិត្តនារីយើង តែមិនដឹងជាហេតុយ៉ាងដូចម្តេច ក៏ស្រាប់តែមេទ័ពទាំងប្រាំនាក់នេះ ត្រឡប់ជាកំបុតក្បាល, របូតខ្លួនធ្លាក់ពីលើខ្នងសេះអស់ទៅវិញដោយសារមុខដាវរបស់កញ្ញា ។

រាមរាជ្យក្តៅក្រហាយ ដូចធ្លាក់ទៅក្នុងភ្នក់ភ្លើងកល្ប វាដកលំពែងចោលយ៉ាងរហ័ស សំដៅផ្ទាំងទ្រូងកល្យាណី ។ ឥតប្រយោជន៍, រហ័សដូចផ្លេកបន្ទោរ, ស្រីថ្លៃគេចផុតពីមុខអាវុធនេះ ទើបស្រវាចាប់ដងលំពែង, ដែលកំពុងហោះជ្រែកអាកាសយ៉ាងលឿននេះ, ជាប់ទៀតផង ។

មិនបង្អង់អោយយូរពេល នាងចោលលំពែងតបទៅម្ចាស់ដើមវិញ ។ ជាកុសលយ៉ាងថ្លៃរបស់រាមរាជ្យ សេនាសំណប់របស់វាម្នាក់ បានយល់ថាមុខលំពែងនេះ ច្បាស់ជារត់ទៅពុះជ្រែកផ្ទាំងទ្រូងចៅហ្វាយរបស់វា វាក៏យកខ្លួនចូលមករងគ្រោះថ្នាក់នេះយ៉ាងក្លាហាន ។

- ឈិប ! អឿក ! ....... អូយ !

មុខលំពែងដ៏មុត រត់ទៅទម្លុះលង្វែកទ្រូងអានេះយ៉ាងជ្រៅ បណ្តាលឱ្យធ្លាក់ពីខ្នងដំរីមកដី ដល់ក្ស័យមរណកាលទៅមួយរំពេច ។

ជាបន្ទាន់នេះ វរជនស្នេហាជាតិយើងបីរូប ក៏ជិះសេះមកដល់ជាមួយនឹងកងទ័ពមួយចំនួនដែរ ។

ព្រះរាជា ទ្រង់ទតយល់ថាសុទ្ធជាសហការីរបស់ព្រះអង្គ គឺលោកតេជោក្លាហាន, លោកពិជ័យរចនា និងហោរាធិបតីទើបស្តេចទ្រង់បញ្ជាអោយនាំទ័ពថយក្រោយវិញ ហើយទ្រង់ត្រាស់ទៅនារីយើងថា ÷

- នាង ! ចូរបត់សេះតាមក្រោយទ័ពនេះចុះ ! នេះជាពួកយើងទេ !

- ព្រះពរ !

វរកញ្ញា ត្រីដាវបញ្ចេញពន្លឺស្មើរខ្វាក់ភ្នែក បំផាយសេះតាមក្រោយកងទ័ពជាតិ ចេញពីព្រះរាជវាំងយ៉ាងលឿន ។

ពួដំនភាល័យឯណោះ ព្រះនិសាករបង្កប់ព្រះកាយ បាត់ទៅក្នុងផ្ទាំងពពកខ្មៅ សភាពងងឹតបានគ្របដណ្តប់រាជធានីហាក់ជួយលាក់បំពួនអ្នកស្នេហាជាតិ អោយមានឱកាសភៀសខ្លួនទៅបានយ៉ាងងាយ ។

ឆាកបង្ហូរឈាម បានបិទវាំងននទៅវិញ ដាយប្រគល់ការជ័យជំនះទៅអោយរាមរាជ្យទាំងស្រុង ។ ក្រោមសម្លេងស្រែកហ៊ោកញ្ជ្រៀវប្រកបដោយការសប្បាយរីករាយ ក្រុមបក្សអាក្បត់នាំគ្នាហក់លោតដេញចាប់ស្រី១ ពេញព្រះបរមរាជវាំង ។

រាមរាជ្យ ដោយហេតុតែត្រេកអរនឹងមហាជោគជ័យនេះពេក ក៏បោះបង់ក្រិត្យវិន័យចោលអស់រលីង គេបើកច្បាប់អោយទាហានរបស់គេ ប្រព្រឹត្តអំពើពុករលួយតាមទំនើងចិត្ត ។

ពេលដែលជាបទឧក្រិដ្ឋពាលយង់ឃ្នង់ កំពុងរាតតទ្ធិពលពេញក្នុងផ្ទៃវាំង និងរាជធានី កងទ័ពជាតិ ក្រោមការដឹកនាំនៃព្រះករុណាជាអម្ចាស់លើត្បូងបានមកដល់ភ្នំមាសដោយសុវត្ថិភាព នៅពេលព្រះអរុណោទ័យចាប់ផ្តើមផ្សព្វ-ផ្សាយលំអងមាសលើភពសន្និវាស ។

# ៧
# ក្រោមរស្មីព្រះចន្ទ

រាមរាជ្យឡូន់បល្ល័ង្ករាជ្យព្រះបាទសាយណ្ណាវ័ន្ន ហើយក៏ប្រកាសខ្លួនជាស្តេចសោយរាជ្យនៅលើនគរសុវណ្ណភូមិ ។ ប្រជាពលរដ្ឋទាំងប្រទេសឮដំណឹងនេះភ្លាម ក៏រំភើបក្នុងចិត្តយ៉ាងខ្លាំង រន្ធះប្រតិកម្មមួយបានផ្ទុះឡើង នៅក្នុងដួងចិត្តយើងគ្រប់គ្នា ៗ ។ ចំណែកព្រះបាទសាយណ្ណាវ័ន្នវិញ កាលទ្រង់យាងមកដល់បន្ទាយភ្នំមាសហើយ ព្រះអង្គទ្រង់ព្រះតម្រិះរៀបចំកងទ័ពដែលភៀសមកតាមដង្ហែព្រះអង្គទាំងប៉ុន្មាន, និងកងទ័ពក្នុងបន្ទាយនេះទាំងអស់អោយក្លាយទៅជាកងបដិវត្តន៍មួយ ។ ស្តេចគង់ប្រថាប់នៅក្នុងបន្ទាយនេះបាន ២ ទិវា ទ្រង់ឈ្វេងយល់ថាបន្ទាយនេះស្ថិតនៅជិតរាជធានីពេក ដែលជាហេតុអាចឱ្យសត្រូវលើកទ័ពមកឡោមព័ទ្ធបានយ៉ាងងាយ ព្រះអង្គទ្រង់ប្រមូលទ័ពទៅបោះនៅឯកោះគោកធ្លកវិញ ។

ព្រឹត្តិការណ៍រំជើបរំជួលក្នុងផ្ទៃប្រទេស នៅតែកម្រើកនៅឡើយ តែការបដិវត្តន៍យ៉ាងក្លៀវក្លា ក៏បានចាប់កំណើតឡើងក្នុងពេលជាមួយគ្នានេះដែរ ។ នៅគ្រប់តំបន់ទាំងអស់ដែលព្រះប្រិយមហាក្សត្រ ទ្រង់យាងដល់ អ្នកស្រុកអ្នកភូមិទាំងក្មេងចាស់ប្រុសស្រី បានចោមរោមក្រាបបង្គំគាល់ព្រះអង្គ សំដែងទឹកចិត្តស្វាមីភក្តិយ៉ាងប្តូរផ្តាច់ ។ កម្លោះក្រមុំទាំងអស់នាំគ្នាថ្វាយខ្លួនបំរើក្នុងកងទ័ព

បដិវត្តន៍យ៉ាងស្មោះអស់ពីដួងចិត្ត គ្រឹះនៃសេចក្ដីសង្ឃឹមបានផុសឡើង នៅលើទឹកព្រះទ័យកសាងជាតិដោយចលនាបដិវត្តន៍ ដែលស្ថិតនៅក្រោមព្រះកិច្ចដឹកនាំរបស់ព្រះចមពល ត្រូវបានប្រជាជនក្នុងព្រះរាជអាណាចក្រគាំទ្រពេញទំហឹង

ពេលយើងមកដល់កោះគោកធ្លក បន្ទាយមួយដ៏ធំហើយមាំមហាស្ចារ្យបានត្រូវសង់ហើយគួរអោយស្ញើច ។ ចលនាបដិវត្តន៍ក៏ចាប់បើកឆាកឡើងក្រោមកម្លាំងសាមគ្គីប្ដូរផ្ដាច់ជាធ្លុងមួយ ......... ។

ទិវារាត្រីប្រកបដោយស្ថានការណ៍ច្របូកច្របល់ ចេះតែកន្លងទៅ រាត្រីនេះបើយើងក្រឡេកមកមើលក្នុងបន្ទាយគោកធ្លក យើងនឹងបានឃើញកងទ័ពបដិវត្តន៍ដ៏ច្រើនកកកុញ កំពុងសិក្សាក្បួនយុទ្ធសាស្ត្រយ៉ាងស្វាហាប់ ក្រោមការបង្ហាត់បង្រៀនផ្ទាល់របស់លោកមេទ័ពតេជោក្លាហាន លោកហោរាធិបតីឥសូរភទ្រ និងឧកញ៉ាពិជ័យរចនា ព្រមទាំងគ្រូអាវុធដ៏ចំណានច្រើនមកទៀត ។

ព្រះបាទសាយណ្ហាវ័ន្តមានព្រះភ័ក្ត្រីករាយ ទ្រង់យាងទតក្រុងនីមួយៗ ដោយសព្វព្រះរាជហឫទ័យជាអនេក ។

សូរអាវុធលាន់ឮប៉ែស ! ប៉ែស ! ឥតដាច់ ។ យូរៗ យើងឮសូរសំរែកហ៊ោកញ្ជ្រៀវ នៃពួកបដិវត្តន៍ម្ដងៗ ។

ព្រះរាជាទ្រង់ត្រាស់សរសើរលើកទឹកចិត្តកងទ័ព ហើយក៏ទ្រង់យាងចេញពីបន្ទាយតែមួយព្រះអង្គឯង ។

ផ្ទកខ្យាច់សស្អាតលាតសន្ធឹងវែងអន្លាយ ក្រោមពន្លឺព្រះច័ន្ទ ។

ព្រះពាយបក់មកត្រសៀកៗ ក្លិនផ្កាក៏រសាត់មកក្រអូបសាយ នៅឯ

មាត់សមុទ្រសម្លេងទឹករលកបោកផ្ទប់ច្រាំងបន្ទឹមកស្រោល។ ។

ព្រះភូមិន្ទ្រយាងកាត់វាលខ្សាច់យឺត។ ស្រូបយកខ្យល់អាកាសដ៏បរិសុទ្ធ ដែលកំពុងបក់ផាត់មកនាំទាំងក្លិនទឹកសមុទ្រមកជាមួយផង ។ យូរ។ ទ្រង់ងាកបែរព្រះភ័ក្ត្រមកក្រោយម្តង។ រូបរាងទ្រង់ទ្រាយបន្ទាយគោកធ្លក បានធ្វើអោយទ្រង់មានសេចក្តីទុក្ខភ័យយ៉ាងខ្លាំង ។ របងមាំ។ ហ៊ុំព័ទ្ធទៅដោយចម្រូងស្រួចមុត បញ្ចេញក្បាលរបង់ច្រូងច្រាង ហាក់ដូចជាមានវិញ្ញាណចងចាំថា នឹងរង់ចាំប្រហារខ្មាំងឈ្លានពានគ្រប់ពេល បើវាប៉ានចូលមកលុកលុយទៀត ។

ព្រះនរបតីដកព្រះនេត្រពីបន្ទាយ ទតឆ្ពោះសមុទ្រដ៏ធំធេង ដែលក្រាលទៅដោយកំទេចប្រាក់ភ្លឺផ្លេក ។ ទ្រង់សោយសុខក្នុងព្រះអារម្មណ៍យ៉ាងខ្លាំងចំពោះទស្សនីយភាពនាពេលរាត្រីខែភ្លឺដ៏ត្រជាក់នេះ ។ ព្រះអង្គយាងមកគង់នៅមាត់សមុទ្រអស់រយៈពេលមួយស្របក់ធំ ទើបទ្រង់សំរេចព្រះទ័យយាងនិវត្តន៍ចូលមកក្នុងបន្ទាយវិញ ។

ព្រះបាទាហៀបនឹងឈានទៅហើយ ស្រាប់តែសម្លេងដ៏ពិរោះផ្អែមល្ហែមមួយបន្លឺឡើង ញ៉ាំងទឹកព្រះទ័យព្រះអង្គអោយចង់ទៅស្គាល់មុខម្ចាស់សំលេងជាដាច់ខាត ។

ព្រះនរបតីបង្វិលព្រះកាយ មកកាន់ទីដែលសព្ទសម្លេងចម្រៀងកំពុងផ្ទុះ ទើបទ្រង់ចាប់យាងព្រះបាទាថ្នម។ តាមមាត់ទឹក ដរាបមកដល់កន្លែងដែលអ្នកចម្រៀងនៅឈប់សំចត ។

ព្រះយុវក្សត្រ លបវែកមែកព្រឹក្សាទៅ រូបភាពកញ្ញាដ៏ឆើតឆាយដែលទ្រង់ធ្លាប់ស្គាល់ច្បាស់បានលេចធ្លោឡើង ធ្វើអោយទ្រង់រំភើបញាប់ញ័រក្នុងព្រះ

ចិន្តាយ៉ាងខ្លាំង ។ នៅលើផែនដីសិលាមួយផ្ទាំងដែលទឹករលកតែងយកកាយមកត្រដុសលេង នាងអង្គុយយ៉ាងស្ងួតស្ងប់ច្រៀងបណ្តែតអារម្មណ៍ទៅសែនឆ្ងាយ ។

ឱ ! ប្រហែលជានាងពុំទាន់ដឹងខ្លួនថា ព្រះបាទសាយណ្ហាវ័ន្តយាងមកលបស្តាប់នាងច្រៀងលេងទេមើលទៅ ?

មែនហើយ ! នាងពុំទាន់ដឹងនៅឡើយទេ ! តែចៃដន្យអ្វីបន្តិចមកស្រាប់តែនាងភ្ញាក់ខ្លួនក្រញាង ចាកផុតពីភពរីករាយដោយសត្វរលកខ្មោចមួយមិនដឹងជាហើរមកពីទីណាផង បានស្រែកសង្ឃកយ៉ាងខ្លាំងកាត់សម្លេងនាងកល្យាណីឈប់ច្រៀងទ្រូងនាងញ័ររណ្តំ ដោយអារម្មណ៍ព្រឺស្ញើប ។ នាងងាកមុខងើយមើលទៅលើ បក្សាហិចហើរទៅបាត់ ។ ជាមួយគ្នានេះ ធីតាក៏ភ្ញាក់ម្តងទៀត ព្រោះនៅក្រោយខ្នងនាង សម្លេងមួយដែលនាងធ្លាប់ឮជាច្រើនដងមកហើយ បានបន្លឺឡើងនៅក្រោយខ្នងនាងថា ÷

- ចម្រៀងនេះពិរោះណាស់ កេសររង្សី !

ឆោមឆើត ងាកផាំងមកក៏ស្គាល់ច្បាស់នៃម្ចាស់សំលេងនេះ. នាងបាត់ភ័យតែស្រីអៀនអន់ក្នុងចិត្តពន់ប្រមាណ ។ ឆោមនិមលបញ្ចេញសម្លស្សញញឹមទៅកាន់ម្ចាស់សំលេងនេះ ទើបប្រែកិរិយាហៀបនឹងក្រោកឈរស្រាប់តែបុរសមកដល់ ទល់នឹងមុខនាងទៅហើយដែរ ។

- មិនបាច់ក្រោកទេកេសររង្សី នាងអង្គុយដូចដើមចុះ ! ..... អម្បាញមិញប្រហែលជានាងភិតភ័យខ្លាំងហើយ !

- ព្រះពរ ! (នាងតបដោយសំលេងសុភាព) ខ្ញុំម្ចាស់ភិតភ័យបន្តិចដែរ ! .......

- ឥឡូវនាងបាត់ភ័យហើយឬនៅ ?

ព្រះចមពលទ្រង់ត្រាស់ដោយសម្រុតព្រះវរកាយ គង់នៅលើផែនសិ-លាមួយផ្ទាំងទល់មុខកញ្ញា កញ្ញាកេសរវង្សីដែលមិនគឺនរណាក្រៅពីវីរកញ្ញាបានចូលទៅរំដោះព្រះអង្គ ចេញពីក្រញាំនៃការឡោមព័ទ្ធរបស់រាមរាជ្យ កាលពីក្នុងពេលកើតរដ្ឋប្រហារឡើយ ។ នាងងើបភ័ក្ត្រ ដក់ទៅដោយទឹកដមមន្តស្នេហ៍គយគន់ព្រះភក្ត្រព្រះរាជាទើបបង្ហូរមធុរវាចាតបទៅព្រះអង្គថា ÷

- ព្រះពរ ! ........ ឥឡូវខ្ញុំម្ចាស់ បាត់ភ័យរន្ធត់ទៀតហើយព្រោះដឹងថាព្រះអង្គ ! .......

វលកសព្ទវាចារលត់ផុតទៅសភាពស្ងប់ស្ងាត់ ក៏បញ្ចេញកាយលេបបរិយាកាស ដ៏ប្លែកនៃបេះដូងជីវិតទាំងពីរនេះ ។ ព្រះរាជា ទតសំលឹងទឹករលកបោកប៉ះថ្មយ៉ាងស្ងៀមស្ងាត់ចាំស្តាប់ទិព្វវាចារបស់កេសរវង្សី ។ តែផ្ទុយទៅវិញស្រឡះ តរុណី ពេលនេះហាក់ដូចស្លុតរន្ធត់ក្នុងចិត្តយ៉ាងប្លែកខុសពីធម្មតា ។ អណ្តាតនាងទាំងអស់ មួយខណៈដោយមិនដឹងរើសរកពាក្យអ្វី មកបំពាស្ពីទូលថ្វាយព្រះនរបតីបានតទៅទៀត នាងមានតែឱនមុខរំលេចសម្រស់ញញឹម ដែលជាកំណាប់ទ្រព្យកើតមកពីធម្មជាតិ និងកេះក្រចកបណ្តើរខ្យល់អារម្មណ៍ តាមចង្វាក់ភ្លេងជីពចរដែលលោតហាក់យ៉ាងញាប់រន្ថាន់ ។

ទឹករលកបោកផ្ទប់ច្រាំងឮឥតដាច់សូរ ខ្យល់ថ្ងូរឮគ្រលួចបន្លំបន្ទរនឹងទំនួញស្លឹកឈើដែលរណ្តំគ្នាឮរ៉ាក១ ឥតឈប់ ។

ពន្លឺនភមណ្ឌលព្រះចន្ទ្រារះពេញពន្លឺ ។

ព្រះបាទសាយណ្ហាវ៉ុន ងាកបែរព្រះភ័ក្ត្រពីទឹករលកទតមកកេសរវង្សី

ដោយបន្ទឹព្រះវាចាតិច១ នូវទំនុកថ្មីថា ÷

- កេសរវង្សី ! យប់នេះខ្ញុំពុំបានគិតថា នឹងបានមកជួបនាងដោយចៃ-ជន្យយ៉ាងនេះទេ ! ....... ខ្ញុំជឿថានេះប្រហែលជាខ្សែវិថីព្រះព្រហ្មលិខិតចារតម្រង់ យើងអោយបានមកជួបគ្នាដោយពិត នៅជិតខ្ញុំនាងមានសេចក្តីរីករាយទេ ! ........

- ព្រះពរ ! ខ្ញុំម្ចាស់រីករាយណាស់ តូចតន់ពោលដោយវាសខ្សែនេត្រកាត់ផ្ទៃព្រះភ័ក្ត្រព្រះភូមិន្ទ្រ ធ្វើអោយព្រះទ័យព្រះអង្គព្រឺព្រួចឥតបីថ្លែងបានឡើយ តែនៅចំពោះមុខចំណុចដ៏ទន់ខ្សោយនៃភ្លើងតណ្ហាបក់បោក បានមួយខណៈយ៉ាងតូចនេះ ព្រះអង្គបានប្រមូលនូវសភាពរឹងប៉ឹង ពន្លត់វាអោយទ្រុតទ្រោមទៅវិញ ទើបទ្រង់កាត់សំណួរចាស់ចោល វិលមកចាប់សំនួរថ្មីមួយទៀត ។

- កេសរវង្សី ! (ព្រះរាជាត្រាស់ដាច់១) ក្នុងមួយជីវិតខ្ញុំនេះ ខ្ញុំពុំដែលស្គាល់នារីរូបណា ដែលមានសេចក្តីក្លាហានអង់អាចដូចនាងទេ ! ......

នាងជាវីរនារីពិត១, កាលពីរដ្ឋប្រហារបានកើតឡើងដោយស្ងាត់កំ-បាំង ដែលគេពុំអាចដឹងជាមុនបាន កុំតែនាងចូលមកជួយការពារខ្ញុំ ខ្ញុំប្រហែលជាអស់ជីវិតដោយសារមេក្បត់រាមរាជ្យទៅហើយ ។

- ព្រះពរ ! ពេលនោះខ្ញុំម្ចាស់អង់អាច និងហាក់ដូចជាពូកែទៅបាន ក៏អាស្រ័យដោយសារដាវជ័យសិទ្ធិ ជាកេរ្តិ៍មរតកពីជីតារបស់ខ្ញុំម្ចាស់ប៉ុណ្ណោះ ! តាមពិតខ្ញុំម្ចាស់ពុំដែលប្រឡូកក្នុងសមរភូមិដល់ម្តងណាឡើយ ! ........

កេសរវង្សី ទូលព្រះអង្គដោយទឹកមុខញញឹម ។ ព្រះរាជាទ្រង់ជ្រាបថា នាងមានដាវជ័យសិទ្ធិ ក៏ទ្រង់ចាប់ព្រះអារម្មណ៍យ៉ាងខ្លាំង ។

- នាងមានដាវជ័យសិទ្ធិ ? ចុះដាវជ័យសិទ្ធិហ្នឹង នាងបានពីណា ?

- ព្រះពរព្រះអង្គ ! កាលដែលខ្ញុំម្ចាស់រត់ចេញពីស្រុកដើម្បីភៀសខ្លួន ចេញឱ្យផុតពីក្រញាំរបស់មេក្បត់ជាតិរាមរាជ្យ ដែលបានលើកទ័ពលបលួច ចូលមកវាយបំបែកបន្ទាយគោកធ្លក ដោយអស់កំលាំងក្នុងការធ្វើដំណើរពេក ខ្ញុំម្ចាស់ក៏ដាច់ចិត្តចូលទៅសម្រាកក្នុងខ្ទមមួយ ដែលគេសង់ចោលនៅក្រោមដើមជ្រៃមួយដើមនាជើងភ្នំមាស ស្រាប់តែដល់ពេលដែលខ្ញុំម្ចាស់បានលង់លក់ស៊ប់ក្នុងដំណេក ខ្ញុំម្ចាស់បានយល់សប្តិឃើញខ្មោចជីតារបស់ខ្ញុំម្ចាស់ស្លៀកសពាក់សមកប្រាប់ថា ឱ្យខ្ញុំម្ចាស់ទៅយកដាវជ័យសិទ្ធិ ដែលជាដាវមរតករបស់គាត់ទុកឱ្យខ្ញុំម្ចាស់ ដែលលាក់នៅក្រោមព្រះរូបសំណាកព្រះបាទសុនិន្ទ្រាវរ្ម័ន ត្រង់ព្រះបាទខាងឆ្វេង ។ ពេលនោះជីតាខ្ញុំម្ចាស់បានប្រាប់ខ្ញុំម្ចាស់ថា : បើបានដាវនេះហើយ អោយប្រញាប់មកជួយព្រះអង្គ ដែលពួកក្បត់ចូលមកប្លន់ព្រះរាជបល្លង្ករាជ្យ ។ ពេលភ្ញាក់ពីដំណេកខ្ញុំម្ចាស់ឥតនឹកថា សុបិននិម្មិតនេះជារឿងពិតទេ តែដោយមិនអស់ចិត្ត ខ្ញុំម្ចាស់ឡើងទៅលើកំពូលភ្នំ ឃើញព្រះរូបសំណាកព្រះបាទសុនិន្ទ្រាវរ្ម័នមែន ខ្ញុំម្ចាស់ក៏ជឿ ។ លុះមើលទៅត្រង់ព្រះបាទខាងឆ្វេងខ្ញុំម្ចាស់ឃើញសិលាចារិកមួយផ្ទាំង ខ្ញុំម្ចាស់បានទាញបង្ហើបឡើងស្រាប់តែឃើញដាវមួយគូដាក់ទន្ទឹមគ្នា ខ្ញុំម្ចាស់ក៏ចាប់យកដាវមួយមក ។

បានដាវហើយខ្ញុំម្ចាស់ ហាក់ដូចជាក្លាហានក្នុងចិត្តយ៉ាងប្លែក ខ្ញុំម្ចាស់បានចុះពីលើកំពូលភ្នំមកដល់ខាងក្រោមវិញ នៅពេលថ្ងៃហៀបលិចទៅហើយ ។

ពេលនេះខ្ញុំម្ចាស់បានជឿស៊ប់ថា សុបិននិម្មិតនេះជារឿងពិត ក៏ប្រញាប់ជិះសេះចេញពីជើងភ្នំមកកាន់ទីក្រុង ដោយឥតហ៊ានឈប់បង្អង់ ..... លុះ



មកដល់ស្រាប់តែជួបប្រទះការប្រយុទ្ធគ្នាយ៉ាងសម្បើមមែន ។

- ដាវជ័យសិទ្ធិ ! (ព្រះរាជាទ្រង់ត្រាស់ដោយព្រះទ័យកោតស្ញប់ស្ញែង) ឱ ! ដាវជ័យសិទ្ធិពូកែមែន ! តែអត់ទោសចុះនាង ឪពុកម្ដាយនាងសព្វថ្ងៃនៅឯណា ហើយគាត់ឈ្មោះអ្វីទៅ ! ខ្ញុំចង់ស្គាល់គាត់ណាស់ ។

នាងកេសរវង្សីឮព្រះសំនួរភ្លាម ក៏អួលអាក់ក្នុងចិន្ដាយ៉ាងខ្លាំង នាង

ទូលព្រះអង្គដោយទឹកមុខស្រពាប់ស្រពោនថា ÷

- ព្រះពរព្រះអង្គ ! មាតាបិតាខ្ញុំម្ចាស់ អនិច្ចកម្មក្នុងសង្គ្រាមបាត់អស់ទៅហើយ ! .......

បិតាខ្ញុំម្ចាស់ឈ្មោះជិនិតភក្តី ជាឧកញ៉ារក្សាខ័ណ្ឌចៅហ្វាយគោកធ្លកនេះក្រាបទូល !

- អុះ ! លោកជិនិតភក្ដីទេ ជាឪពុកនាង ! (ព្រះរាជាទ្រង់ភ្ញាត់ព្រះឱស្ឋ) ហ៊ឺ ! លោកជាមន្ត្រីស្មោះចំពោះជាតិណាស់ ! ........

ធីតានៅស្ងៀមស្ដាប់ព្រះបន្ទូលព្រះករុណា ទ្រូងនាងតឹងចង្អៀតពន់ប្រមាណដោយសារព្យុះនៃការសោកសៅ បក់បោកទងប្រមាត់ និងបេះដូងនាងយ៉ាងសាហាវ ។ ព្រះនរបតីទ្រង់យល់ថាកេសរវង្សី កំពុងមានអារម្មណ៍ខ្សឹកខ្សួលយ៉ាងសម្ងាត់ ព្រះអង្គទ្រង់ប្រញាប់បង្វែរព្រះរាជសព្ទផ្សេងៗ ជាការលប់បន្លប់ស្មានទុក្ខវិយោគរបស់នាង ។

ព្រះពាយបក់ជូនដំណើរព្រះច័ន្ទ អោយចរទៅកាន់តែឆ្ងាយណាស់ហើយ ។

តារាទាំងឡាយបានរលប់រូបឆោមមួយម្ដងៗ ទៅតាមសភាពដំណើរនៃធម្មជាតិ ។ ពពកសរសាត់លយលេងយឺតៗ ប្រកិតគ្នាគួរអោយចង់គយគន់ណាស់ ។ តែពេលថ្មើរណេះយប់យន់ជ្រៅណាស់ទៅហើយ ព្រះបាទសាយណ្ហាវ័ន្តពុំអាចគង់ក្រសាលតទៅទៀតបាន ព្រះអង្គទ្រង់នាំគូសន្ទនារបស់ព្រះអង្គត្រលប់មកបន្ទាយវិញ ។

កាលបានជួបនាងកេសរវង្សីនៅមាត់សមុទ្រ ក្នុងពេលរាត្រីដ៏ត្រជាក់

ព្រះទ័យព្រះបាទសាយណ្ណាវ័ន្ន ហាក់បានដក់ប្រឡាក់ទៅដោយលំអងអារម្មណ៍មួយយ៉ាងប្លែក ដែលតាំងតែពីដើមព្រះអង្គពុំដែលបានគិតគួរព្រាងទុកមកទាល់តែសោះ ។

ពេលឃ្លាតពីនាងទៅ ព្រះអង្គទ្រង់រសាប់រសល់ខុសប្រក្រតីទាំងអស់ហេតុដូច្នេះហើយបានជាទ្រង់ត្រាស់សួរព្រះអង្គឯងថា : ឱ ! តើនេះវាបណ្ដាលមកពីអំណាចមហាវេទមន្តអ្វីទៅហ្ន៎ !

ក្រាបទូល ! ហ្នឹងហើយ សេចក្ដីស្នេហា ! ........

សេចក្ដីស្នេហា ! ព្រះម្ចាស់សួគ៌អើយ ! វាបានញុំាងព្រះទ័យព្រះយុវក្សត្រអោយវិលវល់យ៉ាងចំលែកណាស់ ដែលក្នុងមួយជីវិតព្រះអង្គៗ ពុំដែលពើបប្រទះសោះ ។

នៅរាត្រីបែកគ្នានេះ ទ្រង់ផ្ទំសឹងពុំលក់ទេ ព្រះវិញ្ញាណចេះតែនាំឱ្យព្រះអង្គមមៃគិតមកកេសររង្សី. ហើយពាក្យសំដីគ្រប់ម៉ាត់របស់នាងសោត ក៏មិនដឹងជាវត្ថុសក្ដិសិទ្ធិអ្វី នាំមកបន្លឺសារជាថ្មីឱ្យលាន់ឮកងរំពងពេញក្នុងសោតិន្ទ្រីយារម្មណ៍ព្រះអង្គ ។

ខ្យល់ជំនោរបក់ វូ ! វូ ! ចូលតាមបង្អួចព្រះដំណាក់. ក្សត្រាទ្រង់ផ្ទំបើកព្រះនេត្រភ្លឹះ ! ភ្លឹះ ! អស់ពេលយ៉ាងយូរ ទើបទ្រង់បិទព្រះនេត្រលង់លក់ក្នុងព្រះនិន្ទ្រារម្មណ៍យ៉ាងក្សេមក្សាន្ត ។

# ៨
# ដាវខ្ញុំបាត់ទៅណា ?

យើងនិយាយពីរាមរាជ្យម្តង .........

អ្នកគ្រប់គ្រងរដ្ឋថ្មីនេះ ក្រោយដែលរៀបចំមុខដំណែង ចែកជូនសហការីរបស់គេគ្រប់រូបបានស្រួលបួលហើយ ក៏ផ្តើមចាត់ទាហានសម្ងាត់ចេញទៅស៊ើបការណ៍រកព្រះបាទសាយណ្ហាវ័ន្ត និងមន្ត្រីព្រមទាំងទាហានភៀសខ្លួនទាំងអស់អោយដឹងថា តើសព្វថ្ងៃនៅឯណា ?

មួយផ្នែកទៀតក្នុងករណីនេះ រាមរាជ្យបានប្រាប់ទាហានសម្ងាត់ឱ្យស៊ើបពីនារី ដែលចូលមករំដោះព្រះបាទសាយណ្ហាវ័ន្តអោយបានចេញផុតពីការឡោមព័ទ្ធរបស់គេ អោយបានច្បាស់លាស់បំផុតថា តើនាងពូកែដោយសារអ្វី ? បើមកពីដាវដែលនាងកាន់គ្រវីលេចចេញនូវកាំរស្មីយ៉ាងចម្លែកនោះមែន ត្រូវចាត់វិធានការដណ្តើមយកដាវនោះអោយបានជាដាច់ខាត ។

ចារបុរសចេញដំណើរបែកគ្នា តាមដោយក្រុម១ ទៅគ្រប់ច្រកល្ហកទាំងអស់ក្នុងព្រះរាជអាណាចក្រ ។

ក្សិណនោះសាយណ្ហសម័យ ដ៏ត្រជាក់បានធ្លាក់មកដល់ដោយព្រះសុរិយង្គ បានបន្ទាបព្រះកាយកៀកកិតជិតកំពូលភ្នំព្រះសុមេរុទៅហើយ ។ ព្រះវាតារសាត់ត្រសៀក១ ពីទិសបូពិរុញច្រានកំសួលពិសព្រះសូរ្យសែងអោយឃ្លាតផុត

ពីផែនដី ។

នៅកោះគោកធ្លក សកម្មភាពខ្សៀវខ្សា ដែលកើតឡើងពីព្រលឹងនៃការរួបរួមយ៉ាងជិតស្និទ្ធ ជុំវិញព្រះប្រិយមហាក្សត្របានទាញអារម្មណ៍អ្នកលក់សំពាយបីរូប ដែលបានមកដល់ភូមិភពសន្តិភាពនេះយ៉ាងខ្លាំង ។

នាយឈ្មួញចល័ត បោះជំហានដើរកាត់ទីប្រជុំជនគោកធ្លកមៀងមើលមុខគ្នា ដោយក្រសែភ្នែកពេញពោរទៅដោយរហស្សបាយ ។ ជួនជាឱកាសល្អដល់នាយម្នាក់ឈ្មោះឃ្មីល ឧទានទៅកាន់គូកនគេពីរនាក់ដោយតិចៗ ថា ÷

- អាប្រុញ ! អាស្មោញ ! យើងគិតធ្វើយ៉ាងម៉េចពេលនេះ ដើម្បីឱ្យបានដឹងពតិមានជាក់លាក់ពីព្រះបាទសាយណ្ហាវ័ន្ន និងនាងដែលមានដាវជ័យ-សិទ្ធិ ! ........

ស្មោញងាកមើលឆ្វេងស្តាំ ខ្លាចក្រែងមាននរណាម្នាក់លបស្តាប់ឮ ទើបវាចាតបទៅមិត្តរួមដំណើររបស់គេ ÷

- តាមគំនិតអញ ! គឺមានតែម្យ៉ាងទេ ! យើងត្រូវតែនាំគ្នាចូលទៅក្នុងបន្ទាយគោកធ្លក ធ្វើជាសុំថ្វាយខ្លួនចំពោះព្រះបាទសាយណ្ហាវ័ន្ន បំរើក្នុងកងទ័ពព្រះអង្គ នោះយើងពិតជាបានសម្រេចនូវគម្រោងការណ៍ស៊ើបអង្កេត ជាប្រាកដ ! ......

- ចុះបើត្រឡប់ជាស៊យ ត្រូវគេដឹងជើងការសម្ងាត់របស់យើង នោះយើងមិនបាក់ដូចជាដើរចូលក្នុងមាត់ខ្លាទៅហើយ !

នាយប្រុញពោលដោយរារែកក្នុងចិត្ត ។ នាយឃ្មីលយល់អាកប្បកិរិ-

យាមិត្តរបស់ខ្លួន ដូច្នេះក៏ឆ្លើយកាត់ជាសំនួរថា ÷

- ចុះតើលក្ខណៈណាខ្លះដែលបង្ហាញអោយឃើញថា ពួកយើងប្រើឧបាយកលចូលមកស៊ើបការសម្ងាត់ពីពួកនេះ ! ........

ណ្ហើយអាឃ្នីលអើយ កុំទៅជំនុំជាមួយអាប្រុញសុញ្ញគំនិតនោះ វាពុំអាចសំរេចការអ្វីទៅបានទេ ! ...... របៀបវានេះ បើព្រះអង្គរាមរាជ្យ (១) ទ្រង់ជ្រាបមុខជាកំបុតកជាមិនខាន ! មក !

យើងគិតការលក់ក្រណាត់ក្នុងសំពាយនេះ អោយអស់ភ្លាម១ ទៅនឹងអាលទៅបន្ទាយកុំអោយយប់ទាន់ !

ស្របតាមយោបល់នេះ អ្នកចារបុរសរបស់រាមរាជ្យទាំងបីរូប បានយកក្រណាត់ក្នុងសំពាយទៅបោះលក់អោយអ្នកទំនិញក្នុងផ្សារ ទើបនាំគ្នាស្រូតរូតដំណើរ មកកាន់បន្ទាយគោកធ្លក ។

កាលមកដល់ អ្នកទាំងបីបានសុំអ្នកយាមចូលទៅគាល់ព្រះបាទសាយ-ណ្ហាវ័ន្តដែលគង់នៅក្នុងបន្ទាយ ថាខ្លួនគេសុំចូលមកបម្រើព្រះអង្គក្នុងកងទ័ពបដិវត្តន៍នេះ ។

ដោយហេតុមិនដឹង យើងបាននាំនាយប្រុញ, នាយស្មោញ, និងនាយឃ្នីល ចូលទៅក្រាបបង្គំគាល់ព្រះចមពលក្នុងព្រះតំណាក់ពិសេស ។ ព្រះរាជាកាលទ្រង់ជ្រាបថា ពួកវាសុំថ្វាយខ្លួនមកបម្រើកងទ័ពបដិវត្តន៍ ព្រះអង្គទ្រង់ថ្លែងព្រះទ័យសោមនស្សយ៉ាងខ្លាំង ដោយទ្រង់ព្រមទទួលវាតាមសេចក្ដីសុំ ។

---

(១) ទាហានរបស់រាមរាជ្យ ហៅរាមរាជ្យ ដោយពាក្យនេះ

អ្នកស៊ើបការ បានមករស់នៅក្នុងបន្ទាយគោកធ្លក ហើយក៏ចាប់ផ្ដើមលួចស៊ើបយកការសម្ងាត់ពីក្រុមបដិវត្តន៍ គ្មានសល់ចន្លោះ ។

ជាអកុសលថ្ងៃមួយព្រះប្រមុខនៃកងទ័ពបដិវត្តន៍ ស្ដេចទ្រង់អផ្សុកក្នុងព្រះរាជហឫទ័យភ័យយ៉ាងខ្លាំង ហើយដោយពេលនោះ ស្បៀងអាហារសំរាប់ផ្គត់ផ្គង់ក្រពះកងទ័ពត្រូវខ្វះខាតផង ព្រះអង្គទ្រង់យាងចេញពីបន្ទាយទៅអង្គាសស្បៀងអាហារពីប្រជារាស្ត្រតាមស្រុក ភូមិ ដោយផ្ទាល់ព្រះអង្គ ជាមួយនឹងកងទ័ពមួយចំនួន ដែលហែរហមព្រះអង្គថ្វាយជាព្រះរាជកិត្តិយស ។

នាយប្រុញ, នាយស្មោញ និងនាយឃ្មីលដឹងដូច្នេះភ្លាម ក៏ប្រញាប់នាំគ្នាចូលមកបង្កប់ខ្លួនក្នុងក្បួនទ័ពដែលចេញទៅអង្គាសស្បៀងអាហារ ។

ពេញមួយថ្ងៃ ដែលព្រះករុណាបាននាំទ័ពយាងចូលគ្រប់ភូមិស្រុក អ្នកស្រុកបានចោមរោមចូលមកថ្វាយបង្គំព្រះអង្គ ដោយបញ្ចេញស្បៀងអាហារពីគេហស្ថាន នាំយកមកថ្វាយព្រះអង្គគ្រប់ៗ គ្នា ។

ព្រះប្រិយមហាក្សត្រទ្រង់រីករាយក្នុងព្រះទ័យ ដោយឃើញសេចក្ដីស្វាមីភក្ដិដ៏ស្មោះត្រង់របស់ប្រជារាស្ត្រ ។

ស្ដេចគង់នៅលើព្រះទីនាំងអស្សពាហ៍ពណ៌ស, ដែលបោលទៅមុខក្បួនទ័ព ទន្ទឹមនឹងជំនិះនាងកេសររង្សី ព្រះអង្គត្រាស់ដោយព្រះភ័ក្ត្រញញឹម ដូចបុប្ផាទើបតែរីកចេញពីស្រទាប់ត្របកនាពេលអរុណរះពេញពន្លឺ ។

- កេសររង្សី ! ខ្ញុំមិននឹកស្មានថាយើងចេញទៅអង្គាសស្បៀងអាហារពីអ្នកស្រុកបានច្រើនដូច្នេះសោះទេ ! តែពេលនេះ ព្រលប់ធំណាស់ទៅហើយ

តើយើងគិតបោះជម្រុំសម្រាកត្រង់មាត់ស្ទឹងនេះ ឬមួយត្រលប់ទៅបន្ទាយគោក ធ្លកទាំងយប់តែម្ដង ! ........

កល្យាណីបន្ទន់កាយ គោរពចំពោះព្រះភូធរ ទើបទូលព្រះអង្គថា ÷

- ព្រះពរ ! ការនេះបើល្អងធូលីព្រះបាទ មិនទ្រង់យាងទៅអង្គាសស្បៀងអាហារពីអ្នកស្រុកផ្នែកខាងជើងក្នុងពេលស្អែកទេ ! គួរយាងទៅបន្ទាយគោកធ្លកទាំងយប់នេះទើបសម តែបើព្រះអង្គស្ដេចត្រូវការយាងទៅស្រុកខាងជើង ក្នុងពេលស្អែកដដែល, គួរព្រះអង្គបោះទ័ពសំរាកត្រង់នេះចុះ ព្រោះកុំឱ្យខាតពេលក្រាបទូល ! ........

- បើដូច្នេះ យើងត្រូវបោះទ័ពឈប់សម្រាកនៅត្រង់មាត់ស្ទឹងនេះហើយ យប់នេះ ! ....... ព្រោះស្អែកយើងត្រូវទៅភូមិខាងជើងទៀត ! .......

ដោយគោរពតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់ នៃព្រះបាទសាយណ្ហាវ័ន្ន ព្រះរាជបរិពារ ក៏នាំគ្នាបោះទ័ពឈប់សម្រាកនៅត្រង់មាត់ស្ទឹង ដោយរៀបចំដាក់កងយាមល្បាតយ៉ាងហ្មឹងម៉ាត់ ។

អ្នកយាការសម្ងាត់របស់រាមរាជ្យយល់ឃើញថា រាត្រីបោះទ័ពនៅតាមមាត់ស្ទឹងនេះ ជាឱកាសប្រសើរបំផុត សម្រាប់ចៅហ្វាយរបស់វា វាក៏បានចាត់អោយនាយប្រុញ លួចរត់ចេញពីជម្រំទ័ព នាំយកដំណឹងនេះទៅអោយរាមរាជ្យ ឯរាជធានីសុវណ្ណភូមិ ។

ប្រុញលួចជិះសេះចេញពីជម្រំផុតទៅ ...... ព្រះចន្ទ្រារាងជាផ្លែកណ្ដៀវមាសក៏បានរះចេញមកជួបសត្វលោក ។

ព្រៃព្រឹក្សាឈើទ្រមឹងស្ងៀមស្ងាត់ក្នុងជំរៅរាត្រី ។ បក្សាបក្សីស្រែកយំទ្រហឹង គួរអោយព្រឺខ្លាច ក្រោមផ្ទៃដ៏មហាស្ងាត់ក្នុងដែនអរញ្ញនេះ ។

ទាហានទាំងឡាយដេកលក់ត្រៀបត្រាទៅហើយ នៅសល់តែអ្នកយាមល្បាតកំពុងដើរប្រតិបត្តិការណ៍ តាមមុខងាររបស់ខ្លួនយ៉ាងប្រុងប្រយ័ត្នប៉ុណ្ណោះ ។

យប់នេះ ពិតមែនតែយើងស្ថិតនៅក្នុងលង្វែកទ្រូងព្រៃ តែយើងស្អុះ-ស្អាប់យ៉ាងចម្លែក ។

គ្មានខ្យល់សោះ, អាកាសធាតុក្តៅហប់គួរអោយធុញទ្រាន់ ។ អកុសលអ្វីចំហាយដីក្តៅឧណ្ហៗ បានបក់មកភាយៗ ឥតឈប់ឈរ ហាក់មិនចង់អោយព្រះបាទសាយណ្ហាវ័ន្តនាំកងទ័ពមកឈប់សំរាកកំលាំងនៅទីនោះសោះ ។

ព្រះរាជាមិនទាន់ចូលផ្ទុំនៅក្នុងព្រះពន្លា ពិសេសនៅឡើយទេ, ព្រះអង្គទ្រង់យាងមកគង់ក្រសាលមាត់ស្ទឹងជាមួយកញ្ញាកេសរវង្សី ដោយទ្រង់ស្អុះ-ស្អាប់ព្រះវរកាយពេក ។

ពេលនេះគ្មានអ្វីអោយមានតម្លៃស្មើនឹងរាត្រី ដែលបេះដូងពីរកំពុងតែបង្ហាញនូវគំនូចស្នេហ៍រៀងៗ ខ្លួន ក្រោមពន្លឺដ៏ស្រទន់នៃព្រះចន្ទា ។ គេទាំងពីរកំពុងតែលង់ក្នុងអារម្មណ៍ ដ៏លន្លង់លន្លោច ដោយពុំដឹងថាមានស្រមោលពីរកំពុងតែដើរលបៗ តាមគុម្ពោតព្រៃប្របមាត់ស្ទឹង មកលបមើលកាយវិការ និងការសន្ទនារបស់ពួកគេឡើយ ។

ព្រះរាជា ប្រថាប់ព្រះកាយព្រះអង្គនាគល់ឈើមួយក្បែរតរុណី ព្រម

ទាំងឆ្មៀងព្រះនេត្រ លបលួចគយគន់សម្ផស្ស កេសរវង្សី សព្វអន្លើ តែដោយពុំឃើញនាងយកដាវជ័យសិទ្ធិ ជាប់មកតាមខ្លួន ព្រះអង្គទ្រង់ព្រះចិន្តាតែមួយអង្គឯងថា ប្រហែលជានាងមិនយកដាវនោះមកជាមួយទៅមើលទៅ ។

ទ្រង់ត្រាស់សួរទៅតរុណីថា ÷

- កេសរវង្សី ! ខ្ញុំចង់ទតដាវជ័យសិទ្ធិរបស់នាងដោយផ្ទាល់ព្រះនេត្រណាស់ !

កេសរវង្សី ក្រាបទូលព្រះអង្គវិញភ្លាមថា ÷

- ក្រាបទូល សូមព្រះរាជទានទោសព្រះអង្គ ខ្ញុំម្ចាស់មិនបានយកមកទីនេះទេ ! ខ្ញុំម្ចាស់ .......

ព្រះរាជាទ្រង់គង់ស្ងៀមទុកនៅឯជម្រំឯណោះក្រាបទូល ថ្ងៃស្អែកខ្ញុំម្ចាស់នឹងយកមកថ្វាយព្រះអង្គទតដោយពិតប្រាកដក្រាបទូល ។

ព្រះរាជាទ្រង់ព្រះសម្រួលព្រមទាំងព្រះចិន្តាទៀតថា នាងមុខជាទុកនៅក្នុងដំណាករបស់នាងឯណោះហើយ ! .........

អ្នកទាំងពីរញញឹមមើលមុខគ្នា រួចកេះគ្នាដើរចេញពីនេះមួយរំពេច ។ មកដល់ដំណោករបស់នាងដែលមានការរៀបចំយ៉ាងស្រួលបួល ជាប់ជិតនឹងព្រះពន្លាពិសេស នៃព្រះបាទសាយណ្ហាវ័ន្ន វាលបចូលទៅ ក៏ប្រទះឃើញដាវជ័យសិទ្ធិនៅលើកន្ទេល ។ សែនត្រេកអរ. ឃ្មីលស្រវាចាប់ដាវនេះមកស្ពាយ ទើបដាក់ដាវរបស់គេទៅលើកន្ទេល ។ គេនិយាយទៅស្មោញថា ÷

- ដាវបានមកយើងហើយ ពេលនេះយើងត្រូវតែភៀសខ្លួន ចេញពី

កន្លែងនេះទើបបាន !

- អើនៅទាល់តែស្លាប់ទៅឬ ?

ស្មោញតប ដោយដឹកដៃឃ្មីលលូនចេញពីដំណេកនាងកេសរវង្សីវិញ យ៉ាងថ្នមៗ ហើយប្រុងប្រយ័ត្នរហូតចេញផុតពីជំរុំនេះដោយសុវត្ថិភាពទៀតផង

អនិច្ចា ! កេសរវង្សី នៅឯមាត់ស្ទឹងឥតដឹងថាដាវមរតកបណ្តូលចិត្តរបស់នាង ត្រូវគេលួចយកបាត់ទៅហើយទេ ។ ទោះបីពេលដែលត្រលប់មកដល់ដំណេកវិញ ស្រីថ្លៃក៏ពុំបានដឹងថាដាវដែលស្ថិតនៅលើកន្ទេល ក្បែរខ្លួននេះជាដាវក្លែងក្លាយរបស់អាឃ្មីលចង្រៃឡើយ ។

ដោយយប់ងងឹត ចាក់ភ្នែកស្ទើរមិនយល់ មាណវីប្រាសប្រាណទៅលើកន្ទេល ហើយនាងស្រវាទៅចាប់ដាវលើកយកថើប ទើបបិទនេត្រាបណ្តោយខ្លួន ទៅតាមឥទ្ធិពលសំណាញ់មន្តនៃឋិនមិទ្ធ [(១)] ។

នាងគេងលក់ទៅយ៉ាងក្សេមក្សាន្ត តែលុះដល់ពេលមាន់រងាវឆ្លង-ឆ្លើយនាពេលទៀបភ្លឺ ស្រាប់តែគេឮ នាងកេសរវង្សីស្រែកឆោឡោឡើងថា ÷

- ជួយផង ! ជួយផង ! ដាវខ្ញុំបាត់ទៅណាហើយ ! ......

ព្រះបាទសាយណ្ហាវ័ន្តដែលគង់ក្នុងព្រះពន្លាពិសេស ជិតកន្លែងដំណេកនាង ទ្រង់តើនចាកព្រះក្រឡាបន្ទំ ។ ព្រះអង្គទ្រង់ស្ទុះក្រោកឡើងដោយហឫ-ទ័យញាប់ញ័រ. ជាមួយគ្នានេះទាហានទាំងអស់ បាននាំគ្នារត់ស្រមកដល់កន្លែងដែលផ្ទុះសំលេងប្រកបដោយសប្បដិភ័យនេះដែរ ។

---

(១) ដំណើរងោកងុយក្នុងដំណេក ។

ភ្លើងចន្លុះបានបញ្ចេញពន្លឺព្រោងព្រាត ។ ពេលនេះទាំងអស់គ្នា ងឿងឆ្ងល់យ៉ាងខ្លាំងចំពោះអាកប្បកិរិយារបស់កេសរវង្សី ។ ស្រីតន់ហួតដាវមកកាន់ដោយទឹកភ្នែករាប់លានតំណក់ហូរចុះមកច្រោកៗ លើទីលានថ្កាល់ទាំងគូ ។

ព្រះបាទសាយណ្ហាវ័ន្ន ទ្រង់យាងចូលទៅជិតនាងរួចទ្រង់ត្រាស់សួរថា÷

- កេសរវង្សី ! ដាវនាងនៅនឹងដៃទេតើ ម្តេចក៏ស្រែកថាបាត់ទៅណាវិញ អីចឹង ! .........

- ព្រះពរ ! នេះជាដាវក្លែងក្លាយទេ ! ដាវមរតករបស់ខ្ញុំម្ចាស់មានទ្រង់ទ្រាយមិនដូចដាវនេះទេ ! ...... គេលួចដាវខ្ញុំម្ចាស់ហើយ ជីវិតខ្ញុំម្ចាស់ពិតជាត្រូវរលាយបង់ក្នុងពេលនេះហើយព្រះអង្គ .......

ព្រះភូមិន្ទ្រទ្រង់ព្រះសង្ការយ៉ាងខ្លាំង ចំពោះប្រយោគរបស់កេសរវង្សី ព្រះអង្គទ្រង់សុំដាវពីដៃនាងយកមកពិនិត្យនឹងពន្លឺភ្លើង ទើបទ្រង់ត្រាស់សួរទៅកាន់នាងទៀតថា÷

- កេសរវង្សី ! ចំណុចត្រង់ណាដែលថាដាវនេះជាដាវក្លែងក្លាយ ! .....

តរុណីជោគជាំដោយជលនេត្រពេញវង់ភក្ត្រា ទូលព្រះនរបតីថា÷

- ព្រះពរ ! រាងដាវខ្ញុំម្ចាស់មិនកោងងរដូចដាវធ្វើអាយនេះទេ ! .......

ទាហានទាំងអស់ងឿងឆ្ងល់ណាស់ គេបែរមុខមើលគ្នាឡឺនឡង់ ។

- បើដូច្នេះ (ព្រះរាជាទ្រង់ត្រាស់) យើងចាប់គ្នាយើងទៅមើល ដាវនេះបើប្រាកដជាបាត់មែន គឺគ្មាននរណាក្រៅពីគ្នាយើងលួចទេ ។

មេកងឥឡូវប្រមូលទាហានអោយឈរជាជួរ ហើយហៅឈ្មោះភ្លាម ទើបបានដឹងថាបាត់នាយប្រុញ, នាយស្មោញ និងនាយឃ្មឹល ។

- ម៉េចបាត់គ្នាយើងខ្លះឬ លោកមេកង ?

ព្រះករុណាទ្រង់ត្រាស់សួរទៅលោកមេកង ។

- ព្រះករុណាថ្លៃវិសេស ! គ្នាយើងបាត់បីនាក់គឺ នាយឃ្មឹល, នាយស្មោញ និងនាយប្រុញ ដែលជាទាហានទើបតែសុំចូលមកថ្មីៗ ក្រាបទូល ! .......

- ហ៊ុះដាវរបស់កេសររង្សីបាត់មែន ឥឡូវយើងពុំអាចនៅតទៅទៀតបានទេ, យើងត្រូវរៀបចំចេញដំណើរពីនេះភ្លាមទៅទើបបាន ! ........

ទាហានទាំងអស់ក៏នាំគ្នារៀបចំប្រដាប់ប្រដា ដើម្បីចេញដំណើរទៅតាមព្រះរាជតម្រាស់ព្រះចមពល តែជាបន្ទាន់គ្នានេះភេរវសព្ទបានផ្ទុះឡើងជុំវិញជំរុំ ។

ព្រះបាទសាយណ្ហាវ័ន្តត្រាស់សួរទៅមេកង ដោយព្រះទ័យរំជើបរំជួល

- លោកមេកង ! សូរសព្ទសន្ធឹកអ្វីខ្លាំងម្ល៉េះ ?

- ក្រាបទូល ! សត្រូវចូលមកព័ទ្ធយើងហើយក្រាបទូល ! ......

- ចាប់អាវុធប្រយុទ្ធយកច្រករត់ដោះដៃភ្លាមគ្នាយើង ! .......

ព្រះករុណាទ្រង់ត្រាស់ដោយព្រះសូរសៀងអង់អាច ។

កញ្ញាកេសររង្សីស្រយុតចិត្តចំពោះព្រឹត្តិការណ៍ ដែលកំពុងកើតឡើងនេះយ៉ាងខ្លាំង ។ តរុណី ចាប់ដាវដែលគេដាក់បន្ទំមកអោយនាង ក្តាប់យ៉ាងណែនរត់ឡើងលើខ្នងសេះ ប្រមូលទាហានការពារសត្រូវដែលកំពុងសម្រុកចូល

មកយ៉ាងសាហាវ ។

- ទម្លាក់អាវុធចុះទាំងអស់គ្នាភ្លាមទៅ បើចង់រស់ឃើញពន្លឺព្រះអា-ទិត្យ ។

មេទ័ពម្នាក់របស់សត្រូវស្រែកបញ្ជាដល់កងកម្លាំងបដិវត្តន៍ ។ ព្រះករុណាទ្រង់ហួសព្រះទ័យ ចំពោះការដែលមកធ្លាក់ក្នុងក្រញាំសត្រូវយ៉ាងនេះណាស់ តែទ្រង់ព្រះចិន្តាថា បើនឹងទម្លាក់អាវុធចុះចាញ់សត្រូវ ក៏ជាការអាម៉ាស់មួយយ៉ាងធំក្រៃលែង ហើយបើពួកវាចាប់ទ្រង់បាន វាក៏ពុំប្រណីទុកព្រះជន្មព្រះអង្គទេ ។ ក្សត្រាខាំព្រះទន្តសង្កៀតយ៉ាងមាំ ទើបតបទៅវិញយ៉ាងក្លាហានថា÷

- យើងសុខចិត្តស្លាប់ជាជាងទម្លាក់ដាវអោយពួកឯង ដែលជាមនុស្សក្បត់ជាតិ ចាប់ខ្លួនយើង ! ...... ចូលកនយើង ! ចូលកុំរុញរា ! .......

គូបដិបក្សទាំងសងខាងក៏សម្រុករកគ្នា ដោយកាប់ឆ្ការប្រហារគ្នាយ៉ាងសាហាវ ។ ឆាកបង្ហូរលោហិតមួយបានកើតឡើង ព្រមគ្នានឹងពេលព្រះអារុណទើបចាប់បញ្ចេញព្រះវរកាយបំភ្លឺសត្វនិករ ។

ខាងខ្មាំងមានគ្នាច្រើនណាស់ ។ ពេលនេះគេសង្កេតឃើញក្រឡាសួបានបញ្ចេញខ្លួនដឹកនាំការឡោមព័ទ្ធនេះ ។ កញ្ញាកេសររង្សីឃើញមេក្បត់នេះភ្លាម ក៏ងាកទៅទូលព្រះបាទសាយណ្ហាវ័ន្តថា÷

- ព្រះអង្គ ! អាគាត់ដែលខ្ញុំម្ចាស់កាប់វាធ្លាក់ពីលើខ្នងកាលពីនៅក្នុងវាំង ឥឡូវមកទៀតហើយ ! ពេលនេះខ្ញុំម្ចាស់យល់ថា ព្រះអង្គគួរភៀសព្រះកាយយាងគេចចេញពីនេះភ្លាមទៅ ! ចំណែកខ្ញុំម្ចាស់ទៅតាមក្រោយព្រះអង្គ !

- ទេ ! កេសររង្សី ! ខ្ញុំមិនដាច់ចិត្តរត់ចោលនាង និងកូនទាហានទាំងអស់គ្នាទេ !

ព្រះករុណាទ្រង់ត្រាស់ដោយព្រះទ័យរារែក ។

- ការសំខាន់មិនមែនស្ថិតលើចំណុចនេះទេក្រាបទូល ! ....... បើពេលនេះស្លាប់កូនទាហានប៉ុណ្ណេះ នោះក៏មិនជាការអ្វីដែរទេ ! អោយតែព្រះអង្គគង់ព្រះជន្ម ! ចុះបើអត់ពីព្រះអង្គទៀត តើសុវណ្ណភូមិនឹងត្រូវធ្លាក់ទៅដល់ណា ?... យាងចុះតាមស្ទឹងនេះភ្លាមទៅក្រាបទូល !

តរុណីពោលបង្ខំព្រះករុណា តែព្រះអង្គព្រះពុំព្រមសោះ ។ ទ្រង់គិតតែពីញាក់ព្រះទីនាំងអស្សតរ ចូលមកជួយប្រយុទ្ធកូនទាហានទៅវិញព្រងើយ លោកមេកងឃើញថា ឱកាសនេះពិតជាពុំអាចកែគេចខ្លួនពីក្រញ៉ាំសត្រូវបាន ក៏បកសេះចូលមកទូលព្រះករុណាថា ÷

- ព្រះអង្គយាងតាមស្ទឹងនេះភ្លាមទៅ ! ក្រាបទូលកុំគិតពីទូលបង្គំទាំងអស់គ្នាអោយសោះ ! បើព្រះអង្គបណ្តោយឱ្យសត្រូវចាប់ព្រះអង្គបាន សុវណ្ណ-ភូមិនឹងត្រូវរលាយហើយក្រាបទូល ។

- ទេ ! លោកមេកង ! រកឈានជើងចេញចោលមិត្តរួមអាវុធរបស់ខ្ញុំមិនបានទេ ! .....

- យាងភ្លាមទៅព្រះអង្គ ! ពួកយើងស្លាប់អស់ក្រែលណាស់ហើយ ។

កេសររង្សីតឿនដោយទឹកមុខព្រួយបារម្ភ ។ តែព្រះករុណាទ្រង់ពុំដាច់ព្រះទ័យយាងចេញទៅសោះ ។

- បើព្រះអង្គពុំព្រមយាងទៅទេ ខ្ញុំម្ចាស់នឹងអារកធ្វើអត្តឃាតហើយ

ព្រះករុណា ទ្រង់ព្រះសណ្ដាប់ការសម្រេចរបស់តរុណីជាទីស្នេហា ដូច្នោះ ទ្រង់ក៏ព្រមយាងចេញពីសមរភូមិភ្លាម ។

- ខ្ញុំសូមលាសិនហើយ អ្នករាល់គ្នា ! .......

យើងរីករាយពន់ប្រមាណ កាលដែលឃើញព្រះចមពលទ្រង់សុខចិត្ត យាងភៀសព្រះអង្គចេញពីសមរភូមិ ។ ទាហានទាំងអស់បានធូរទ្រូង ផុតក្ដីកង្វល់គ្រប់គ្នា ។ យើងបាននាំគ្នាចូលមកប្រយុទ្ធជាមួយខ្មាំងគ្មានស្ដាយជីវិត ។ ក្រឡាសូក្រឡេកឃើញកញ្ញាកេសរវង្សីភ្លាម ត្រេកអរណាស់ ។ គាត់នេះញ្ជាក់សេះជិះជ្រែកហ្វូងទ័ពចូលមកជិតនាង ទើបបោះសំដីផ្អែផ្អាថា ÷

- អូរ៎ា ! សួស្ដីនាង ! ថ្ងៃនេះខ្ញុំមិននឹកស្មានថាមានភ័ព្វបានជួបមុខនាងសោះទេ ! .......

នេះជាសំណាងខ្ញុំហើយ ! ......

ឆោមស្នេហ៍ ឆេះឆួលក្នុងឱរាយ៉ាងខ្លាំង នឹងពាក្យសឹកសៀតរបស់ព្រានកញ្ចាស់នេះ នាងពេបមាត់ចំអកអោយបន្តិច ទើបវីធដាវកាប់ផាំងទៅលើជនក្បត់នេះ ។ តែវាបានរងមុខអាវុធនាងជាប់ ទើបនាងចោលសំដីតបទៅវាវិញថា ÷

- អូ ! លោកនៅរស់នៅឡើយទេ ! ខ្ញុំស្មានតែលោកស្លាប់បាត់តាំងពីយប់រដ្ឋប្រហារទៅហើយតើ !

- ក្រឡាសូ ! មិនងាយស្លាប់ផ្ដេសផ្ដាសទេ ! ជីវិតវាមច្ចុរាជសុំខ្លាច

ណាស់ !

ក្រឡាសូពោលបែបកំប្លែង ។

- ចាំ ! មែនហើយ តែបើកាលនោះខ្ញុំកាប់ថែមពីរបីដាវចំកន្លែងល្អ ទៅទៀត ប្រហែលជាលោកត្រឡប់ជាសុំខ្មាសមច្ចុរាជវិញទេមើលទៅ ! .....

ធីតាពោលចប់ក៏កាប់គាត់នេះទៀត តែគ្រប់ដំណើរក្បាច់អាវុធរបស់នាង ក្រឡាសូបានរងជាប់ទាំងអស់ ហើយឆាកប្រយុទ្ធនេះគួរអោយចង់គយគន់ណាស់ ។ មេជនក្បត់នឹកឃើញថា កាលពីជួបនាងនៅពេលរដ្ឋប្រហារ ដាវរបស់នាងជាដាវមានពន្លឺរស្មីយ៉ាងប្លែក ចុះម្តងនេះម្តេចក៏គ្មានឃើញពន្លឺអ្វីសោះ គេក៏យល់ភ្លាមថា ដាវនាងច្បាស់ជាត្រូវអ្នកយកការសម្ងាត់របស់គេលួចបានហើយ ។

- ម៉េចទៅនាង ! គ្មានដាវជ័យសិទ្ធិ នាងដូចជាមិនសូវធ្វើអោយគេឯងចាប់អារម្មណ៍នឹងក្បាច់អាវុធនាងសោះ !

ណ្ហើយនាងអើយ ស៊កដាវទុកទៅវិញទៅ មើលហ្ន៎កូនទាហានរបស់នាងស្លាប់ជិតអស់ទៅហើយៗ រូបរាងនាងស្អាតម្លឹងៗ ព្រមទាំងវ័យនៅខ្ចីដូចនេះទៀត ខ្ញុំមិនដឹងជាមកចងពៀរវេរា យកឈ្នះពីនាងដូចម្តេចទៅរួចទេ ! ......

ក្រឡាសូពោលដោយទឹកមុខញញឹម ហើយប្រហែសខ្លួន ។ កេសររង្សីដឹងថា គាត់នេះប្រាសចាកការប្រុងប្រយ័ត្នហើយ ក៏លួចប្រើល្បិចកាប់ផាំងយ៉ាងធ្ងន់ ត្រូវកំភួនដៃមេក្បត់នេះ ។ ឈាមក៏ហូររ៉ាវចេញមក ។

- យី ! មេចង្រៃ កាប់អញផងតើ !

ក្រឡាសូពោលដោយភ្ញាក់ខ្លួន ។

កេសររង្សី ត្រេកអរណាស់ នាងអស់សំណើចបន្តិចទើបឆ្លើយថា ÷

- ពុទ្ធោ ! ខ្ញុំមិននឹកស្មានថា ខ្ញុំបានមកចងពៀរនឹងលោកដោយមុខដាវនេះទៀតទេ ! ..........

- មេស្រីចង្រៃ ! អញកាត់ក្បាលឯងហើយពេលនេះ ។

ខ្លាចាស់ត្រូវរបួស ក្រោធយ៉ាងខ្លាំង វាស្ទុះចូលមកកាប់តរុណីយ៉ាងសាហាវ ប្រៀបបាននឹងរលកព្យុះសមុទ្រ ។

ស្រស់និមលពិតមែនជាស្ត្រីភេទ តែភ្លេងអាវុធរបស់នាងមានល្បិចគួរអោយស្ញើចពន់ប្រមាណ គ្រប់ដំណើរវាយដណ្តើមយកជ័យជំនះពីនាង នាងបានរងកាត់បានទាំងអស់ ដោយកាប់សងយ៉ាងរហ័ស ធ្វើអោយក្រឡាស្វូបុកពោះម្តង១ដែរ ។

នាយប្រុញ ឃើញដំណើរការមិនសូវល្អ កំពុងគ្របសង្កត់លើរូបក្រឡាស្វូ ក៏ញោក់សេះចូលមកជួយតយុទ្ធគាត់ ។ កេសររង្សីឃើញមុខវាភ្លាមក៏ស្គាល់ច្បាស់ថា ជាអ្នកបានមកបន្លំខ្លួនយកការសម្ងាត់ពីកងទ័ពបដិវត្តន៍ និងបានលួចដាវជ័យសិទ្ធិរបស់នាងផង នាងក៏និយាយថា ÷

- ឃើ ! អាប្រុញ ឯងជាមនុស្សក្បត់បន្លំខ្លួនចូលមកបំផ្លាញគម្រោងការណ៍បដិវត្តន៍ដ៏ថ្លៃថ្លាទេតើ ! ឯងលួចយកដាវអញទៅទុកឯណា ? .....

- ដាវនាងឯង (ប្រុញតប) យើងមិនដឹងទេ ! .......

- ឯងមិនដឹង ? ណ្ហើយស្លាប់ទៅអាចង្រៃ ! .......

តរុណីបញ្ចប់ប្រយោគនេះ ហើយក៏ប្រើចុងដាវទៅទម្លាយផ្ទាំងទ្រូង

នាយប្រុញអប្បលក្ខណ៍គ្មានមេត្តា ។ ជនក្បត់របូតដាវពីដៃ របេះខ្លួនធ្លាក់ពីលើខ្នងសេះមកដី មច្ចុរាជក៏ក្រញីយកជីវិតវាទៅចោលនៅស្ថាននរកអវិចីមួយរំពេច

- ទាហានចូលព័ទ្ធចាប់មេស្រីចង្រៃនេះអោយបាន ........... (ក្រឡាសូហៅទាហាន)

ពេលនេះទាហាន ១០ នាក់ បានចូលមកចោមរោមវីរកញ្ញាយើងជិតជុំ ។

កល្យាណីក្នុងខណៈនេះ នៅសល់តែទឹកចិត្តក្លាហានប៉ុណ្ណោះទេ ដែលជម្រុងញនាងអោយលើកដាវឡើងធ្វើការតស៊ូទល់នឹងបច្ចាមិត្ត ។

ចុះបើនាងហេវហត់អស់កំលាំងណាស់ទៅហើយ ហើយគ្មានដាវជ័យសិទ្ធិទៀត តើនាងអាចប្រមូលយកជ័យជំនះពីពួកនេះបានទេ ? ........

អនិច្ចាអើយ ! កេសររង្សីអស់សមត្ថភាពគ្រប់យ៉ាងហើយ មើលចុះនាងរបូតដាវពីកញ្ចប់ដៃទៅហើយ ។ ទាហាននៃពួកក្បត់ឃើញដូច្នេះ ក៏ស្រែកហ៊ោកញ្ជ្រៀវចូលមកផ្ទង់អាវុធចាប់នាងចងភ្ជាម ។

ពេលនេះ បើយើងក្រឡេកមកមើលទាហានបដិវត្តន៍វិញ យើងគ្មានឃើញសល់អ្នកណាម្នាក់ មានជីវិតរស់នៅលើសមរភូមិក្រៅពីនាងកេសររង្សីឡើយ ។ ក្នុងថ្លុកលោហិត មិត្តយើងបានរំលាងខន្ធទៅយ៉ាងថ្លៃថ្នូរ ........ ។

ក្រឡាសូ កាលបើបានដឹងថាពួកគេបានទទួលជ័យជំនះហើយក៏ចាត់គ្នាអោយរកមើលព្រះបាទសាយណ្ហាវ័ន្ន ក្រែងទ្រង់បានរំលាងខន្ធ ដោយមុខអាវុធរបស់ទាហានក្បត់ណាម្នាក់ ។ តែគេរកពុំឃើញព្រះអង្គសោះ ព្រោះព្រះអង្គ

បានភៀសព្រះកាយចេញផុតពីសមរភូមិយូរក្រៃលបាត់ទៅហើយ ។

ក្រទ្បាស្ទូ ក្តៅក្រហាយណាស់ ដែលព្រះបាទសាយណ្ហវ័រ្មន ទ្រង់អាច យាងភៀសព្រះអង្គចាកផុតពីក្រញាំពួកគេបានក្នុងលើកនេះតទៅទៀត ។ គេ បន្ទោសកូនទាហានគេយ៉ាងខ្លាំង ។

- ពួកយើងបានទទួលជោគជ័យមែនហើយ ! តែខ្ញុំមិនសរសើរទេ ព្រោះចាប់ព្រះបាទសាយណ្ហវ័រ្មនមិនបាន ! ឥឡូវរៀបចំនាំគ្នាត្រឡប់ទៅវិញ ។

# ៩

# ប្រតិកម្មស្នេហា

ព្រះបាទសាយណ្ហាវ័ន្ន កាលទ្រង់យាងមកដល់បន្ទាយគោកធ្លកភ្លាម ទ្រង់បាននាំកងទ័ពបដិវត្តន៍ មួយចំនួនធំមកកាន់កន្លែងរងគ្រោះថ្នាក់ ដើម្បីជួយព្រះរាជបរិពារដែលត្រូវទាហានរបស់រាមរាជ្យ ដឹកនាំដោយក្រឡាសូលបចូលមកព័ទ្ធវាយប្រហារ ។

នៅទីនោះ ទិដ្ឋភាពដ៏តក់ស្លុតបានកន្ត្រាក់ទងប្រមាត់បេះដូងយើងរាល់គ្នាយ៉ាងខ្លាំង ។ មើលចុះ ! សាកសពទាំងអស់ដែលនៅដេកស្តូកស្តឹង ក្នុងថ្លុកលោហិត ប្រកបដោយក្លិនឆ្អាបគឺសុទ្ធសឹងជាមិត្តរួមអាវុធរបស់យើង ។

- ពុទ្ធោ ! ពួកយើងស្លាប់ទាំងអស់ ! កេសររង្សីប្រហែលវាចាប់យកបាត់ទៅហើយ ........

ព្រះប្រមុខកងទ័ពបដិវត្តន៍ ទ្រង់លាន់ព្រះឱស្ឋដោយបង្ហូរព្រះអស្សុជលមកជាមួយផង ។

កងទ័ពបដិវត្តន៍ បាននាំគ្នាឈរស្ងឹងស្ងាធី មួយរយៈពេលយ៉ាងតូច គោរពចំពោះវិញ្ញាណក្ខន្ធ អ្នកដែលបានបាត់បង់ជីវិតលាចាកលោកយើងទៅ ទើបចូលទៅរើសសាកសពនាំយកមកបន្ទាយ ដើម្បីចាត់ចែងធ្វើបុណ្យបញ្ចុះទៅតាមប្រពៃណីជាតិ ។

ពន្លឺត្រជាក់នៃព្រះសុរិយា បានក្លាយទៅជាពិសដ៏ក្តៅទៅហើយ ពួកអ្នកបដិវត្តន៍ កាលប្រមូលសាកសពបានគ្រប់ចំនួនហើយ ក៏ត្រឡប់មកបន្ទាយគោកធ្លកវិញយ៉ាងសោករន្ធត់ ។

ចំពោះព្រះបាទសាយណ្ហាវ័ន្ទវិញ ការបាត់បង់ជីវិតកងទ័ពរបស់ទ្រង់ និងការបាត់ខ្លួននៃកញ្ញាកេសរវង្សី បានធ្វើអោយព្រះអង្គទ្រង់វិយោគទុក្ខ ជាភិយ្យោភាព ។

សូមបែរមកជួបកញ្ញាកេសរវង្សីម្តង ។

កាលដែលមកដល់ទីក្រុងក្រឡាសូ ពុំបានបញ្ជូនកញ្ញារងគ្រោះយើងមកអោយរាមរាជ្យតាមរយៈច្បាប់ទេ គេយកនាងមកទុកក្នុងបន្ទប់មួយនៅក្នុងគេហស្ថានរបស់គេ ។

ព្រះប្រភាករ ក្រោយដែលបានរែកពុនសំពាយកម្មលោកិយ៍អស់រយៈពេលពេញមួយថ្ងៃគត់ ក៏បានយាងចូលសន្និប្រកាសចាកចោលលោកយើងនេះទៅ ទុកអោយព្រះច័ន្ទ និងដួងតារារាប់ពាន់នៅកំព្រាជាមួយសត្តនិករ ។

សត្វចង្រិត ឥតវាសនាស្រែកយំច្រេកៗ ហែកតុណ្ហីភាពឥតដាច់សូរព្រឹក្សាថ្ងូញថ្ងូរបោកប្រាណខ្សឹកខ្សួលឆ្លើយឆ្លងគ្នាក្នុងលំហសមុទ្ររាត្រី គួរអោយសង្វេគ មិនខុសគ្នាពីកញ្ញាកេសរវង្សីដែលកំពុងតែរងទុក្ខ ដោយសារការឈ្លានពានយ៉ាងខ្មៅក្រខ្វក់របស់ក្រឡាសូឡើយ ។

ក្រោមពន្លឺទៀនដែលឆេះបញ្ចេញរស្មីព្រឹមៗ នាងរត់ឆ្វេឆ្វាចុះឡើង

ពេញក្នុងបន្ទប់ គេចខ្លួនចេញពីកណ្ដាប់ដៃរបស់ព្រានចាស់ ។

តែបន្ទប់មានទីតូច ពុំអាចអោយនាងនាថគេចទៅណាបានដូចបំណង ឡើយ នាងហ៉ៅវហត់ណាស់. ទឹកញើសត្រជាក់ប្រាណនាង ។ ក្រឡាសូរត់តាម ចាប់នាងដោយទឹកមុខញញឹម វាបន្លឺពាក្យលួងលោមនាងថា ÷

- អូនរត់ទៅណាក៏មិនរួចដែរ នៅស្ងៀមទៅល្អជាង ! បងស្រលាញ់ អូនណាស់ ! .......

- អាតិរច្ឆាន ! អញមិនស្រលាញ់អាឯងទេ ! អាឯងសម្លាប់អញទៅ វិញទៅ អញសប្បាយជាងចំណាយខ្លួន ជាចំណីអារម្មណ៍របស់អាឯងណាស់ ។

ធីតាពោលដោយបោះជំហានថយក្រោយសន្សឹមៗ ។ នាងបើកភ្នែក ប្រកបដោយអាការភ័យតក់ស្លុត មើលក្រឡាសូដែលចេះតែរំកិលខ្លួនចូលមក ចាប់នាងឥតអាណិតអាសូរ ។

ភ័យណាស់ ! ដោយនាងទល់ខ្នងនឹងជញ្ជាំងទៅហើយ ។ មិនដឹងគិត ដូចម្ដេច ដើម្បីដោះខ្លួនអោយបានផ្លូងផុតពីគ្រោះកាចនេះបាន គេសរវង្សីក៏ ត្រឡប់ជាពោលពាក្យអង្វរក្រឡាសូ ដោយសំដីផ្អែមត្រជាក់ទៅវិញ ។

- លោក ! សូមកុំធ្វើបាបខ្ញុំ ខ្ញុំភ័យណាស់ ! .......

- អូនភ័យ ! (ក្រឡាសូញញឹម) កុំភ័យធ្វើអ្វីអូន បងមិនធ្វើបាបអូន ទេ ! អូនភ្លេចឬនៅពាក្យដែលបងបានប្រាប់អូនថា បងស្រលាញ់អូន !

- ចាំ ! សូមលោកមេត្តាកុំស្រលាញ់រូបខ្ញុំធ្វើអ្វី ខ្ញុំនៅក្មេងណាស់ ! .....

- ហាំ ! ហាំ ! នៅក្មេង ? នាងពេញក្រមុំស្អាតដល់ទៅម្លឹងទៅហើយ នៅមិនទាន់ដឹងខ្លួនទៀតឬ ? អូនព្រមស្រលាញ់បងធ្វើជាប្ដីទៅ បងនឹងថ្នាក់ថ្នម អូន លើកតំកើងអូនតាមចិត្តអូនប្រាថ្នា .......

ស្រស់នារីមិនទាន់ទាំងឆ្លើយតបដូចម្ដេចនឹងប្រយោគនេះផងក្រឡាសូ បានចូលមកក្រសោបឱបអង្គប្រាណនាងជាប់ ។ នារីកំព្រាភ័យញ័រអស់អង្គកាយ ប្រឹងរើបម្រះចេញពីការឱបរឹតនេះ តែគួរឱ្យសរសើរមេក្បត់ជាតិនេះដែរ ពិត មែនតែដៃរបស់វាម្ខាងត្រូវរបួសមិនទាន់ជានៅឡើយក្ដី ក៏កម្លាំងដៃម្ខាងរបស់ វាអាចក្រសោបឱបប្រាណនាងបានជាប់ដូចបំណង ។

កេសររង្សីមិនដឹងគិតដូចម្ដេចនឹងគេចចេញពីច្រមុះ របស់សត្រូវ ដែល លុតចូលមកក្រេបរសជាតិពីផែនថ្ពាល់របស់នាងបាន ក៏បណ្ដោយខ្លួនសម្ងំយក ស្ថានភាព វាយបម្រះយករួចខ្លួនអោយបានប្រសិទ្ធិភាព ។ ក្រឡាសូបានចិត្ត ព្រោះឃើញនាងនៅស្ងៀម បណ្ដោយប្រាណអោយវាឱបរិតថៃថើបតាមចិត្ត ក៏ ទុកចិត្តបោះបង់ការប្រុងប្រយ័ត្នអស់រលីង ។

កេសររង្សីឃើញថាឱកាសប្រសើរបានចូលមកហើយ ក៏ស្ទុះមកចាប់ ដៃដែលត្រូវរបួសរបស់ក្រឡាសូជាប់ ទើបមួលយ៉ាងខ្លាំង ។

ក្រឡាសូឈឺណាស់ វាស្រែករោទិ៍ពេញក្នុងផ្ទះ ធ្វើអោយទាហានទាំង ឡាយភិតភ័យរត់ចូលមកជួយជាបន្ទាន់ ។

ទ្វារដែលបិទជិតត្រូវទាហានអង្គរក្សទាត់ក្ដាំង ! ក្ដាំង ! លុះត្រាតែ

របើកឡើង ។

- ជួយអញផង ! ជួយអញផង ! វាកាច់ដៃបាក់ឥឡូវហើយ .......

ក្រំឡាស្ងូប្រាប់ទៅទាហានដែលរត់មកជួយ ។

មិនបង្អង់ ពួកនេះនាំចូលមកចាប់ដៃកេសររង្សីច្របាច់ លុះត្រាតែនាងពុំអាចមួលដៃក្រឡាសូតទៅទៀតកើត ។

ក្រឡាសូបានរួចពីគ្រោះថ្នាក់ធូរទ្រូងយ៉ាងខ្លាំង តែការឈឺចាប់បានធ្វើអោយជនជរានេះក្តៅក្រហាយណាស់ ។

- ពួកអាឯងប្រដៅច្បាប់ ឱ្យមេស្រីចង្រៃនេះឱ្យដឹងម្តងទៅមើល៍ ! ហេតុដូចម្តេចបានជាវាមកមួលដៃអញអោយឈឺសឹងងាប់យ៉ាងនេះ ! ......

ពួកអាមាត្រដៃដល់របស់ក្រឡាសូ ឥតប្រណីស្រីរងគ្រោះឡើយ ។ វានាំគ្នា ទះតប់ ទាត់ធាក់ នាងយ៉ាងដំណំ លុះត្រាតែនាងសន្លប់បាត់ស្មារតី ។

- អើអោយវាស្លាប់ទៅចុះ ! មេស្រីចង្រៃ បានគេស្រលាញ់បានចិត្តណាស់ ! ទាល់តែឈឺខ្លួនអីចឹងបានសមមុខ នែៗ ! ពួកឯងនាំគ្នាយកវាទៅថ្វាយព្រះអង្គរាមរាជ្យភ្លាម ! ថាវានេះហើយដែលមានដាវជ័យសិទ្ធិ ជាអ្នកមករំដោះព្រះបាទសាយណ្ហាវ័ន្ទកាលពីរដ្ឋប្រហាររបស់យើងនោះ ........

ទាហានគោរពតាមបញ្ជា ក៏នាំកញ្ញាអភ័ព្វ ដែលសន្លប់ឥតដឹងខ្លួនចេញពីបន្ទប់មួយរំពេច .......

យប់មិនទាន់ជាជ្រៅណាស់ណានៅឡើយទេ ។ ពេលថ្មើណោះ នៅក្នុង

ក្រឡាបន្ទំរបស់រាមរាជ្យ សំលេងតន្ត្រីកំពុងបើកបទយ៉ាងពិរោះរងំ ។

នៅលើគ្រែមាស រាមរាជ្យទម្រេតខ្លួនច្រត់ទៅលើខ្នើយដ៏វិចិត្រ។ គ្រាប់ភ្នែកសំលឹងមើលទៅនាដការី ដែលកំពុងពត់ពេនកាយរេរាំបំពេញចិត្តគេ

នាងទាំងនេះជានារីក្រមុំមានរូបឆោមស្រស់ខ្ចីល្អក់ រាងកាយគ្រប ដណ្តប់ដោយស្បៃយ៉ាងស្តើង១ ។ រាមរាជ្យ ជាមហាចោរកំពូលទាសាកាមគុណ វាចូលចិត្តអោយនាដការី បញ្ចេញរាងកាយស្ទើរអាក្រាតបែបនេះណាស់ ។

ពន្លឺភ្លើងឆេះព្រោងព្រាត. បទភ្លេង និងចម្រៀងកំពុងតែលាន់ឮរំពង ដឹកនាំចង្វាក់នាដកម្ម អោយប្រព្រឹត្តទៅយ៉ាងក្បេមក្សាន្តនៅក្នុងតំណាក់ ។

ស្រាប់តែពេលនេះទាហានម្នាក់ ចូលមកលុតជង្គង់ឱនមុខចំពោះមុខ រាមរាជ្យ រាយការណ៍ថា ÷

- បពិត្រព្រះចមភពកំពូលក្រុងសុវណ្ណទាំងមូល ! នារីម្នាក់ដែលមាន ដាវជ័យសិទ្ធិ ហើយជាអ្នករំដោះស្តេចសាយណ្ហាវ័ន្ន ចេញពីវាំងកាលពីរាត្រីរដ្ឋ ប្រហារ ឥឡូវត្រូវលោកមហាឧត្តមសេនាក្រឡាសូចាប់បានបញ្ជូនយកមកថ្វាយ ព្រះអង្គហើយ ក្រាបទូល ! ........

រាមរាជ្យញញឹមចំពោះដំណឹងដ៏ល្អនេះ ទើបសួរផ្ទួនពាក្យដែលដឹងមក ហើយថា ÷

- ចាប់នាងដែលមានដាវជ័យសិទ្ធិ បានហើយ ? ..... ហាំ ! ហាំ ! នាំ យកមកអោយយើងមើលមុខវាភ្លាម ! ....... យើងចង់ស្គាល់ណាស់ ! ........

ពួកភ្លេង, អ្នកចម្រៀង និងស្រីរបាំបានបញ្ឈប់ការសំដែងភ្លាម ហើយដកខ្លួនចេញពីនេះមួយរំពេច ។ ចំណែកកេសររង្សីក៏ត្រូវគេបញ្ជូនយកមកនៅចំពោះមុខរាមរាជ្យ ។

អ្នកគ្រប់គ្រងរាជសម្បត្តិ នៅលើបល្ល័ង្ករាជព្រះបាទសាយណ្ហាវ៉ុន មិនបានមើលមុខកញ្ញាយើងទេ, ព្រោះនាងឱនចុះពុំព្រមងើបទទួលវាសោះ, រាម-រាជ្យក្ដៅឆេះឆួលក្នុងទ្រូងដូចគេយកភ្លើងមកដុតពេល ក៏ស្រែកគម្រាម កេសររង្សីថា ÷

- នែ ! ស្រីចង្រៃ ! ទីបំផុតនាងបានចូលខ្លួនក្នុងក្រញាំយើង ! .......... នាងងាកមុខមកមើល៍ !

កេសររង្សីហាក់ដូចភ្ញាក់ពីការសន្លប់ នាងងើបមុខមើលមកម្ចាស់សម្លេងនេះ ដោយឃ្នាន់ខ្នាញ់ ។

រាមរាជ្យយល់ជាក់រង់ភ័ក្ត្រនាង ក៏រំជើបរំជួល ញាប់ញ័រក្នុងដួងចិត្តយ៉ាងខ្លាំង ។ ភ្លើងកំហឹងបានរលត់បាត់បង់ទៅមួយរំពេច ដោយសារឥទ្ធិពលនៃទឹកមន្តស្នេហ៍ ដែលព្រះកាមទេពជាម្ចាស់បានស្រោចស្រពប្រោះព្រំទៅលើដួងចិត្តបុរសនេះ ។ គាត់នេះ ប្រែទឹកមុខពីក្រញូវមកជាញញឹម ហើយប្រឹងសម្លឹងមើល ស្រីអភ័ព្វជាប់ចំណងនេះដោយការចូលចិត្តយ៉ាងចម្លែក ។

- ស្រស់ណាស់នាងកញ្ញា ! ពេលនេះបើនាងញញឹមបន្តិច ជាជំនួសទឹកមុខមាំកាច ខ្ញុំប្រហែលជាស្លាប់នៅលើគ្រែមាសនេះហើយ ! នាងឈ្មោះអ្វីទៅ !

- យើងឈ្មោះកេសររង្សី ! គាត់ឯងសួរមានការអី ! .......

កេសររង្សីឆ្លើយកំបុតៗ ។

- ហាំ ! ហាំ ! សម្លេងគម្រោះគម្រើយប៉ុណ្ណេះ ក៏នៅតែមានសភាពជាតន្ត្រីទិព្វដែរ ! ....... យើងសួរឈ្មោះនាង គ្មានប្រាថ្នាអ្វីក្រៅពីចង់ស្គាល់ទេ ! .... ទាហាន (រាមរាជ្យបែរទៅនិយាយអោយសេនាមាត្យ) កាត់ស្រាយចំណងឱ្យនាងភ្លាម ហើយនាំនាងយកទៅអោយយាមអករៀបចំផ្ងូតទឹក តាក់តែងកាយអោយភ្លាមៗ ទៅ ! .......

ទាហានដែលនាំនាងមកពីផ្ទះក្រឡាសូ យកមកកាន់ទីនេះ គឺជាអ្នកដែលបានវាយធ្វើបាបនាង ។ លុះឮរាមរាជ្យសំដែងអាការៈទន់ភ្លន់ ខុសប្លែកពីអ្នកទោសទូទៅ ដែលចាប់បានយកមកអោយសំរេចទោស វាងឿងឆ្ងល់ហើយនាំគ្នាលួចភ័យស្រៀវក្នុងខ្លួនយ៉ាងខ្លាំង ។

គេនាំគ្នាកាត់ចំណងដៃអោយនាង ហើយក៏នាំនាងយកទៅប្រគល់ឱ្យយាយអកភ្លាម ដើម្បីប្រញាប់ប្រញាល់នាំគ្នាភៀសខ្លួន ចេញពីកន្លែងនេះទៅវិញដោយខ្លាចកើតហេតុមិនស្រួល ។

ចំណែកយាយអក ការដែលផ្ងូតទឹកតាក់តែងកាយអោយនាងកេសរ-រង្សីហើយ ក៏នាំនាងយកមកកាន់កន្លែងរបស់រាមរាជ្យ ។

ប្រមុខពួកក្បត់ ឃើញនារីអភ័ព្វមានរូបឆោមស្រស់បវរមកដល់ ក៏ស្ទុះក្រោកឡើង ដោយទឹកមុខញញឹមរីករាយ ។

ភ្លើងស្នេហ៍បានដុតរោលទងបេះដូងគាត់យ៉ាងខ្លាំង ។

- អង្គុយលើគ្រែនេះមកនាង ! .......

រាមរាជ្យនិយាយដោយកិរិយាទន់ភ្លន់ ។ កេសរវង្សី ស្គាល់អាកប្បកិរិយាលាក់ក្រចកយ៉ាងក្រខ្វក់នេះ ក៏តបដូចឥតដឹងខ្លួនអ្វីសោះថា ÷

- ចាំ ! អរគុណណាស់ ! តែកន្លែងនេះមិនសមឋានៈខ្ញុំមកអង្គុយទេ !

- ទេ ! នាងគ្មានទាស់អ្វីទេ ! អង្គុយមក !

កេសរវង្សីធ្វើអេះអុញដូចជាខ្លាចចិត្តរាមរាជ្យ ដើម្បីស្ទង់ជំរៅចិត្តមេជនក្បត់នេះតទៅទៀត ។ រាមរាជ្យឃើញអាកប្បកិរិយានាងដូច្នេះ ក៏សរសៀរចូលជិតចាប់ដៃនាងគ្មានរអែង ។

- អង្គុយលេងជាមួយបងមកអូន ! .......

បុត្រីខ្មោចអ្នកឧកញ៉ារក្សាខ័ណ្ឌជំនិតភក្តី បុកពោះនឹកខឹងមួយរំពេចតរុណីរលាស់ដៃចេញពីចោរព្រាននេះ ទើបទះកំភ្លៀងវាមួយដៃយ៉ាងខ្លាំង ។

- ហ៊ុះ ! អាចង្រៃ ! ឯងចង់បួន់ព្រហ្មចារីយ៍គេឬ ? ណ្ហើយកុំសង្ឃឹមអញសុខចិត្តស្លាប់ល្អជាជាង អាចង្រៃ ! ........ ឯងកុំស្មានថាអញស្រលាញ់ខ្លួនអោយសោះ ! ........

ត្រូវមួយកំភ្លៀង មហាចោរភ្ញាក់ចិត្តនឹកក្តៅឈ្លួលមួយរំពេច។ ទឹកមុខធ្លាប់ញញឹមក៏ក្លាយជាកាចសាហាវមួយខណៈ ។

ពេលនេះ វារំពងសំលេងដូចជាផ្គរលាន់ដើមឆ្នាំសន្ធាប់ទៅនាងថា ÷

- យើ ! មេស្រីចង្រៃ ! ឃើញអញស្រលាញ់បានចិត្តផងឬ ? ឥឡូវ អញសូមសួរថា : ស្លាប់ និងព្រមទទួលអញជាប្ដីហាងឯងទទួលយក ! មុខណា?

- ព្រមទទួលធ្វើជាប្ដី ? ឆ្វើយ ! (នាងពោលដោយស្ដោះទឹកមាត់) មនុស្សក្បត់ជាតិជិះជាន់ពន្លិចជាតិ អោយប្រទះនូវការបែកបាក់សាមគ្គី អញមិន ព្រមស្រលាញ់ឡើយ អញសុខចិត្តស្លាប់ប្រសើរជាជាង ! .......

- សុខចិត្តស្លាប់ ! ហាំ ! ហាំ ! ស្លាប់វាងាយទេ ........

- អើ ! សម្លាប់អញមក ! ឯងចង់ទុកអញធ្វើជាប្រពន្ធធ្វើអ្វី ! សូមកុំ ភ្លេចអោយសោះថា : កងបដិវត្តន៍គ្រប់រូបមិនខ្លាចស្លាប់ដើម្បីជាតិទេ ! ការ ស្លាប់ដោយបំរើជាតិ គឺជាករណីយកិច្ចមួយដែលយើងគ្មានរុញរា !

រាមរាជ្យហួសចិត្តមិនដឹងគិតដូចម្ដេច ព្រោះទឹកចិត្តនៅតែជំពាក់ចង់ បាននាងធ្វើជាភរិយា ក៏ត្រឡប់ជានៅស្ងៀមរិះគិតក្នុងចិត្តទៅវិញ ។ កេសររង្សី យល់ថាឱកាសនេះ នាងមិនអាចគេចខ្លួនទៅណារួចពីក្រញាំសេចក្ដីស្លាប់ឡើយ ក៏ងាកមើលទៅជុំវិញខ្លួន ប្រុងរាវរករបស់អ្វីមួយមកសងសឹកចំពោះមេក្បត់នេះ ដើម្បីអោយបានអស់ចិត្ត បំណាច់មុននឹងគេប្រហារបង់ ។

នុ៎ះ ! កាំបិតមួយនៅលើក្បាលគ្រែយ៉ាងសង្ហា ។ ត្រេកអរណាស់មិត្ត នារីបដិវត្តន៍យើងក៏រំលៀកខ្លួនមករកអាវុធនេះ ។

មកដល់ដូចប្រាថ្នាហើយ នាងកន្ត្រាក់យកមកក្ដាប់យ៉ាងណែន ហើយ លើកឡើងចាក់រាមរាជ្យពេញទំហឹងបំណងផ្ដាច់ជីវិតន្ទ្រីយ៍របស់វាតែម្ដង ។ តែ

ឥតប្រយោជន៍ ចោរហនេយ្យនេះដឹងខ្លួនទាន់ក៏គេចផុត ហើយចាប់ដៃនាងប្របាច់យ៉ាងខ្លាំង លុះត្រាតែធ្លាក់កាំបិតមួយរំពេច ។

ពេលនេះរាមរាជ្យខឹងច្រឡោតលើសគ្រាមុនៗ ទាំងអស់ ។ សេចក្តីស្នេហាដែលគេបានបណ្តុះអោយកើតឡើង ក្នុងបេះដូងគេក៏ត្រឡប់ក្លាយទៅជាភ្លើងសងសឹកមួយយ៉ាងសាហាវ ។

ប្រតិកម្មគ្រប់យ៉ាងបានកើតឡើងហើយ ។ រាមរាជ្យទះតប់នាងឥតត្រាប្រណី លុះត្រាតែគេសង្កេតឃើញតំណក់លោហិតពណ៌ក្រហម ចេញមកតាមច្រមុះ និងតាមមាត់ ។

- ទាហាន ! ចាប់មេចោរស្រីឆ្នាស់នេះយកទៅឃុំឃាំងភ្លាម ខានស្អែកត្រូវយកវាទៅសម្លាប់ចោលជាមួយអារិសេសសេនា ......

- យកអញទៅសម្លាប់ ! ហាំ ! ហាំ ! អញសប្បាយចិត្តណាស់ ព្រោះងាប់បានកើតដើម្បីបន្តការសងសឹកជាមួយអាឯងទៀត ! ......

កេសររង្សី ពោលដោយក្លាហាន ។

ខណៈនេះទាហានជាច្រើនរូបបានចូលមកដល់ ក៏នាំគ្នាចាប់ចងកញ្ញារងគ្រោះ នាំបណ្តើរចេញពីតំណាក់របស់រាមរាជ្យយកមកមន្ទីរឃុំឃាំងវិញ ។

មិត្តអ្នកអានជាទីគោរព អ្នកនិពន្ធសូមស្ទេះទុករឿងរ៉ាវរបស់កញ្ញាកេសររង្សីមួយអន្លើសិន ដើម្បីសូមអញ្ជើញអារម្មណ៍មិត្តអ្នកអាន ទៅជួបដំណើរការផ្សងព្រេង ស្វែងរកដាវមរកតរបស់នាយឆន្ទោ ជាបងរបស់នាងម្តង

ក្រោយពីធ្វើដំណើរអស់រយៈពេលជាច្រើនថ្ងៃ ដោយតិតទាំងការវង្វេងជាច្រើនលើក នៅក្នុងពន្លាជ័យដ៏ស្ងាត់ជ្រងំគួរអោយព្រឺព្រួចតក់ស្លុត ឆន្ទោក៏បានមកដល់ជើងភ្នំមាសដូចប្រាថ្នា ។

ព្រះអាទិត្យរះផុតចុងព្រឹក្សាធំៗ ទៅហើយ តែជោធាតុកំពុងបញ្ចេញឥទ្ធិពលដុតរោលធម្មជាតិ ។ ឆន្ទោចតសេះទុកនឹងជើងភ្នំស្រួលបួលហើយក៏ម្នីម្នាឡើងទៅលើកំពូលភ្នំ ដើម្បីយកដាវដែលកប់នៅក្រោមព្រះបាទព្រះរូបសំណាក តាមបណ្តាំខ្មោចឪពុក ។

ពេលនេះ គឺពេលដែលចៅមាណពកំពុងធ្វើដំណើរយ៉ាងស្វាហាប់មកកាន់គោលដៅនៃដែនអរញ្ញនេះ ដែលបានបន្លឺបទចម្រៀងធម្មជាតិយ៉ាងស្រាលបំពេរសោតាគេ គេពុំបានផ្តោតគំនិតគិតលន្លង់លន្លោច ទៅតាមសង្វាក់តន្ត្រីធម្មជាតិ ឡើយអារម្មណ៍គេចាក់ស្រេះគួចមកតែដាវមរតកមួយមុខប៉ុណ្ណោះ ។

ពេលវេលាកន្លងទៅអស់មួយស្របក់ធំហើយ កំសួលថ្ងៃបានរះមកកំឡោចសារពាង្គកាយគេយ៉ាងខ្លាំង, តែពេលនេះគេក៏បានមកដល់កំពូលភ្នំដោយសន្ទុត់ ។ ឆន្ទោសែនត្រេកអរ, គេក្រឡេកទៅយល់ព្រះរូបសំណាកដ៏ធំមហិមាឈរបែរភ័ក្ត្រទៅកាន់ទិសបូពិប្រកបដោយឫកពារយ៉ាងអង់អាច ។ នរៈបោលយ៉ាងលឿនសំដៅព្រះបាទខាងឆ្វេងដែលមានទំហំធំខ្ពស់ ។

គេបង្វិលខ្លួនមួយជុំនៅទីនេះ ដោយប្រើចក្ខុពិនិត្យរកកន្លែងខ្វេះកកាយលូកយកដាវមរតក ។ តែគ្មានឃើញចំណុចត្រង់ណាថាជាស្នាមល្មមនឹង

បើកខ្ទះទៅកើតសោះ ។ មាណពទាល់គំនិតគេយកដៃអេះក្បាលដោយអាការៈខ្វល់ចិត្ត ។ គួរអោយចាប់អារម្មណ៍ណាស់ ជាប់នឹងព្រះបាទព្រះរូបសំណាកនេះមានសិលាចារិកមួយផ្ទាំងឆន្នោក៏គិតថា បើថ្មមួយផ្ទាំងនេះមិនមែនជាគំរបដែលគេគ្របបង្កប់ដាវនោះទេ ! គេពិតជាមិនដឹងរកដាវនេះយ៉ាងដូចម្ដេចឡើយ !

នរៈក៏ចាប់បង្អើបលើកថ្មនេះពេញទំហឹង ថ្មក៏របើកឡើងបញ្ចេញរូបដាវមួយយ៉ាងស្អាតមានក្បាច់ក្បូរយ៉ាងប្រណិត ។ គេរំភើបចិត្តជាភិយ្យោភាពក៏ចាប់ដាវនេះបានហើយក្ដាប់យ៉ាងណែន លើកគ្រវីកាប់យ៉ាងពេញចិត្ត .......

ដាវនេះល្អណាស់ ! ចាប់ពីពេលនេះទៅពួកក្បត់ដែលកំពុងបង្កបង្កើតភ្លើងអសន្តិសុខពេញនគរនឹងត្រូវវិនាស ដោយសារដាវនេះជាមិនខាន ........

ឆន្នោពោលហើយក៏ថើបយុទ្ធភណ្ឌដោយក្ដីរីករាយ តែខណៈនេះរឿងមួយបានផុសឡើង ទាញស្នាមគំនូសទឹកមុខនរៈអោយវិលទៅជួបសេចក្ដីទុក្ខមួយជំពូក ដែលបានទ្រុតទ្រោមបាត់បង់ចេញពីខ្សែអារម្មណ៍គេអស់មួយរយៈមកហើយ ។ គេឈរសំលឹងកន្លែងដកល់ដាវ ដោយទឹកមុខស្ងួតទើបបន្លឺវាចាថា÷

- កេសររង្សី ! កេសររង្សីប្អូនស្រីរបស់ខ្ញុំស្លាប់ឬរស់ ! ..... តែគួរឱ្យឆ្ងល់ បើនាងស្លាប់ម្ដេចក៏បាត់ដាវមួយគ្រឿង ពីកន្លែងនេះទៅណា ! ឱ ! ប្រ-ហែលជាប្អូនខ្ញុំនៅរស់រានមានជីវិតនៅក្នុងផែនដី ដែលប្រកបដោយកលិយុគអាប់អួរនេះនៅឡើយទេ ! .........

មេឃស្រទំទោរទន់លេបបាត់កាំរស្មីព្រះអាទិត្យ ពិភពសន្និវាស, ព្រះ

ពាយត្រជាក់ធ្លាក់មករំភើយៗ សត្វទោចស្រែកដង្ហោយយំៗ គួរសោកស្រណោះ ឆន្នោលើកថ្មដាក់ដូចដើមវិញក៏ក្រាបថ្វាយបង្គំព្រះរូប លាចុះមកពីលើកំពូលភ្នំ មកដី ប្រញាប់ស្រូតរូតដំណើរទៅស្វែងរកជួបព្រះប្រិយមហាក្សត្រ តាមបណ្ដាំខ្មោចបិតា ។

ព្រះអាទិត្យហៀបអស្ដង្គត ផុតកំណត់នឹងបំភ្លឺពិភពលោកទៅហើយ ឆន្នោក៏ចេញពីភ្នំមាសមកវិញ ។ ដោយអាការៈត្រេកអរណាស់ ។ ទៅតាមដងផ្លូវគេគិតថា ដោយសារដាវមរតកដ៏ប្រកបដោយរិទ្ធីបារមីយ៉ាងសក្ដិសិទ្ធិនេះ គេនឹងក្លាយជាមនុស្សពូកែមួយរូបជាប្រាកដ ។

សេះបោលទៅមុខលាន់ឮកុប ! កុប ! នាំម្ចាស់របស់វាទៅកាន់គោលដៅ រីឯស្រមោលរាត្រីក៏ធ្លាក់សន្សឹមៗ ចូលមកដណ្ដប់មហាប្រថពី ។

មកដល់ភូមិមួយ មិត្តយើងក៏សុំផ្ទះអ្នកស្រុកម្នាក់សំរាកមួយយប់សិន ព្រោះខ្លាចក្រែងវង្វេងផ្លូវរកចូលទៅរាជធានីសុវណ្ណភូមិមិនឃើញ ។

# ១០
# ឥទ្ធិពលជាវជ័យសិទ្ធិ

ការបាត់បង់រូបកញ្ញាកេសរវង្សី បានធ្វើឱ្យកងទ័ពបដិវត្តន៍ទាំងមូលនេះ មានការរំជើបរំជួលយ៉ាងខ្លាំង ចំពោះព្រះនរបតីវិញព្រះអង្គទ្រង់ព្រះវិយោគ លើសលែងអ្វីទាំងអស់ ។

ពីរថ្ងៃកន្លងមក នៅក្នុងរាជធានីសុវណ្ណភូមិ ព្រឹកនេះប្រជារាស្ត្រភ្ញាក់ផ្អើលមកជួបជុំគ្នាកកកុញនាមុខព្រះបរមរាជវាំង ជាទីមួយដែលនឹងសំរេចទោសប្រហារជីវិតអ្នកទោសពីររូប គឺកញ្ញាកេសរវង្សី ដែលជាប់ចោទពីបទចូលរួមក្នុងចលនាបដិវត្តន៍ ប្រឆាំងតបនឹងរបបគ្រប់គ្រងរដ្ឋថ្មី និងលោកវិសេសសេនាពិបទសមគំនិតនឹងព្រះបាទសាយណ្ហាវ័រ្មន ។

មកដល់ត្រង់នេះ យើងសូមមិត្តអ្នកអានអភ័យទោស អោយយើងបរិយាយពីលោកវិសេសសេនានៅក្នុងគុកបន្តិច ។ កាលដែលកងទ័ពរបស់រាម-រាជ្យ បានសំរេចការប្លន់ដណ្តើមយកបល្លង្ករាជ្យ ព្រះបាទសាយណ្ហាវ័រ្មនបានហើយ ហើយឡើងគ្រប់គ្រងរាជ្យភ្លាមនោះ មន្ត្រីក្បត់ដែលមានក្រឡាសូជាមេញុះញង់បានយកលោកវិសេសសេនាមកធ្វើទារុណកម្មយ៉ាងធ្ងន់។ វរជនក្លាហានពុំបានជ្រាបថារដ្ឋប្រហារកើតឡើងទេ. តាំងពីពេលនោះមកទល់នឹងពេលនេះ លោកស្មានថាតែព្រះបាទសាយណ្ហាវ័រ្មន ទ្រង់គង់នៅលើព្រះបល្លង្ករាជ្យនាព្រះ-

បរមរាជវាំងសុវណ្ណភូមិដែរ ។

ពួកក្បត់គិតថា បើទុកវិសេសសេនា អោយរស់រានមានជីវិតតទៅទៀតនោះ ប្រាកដជាមានគ្រោះអាសន្នជាយថាហេតុមិនខាន ។ ដូច្នេះតុលាការទីងមោងពោរពេញដោយអយុត្តិធម៌ ក៏បានកាត់ទោសដាច់ណាត់ថា : វិសេសសេនាត្រូវកាត់ទោសប្រហារជីវិត ។

ថ្ងៃរះបន្តិចហើយ. មុខព្រះបរមរាជវាំង គេសង្កេតឃើញប្រជាជនគ្រប់ប្រភេទមកជួបជុំគ្នាកកកុញ រង់ចាំមើលការប្រហារអ្នកទោសទាំងពីររូបនេះ ។

នៅលើកន្លែងមួយ ដែលគេប្រារព្ធធ្វើអំពីឈើជារបៀបរានមួយ ភ្នែកប្រជាពលរដ្ឋបានផ្តោតទៅលើមនុស្សពីររូប ដែលមានពេជ្ឈឃាតម្នាក់រាងធាត់ក្រអាញសម្បុរខ្មៅគួរអោយខ្លាចនៅជិតនោះ ។

ទស្សនិកជនជ្រួលជ្រើមចំពោះការកាត់ទោស ប្រហារអ្នកទោសអភ័ព្វទាំងពីរនាក់នេះណាស់ ! ដង្ហើមយើងដកស្ទើរមិនដល់គ្នា តែពេលនោះគេបានសាកសួរគ្នាថា តើអ្នកទោសទាំងពីរនាក់នេះប្រព្រឹត្តខុសរឿងអ្វី ក៏កាត់ទោសប្រហារជីវិតយ៉ាងនេះ ?

សំលេងសាកសួរដែលទស្សនិកជនកំពុងខ្សិបខ្សាវគ្នា បានប្រាកដឡើងជាសំលេងមួយគួររំភើប តែរំពេចនោះ គេទាំងអស់ក៏បិទមាត់ឈប់ស្ងៀមទៅ

- ថ្ងៃនេះយើងសំរេចកាត់ទោសប្រហារជីវិត អ្នកទោសពីរនាក់ ដែល

បានប្រព្រឹត្តផ្ទុយនឹងរបបគ្រប់គ្រងរដ្ឋនៃព្រះចៅរាមរាជ្យ ព្រះមហាវីរក្សត្រថ្មី នៃព្រះរាជអាណាចក្រសុវណ្ណភូមិយើងនេះ ។

អ្នកទាំងពីរនាក់នេះ គឺឈ្មោះវិសេសសេនា ដែលជាអតីតមេទ័ពរងរបស់ព្រះបាទសាយណ្ហាវ័ន្ន និងនាងកញ្ញាម្នាក់នេះទៀតឈ្មោះកេសរវង្សី ដែលជាសមាជិកមួយរូបនៃកងទ័ពបដិវត្តន៍ តែងតែធ្វើការប្រឆាំងយ៉ាងសាហាវចំពោះកងទ័ពជាតិយើង ដែលកំពុងស្វែងរកសេចក្ដីសុខ, ការចំរើនលូតលាស់ជូនចំពោះជាតិ ។

ប្រជាពលរដ្ឋស្ដាប់ឮសេចក្ដីប្រកាសនេះ ក៏កេះគ្នាខ្សិបខ្សៀវរអ៊ូរទាំថា ÷

- រឿងនេះមិនពិតទេ ! កងទ័ពបដិវត្តន៍ទេ ដែលស្វែងរកសុខសន្តិភាពជូនជាតិ ! ចំពោះពួកវានេះគឺជាពួកក្បត់ ! ..........

ការជ្រួលច្របល់រំពើករំពើន កំពុងតែផ្ទុះឡើងប្រៀបបាននឹងសកម្មភាពនៃរលកទឹកសមុទ្រ ស្រាប់តែគេឃើញយុវជនមួយរូប ដែលក្រោយពីបានជិះសេះយ៉ាងលឿនជ្រែកហ្វូងមនុស្សដ៏កកស្រទាប់ ឡើងមកលើវេទិការកាប់អ្នកសូត្រសេចក្ដីប្រកាសនេះមួយដាវស្លាប់នៅកន្លែង ទើបប្រកាសឡើងថា ÷

- ឯងចោទលោកវិសេសសេនា និងនាងកេសរវង្សីជាមនុស្សប្រឆាំងនឹងរបបគ្រប់គ្រងរបស់ឯង ត្រូវហើយ ព្រោះអ្នកឯងជាអ្នកប្រព្រឹត្តអំពើពុករលួយជិះជាន់រាស្ត្រ គេីបយកអំណាចចែកជូនតែបក្សពួកឯង ! ........

កញ្ញាកេសរវង្សី ដែលត្រូវគេចងផ្ដោបជាប់នឹងសរសរមួយ លុះឃើញឆន្ទោជាបងរបស់នាងមកដល់ ក៏នឹកត្រេកអរពន់ប្រមាណ ។ នាងបា

មាត់ស្រែកឡើងថា ÷

- បង ! បងឆន្ទោ ! ........

ចំណែកទាហានដែលបានមកនៅយាមឃ្លាំចាំការពារប្រតិកម្ម ដែលខ្លាចកើតមានឡើងប្រឆាំងចំពោះដំណើរ នៃការពិឃាតអ្នកទោសទាំងពីររូបនេះ លុះឃើញកំលោះយើងឡើងមកអុកឡុក ព្រមទាំងប្រហារអ្នកសូត្រសេចក្ដីប្រកាសឱ្យស្លាប់បាត់បង់ជីវិតនៅកន្លែង ក៏នាំគ្នារត់ឡើងមកចោមរោមចាប់មិត្តយើង ។

តែខណៈនោះដាវជ័យសិទ្ធិដ៏ជាដាវប្រោះព្រំ ទៅដោយរិទ្ធិបារមីយ៉ាងមហស្ចារ្យ ក៏បានបញ្ចេញឫទ្ធិដៃឡើង ។ មើលចុះទាហាន ១០ នាក់ ដែលឡើងមកអម្បាញមិញ ព្រមទាំងពេជ្ឈឃាតដែលសុទ្ធសឹងតែប៉ងរំលាយជីវិតឆន្ទោបានត្រូវឆន្ទោកាប់ស្លាប់គរជើងលើគ្នាគួរឱ្យស្ញើច ។ ទស្សនិកជនឃើញដូច្នេះក៏រំភើបក្នុងចិត្ត កោតសរសើរឫទ្ធិដៃយុវជនដ៏អស្ចារ្យនេះយ៉ាងខ្លាំង ។

ឆន្ទោយល់ថាឱកាសប្រសើរសំរាប់រូបគេ ក្នុងការរំដោះអ្នកទោសទាំងពីរនាក់នេះនៅតិចណាស់ ក៏ប្រញាប់កាត់ចំណងដែលចងរិតរូតខ្លួនអ្នកទាំងពីរភ្ជាប់ទៅសសរចេញ ហើយនាំរត់ចុះចេញពីវេទិកាពិឃាតនេះមក ។

- បងប្អូនទាំងអស់ ! យើងត្រូវរួបរួមកំលាំងគ្នា កំចាត់ពួកអាចោរក្បត់ជាតិអោយបាន !

ឆន្ទោពោលតែប៉ុណ្ណោះ ក៏នាំប្អូនស្រីឡើងទៅលើខ្នងសេះ ចំណែកលោកវិសេសសេនា ក៏បានឡើងជិះលើខ្នងសេះមួយទៀតចេញពីនេះភ្លាម ។

យើងគ្រាន់តែបណ្ដោះគ្នាចេញផុតពីហ្វូងប្រជាជន ដែលកំពុងផ្អើល

ឆោឡោឥតសណ្ដាប់ធ្នាប់ ក៏ស្រាប់តែជួបកងទ័ពក្បត់ ៥ នាក់ជិះសេះចូលមក ស្ទាក់ផ្លូវយើង ។

ឆន្នោឥតបង្អង់គិតគូរអោយខាតពេលឡើយ ។ យើងញញឹមខាំមាត់ ទៅរកបច្ចាមិត្ត ហើយលើកដាវឡើងចូលកាប់ឆ្ការប្រហារវាឥតត្រាប្រណី ។ បរបក្សដូចចាញ់បារមីដាវដ៏អស្ចារ្យនេះណាស់ ។ ម្នាក់ៗ គ្រាន់តែឃើញនេះ ភ្លាម ក៏ត្រលប់ជាភ័ន្តភាំងបាត់បង់វិញ្ញាណអស់ ។ ហេតុដូច្នេះហើយបានជាមិត្ត យើង អាចសំរេចកិច្ចការដោះខ្លួនបានយ៉ាងឆាប់ណាស់នោះ ។

ខ្សែរបងរាំងរាដំណើរយើងបានរលាយខ្សុរ ក្លាយទៅជាសាកសពទៅ ហើយ ម្លោះហើយយើងក៏នាំគ្នាដាក់មេផាយចេញពីរាជធានីភ្លាម ។

..............................................................................

ដួងព្រះនភមណីយាងទៅមុខជាលំដាប់ តាមដំណើរធម្មតានៃព្រះ សុរិយាគតិ ។ នៅក្រោមកំដៅដ៏ក្ដៅស្ទើរខ្លោច អស្សពាហ៍មួយគូបោល ព្រឹប ! ព្រឹប ! កាត់វាលស្មៅដ៏ធំល្វឹងល្វើយទៅកាន់ទីដៅមួយ ដែលគេពុំអាចដឹងបាន កាត់ស្មានត្រូវ ។

លុះមកដល់ស្រះមួយដ៏មានទឹកថ្លាដូចកញ្ចក់ ជីវិតទាំងបីនេះក៏នាំគ្នា ឈប់សម្រាកនៅក្រោមម្លប់ពោធិ៍មួយដើម ........ ។

សេះទាំងគូដើរត្រឹកៗ រកស៊ីស្មៅយ៉ាងក្សេមក្សាន្ត ចំណែកម្ចាស់របស់ វាទាំងបីនាក់វិញ កំពុងជជែកមើលមុខគ្នាយ៉ាងរីករាយ ។

- បងខ្ញុំដូចជាធ្ងល់ដល់ហើយ ! ចុះបងម្ដេចក៏បានជាពូកែម្ល៉េះ (កេសរ រង្សីពោល)

- អូនអើយ ! តាមពិតបើនិយាយពីតម្រេះវិជ្ជាបងក្នុងផ្នែកភ្លេងអាវុធ បងប្រហែលជាមិនអាចសំដែងឱ្យឃើញថា មានថ្វីដៃពូកែយ៉ាងនេះទៅបានទេ តែនេះក៏អាស្រ័យទៅលើដាវមរតករបស់ជីតាយើង ដែលទុកអោយបងនៅក្រោមព្រះបាទព្រះរូបសំណាកព្រះបាទសុនិន្ទ្រាវ័ន្ទន ឯភ្នំមាស ។

- បងមានដាវជ័យសិទ្ធិ ? ....... ចំណែកខ្ញុំ ដាវជ័យសិទ្ធិខ្ញុំ ដែលខ្ញុំបានឡើងទៅយកពីក្រោមព្រះបាទព្រះរូបសំណាក នៅលើកំពូលភ្នំមាសដែរនោះ ឥឡូវមិនដឹងជានរណាលួចយកទៅណាបាត់ទៅហើយ ! ខ្ញុំព្រួយចិត្តណាស់ ។

- ដាវអូនបាត់ ? បងកាលពីទៅរកអូននៅឯផ្ទះមិនឃើញ បងនឹកថា អូនប្រាកដជាស្លាប់ ឬត្រូវពួកក្បត់ចាប់យកមកធ្វើបាបមិនខាន តែលុះបងមករកដាវមរតក ដល់ឃើញបាត់មួយ បងនឹកសង្ឃឹមថាអូនពិតជារស់នៅឡើយទេ

លោកវិសេសសេនាអង្គុយស្តាប់ ឮយុវជនទាំងពីរជជែកគ្នាពីរឿងនេះ លោកក៏នឹកគិតក្នុងចិត្តថា នគរសុវណ្ណភូមិនឹងត្រូវបានឆ្លងកាត់ពីគ្រោះមហន្តរាយ ដោយសារដាវជ័យសិទ្ធិមិនខាន ......... ព្រោះត្បិតថាដាវនេះធ្លាប់បានចូលខ្លួនមករំដោះជាតិក្នុងរាជ្យព្រះបាទសុនិន្ទ្រាវ័ន្ទន កាលពីសម័យចាមចូលមកឈ្លានពានម្តងហើយ ។

សេចក្តីសង្ឃឹមបានក្លាយទៅជាព្យុះ នៃសេចក្តីរីករាយមួយបក់បោកទៅលើដួងចិត្តមេទ័ពនេះយ៉ាងខ្លាំង ។ ក្លិនផ្កាសប្បាយបានរីកឡើងស្រស់បំព្រងពេញក្នុងបេះដូងលោកវិសេសសេនា ។

កេសររង្សីនៅស្ងៀមមួយរយៈ ទើបបន្តសំនួរថ្មីទៅឆន្ទោជាបងថា ÷

- បង ! ហេតុដូចម្តេចបានជាបងចូលមករំដោះខ្ញុំទាន់ ? .......

- ហ៊ឺ ! អូន ! នេះចាត់ទុកជាសំណាងថ្លៃរបស់អូនហើយ ! កាលពីបងយកដាវបានមក ពេលនោះជាពេលព្រលប់ធំណាស់ទៅហើយ បងក៏សុំផ្ទះអ្នកស្រុកចូលទៅសំរាកមួយយប់ ជាកុសល ក្រោយពីបានដឹងរឿងនេះ បងជ្រួលច្របល់ក្នុងចិត្តពន់ប្រមាណ ។

លុះដល់ភ្លឺបងក៏មករាជធានី ។ ពេលមកដល់ភ្លាម បងឃើញគេយកអ្នកទោសមកប្រហារ ដូចពាក្យអ្នកស្រុកប្រាប់មែន ។ បងតក់ស្លុតណាស់ ដោយឮថាអ្នកទោសនោះ ជាអ្នកបដិវត្តន៍ហើយឈ្មោះកេសរវង្សីជារូបអូនទៅទៀត ។ ពុំអាចទ្រាំបាន បងក៏សំរេចចិត្តថា ត្រូវតែចូលមករំដោះអោយបាន ........

វាចាមាណពរលត់បាត់ទៅក្នុងភពដ៏ត្រជាក់ ដែលព្រះពាយនាពេលព្រឹកបានសាងឡើង ។

ខណៈនោះ សន្ធឹកជើងសេះក៏សន្ធាប់ចូលមកគគ្រឹកគគ្រេង ទាញអារម្មណ៍មិត្តយើងទាំងបីអោយភ្ញាក់ចាកពីក្តីរីករាយ ។

- យី ! ចុះសម្លេងជើងសេះទ័ពខាងណាក៏គគ្រឹកគគ្រេងម្ល៉េះ ! ........

លោកវិសេសសេនាពោល ។ ឆន្ទោ និងកញ្ញាកេសរវង្សីធ្លាក់ថ្លើមក្តុកងាកក្រឡេកមកកាន់ទីដែលស្នូរដ៏គគ្រឹកគគ្រេងកំពុងតែផ្ទុះទ្វេឡើង ។

- អូនកេសរវង្សី លោកអ៊ំ ទ័ពសត្រូវលើកមកតាមចាប់យើងហើយ ពេលនេះយើងត្រូវគិតយ៉ាងណា ? .........

ឆន្ទោបញ្ចេញវាចាដោយហូតដាវមកកាន់ក្តាប់យ៉ាងណែន ។ លោកវិសេសសេនា ក្រោកឈរឯបនឹងគល់ឈើ និយាយដាច់ៗ ថា ÷

- យើងគ្មានអ្វីដោះស្រាយក្រៅពីតស៊ូ អោយឃើញសខ្មៅមុននឹងស្លាប់

ទេក្មួយ ! .........

- មែនលោកតា ! យើងទាំងបីនាក់ត្រូវតែតស៊ូ ! តែគួរអោយស្ដាយខ្ញុំនឹងលោកតា បើគ្មានអាវុធយ៉ាងនេះ តើបានអ្វីជួយច្បាំងបងឆន្ទោ ? ..........

- បើគ្មានដាវ យើងរកដំបងមួយម្នាក់មក ក៏ជាការគ្រាន់បើជាជាងនៅដៃទទេដែរ ! មែនទេលោកក្មួយឆន្ទោ ........

- បាទ ! មែនហើយ ! .......

ឆ្លើយដូច្នោះហើយ នាយកំហោះក៏ស្ទុះទៅកាប់មែកឈើសន្ទួនត្រង់មួយគួ ប្រវែងមួយព្យាមយកមកអោយកេសររង្សី និងលោកវិសេសសេនា ធ្វើជាដំបងកាន់ការពារខ្លួន ។

សន្ធឹកជើងសេះចូលកៀកណាស់មកហើយ ខណៈនេះគ្រាប់ភ្នែកទាំង ៦ របស់មិត្តយើង ក៏បានក្រឡេកមើលទៅយល់រូបឆោមកងទ័ពសេះ ដែលកំពុងតែបោះពួយយ៉ាងស្រូតរូតនេះ ។

កេសររង្សី ក្រឡេកយល់ឯកសណ្ឋានពួកទ័ពនេះភ្លាម ក៏បោះដំបងចោលទៅដី លើកដៃស្រែកពេញសំលេងថា ÷

- កនយើង ! កនយើង ! ចាំខ្ញុំផង ! ចាំផង ! .......

ឆន្ទោ និងលោកវិសេសសេនា ឆ្ងល់នឹងអាកប្បកិរិយារបស់តរុណីណាស់ ។ កម្លោះសួរថា ÷

- អូនកេសររង្សី ម៉េចក៏អូនហៅគេទៅវិញ ! អូនស្គាល់គេឬ ?

- ចាំ ! បងនេះតឹកងទ័ពបដិវត្តន៍ ។

សេចក្ដីរីករាយបានប្រសូត្រឡើង កំចាត់ការភិតភ័យចេញអស់ពីដួង

ចិត្តយើង ។

ពេលនេះទាហាមមគ្គុទេសក៍ ៥ នាក់ នៃកងបដិវត្តន៏ បានមកដល់ចំពោះមុខមិត្តយើងទាំងបីហើយ ក៏ហក់ចុះមកជីស្ងួរកេសររង្សីថា÷

- យី ! អ្នកនាងមកនៅកន្លែងនេះទេ !

- ចាំ ! លោក ! ចុះលោកនាំគ្នាទៅណាហ្នឹង ! .......

យើងនាំគ្នាទៅរាជធានី ដើម្បីស៊ើបសួររកអ្នកនាងហ្នឹងឯង ! នេះចាត់ជាសំណាងហើយអ្នកនាង ! ព្រះករុណាកាលពីទ្រង់ជ្រាបថាអ្នកនាងត្រូវខ្មាំងចាប់បាន ទ្រង់ព្រួយព្រះទ័យយ៉ាងខ្លាំង ឥឡូវនេះព្រះអង្គនាំកងទ័ពបដិវត្តន៏មួយចំនួនយ៉ាងធំលើកមកកំទេចក្រុងសុវណ្ណភូមិដើម្បីដណ្តើមយកអ្នកនាង ! នុ៎ះទ័ពព្រះអង្គលើកមកហើយ ! .......

នាយទាហានមគ្គុទេសក៍ ក៏ពោលដោយលើកដៃចង្អុលទៅកងទ័ពដ៏ច្រើនមហិមា ដែលកំពុងលើកសម្រុកចូលមកយ៉ាងក្លៀវក្លា ។

បើដូច្នេះបងឆន្ទៃ, លោកអ៊ំ និងអស់លោក យើងឡើងសេះវិលទៅក្រោយជួបព្រះករុណាសិន !

ខណៈនេះយើងក៏នាំគ្នា ឡើងជិះសេះត្រឡប់មករកកងទ័ពដែលកំពុងលើកចូលមក .........

កាលមកដល់ ព្រះបាទសាយណ្ហាវ័ន្ន ដែលទ្រង់គង់នៅពីមុខព្យូហ៍-យាត្រាទ្រង់ទតទៅឃើញ នារីកំពូលស្នេហារបស់ទ្រង់ ឋិតលើខ្នងសេះជាមួយបុរសកម្លោះរូបស្អាត ដែលទ្រង់ពុំដែលស្គាល់ ព្រះទ័យទ្រង់ក៏អាក់អន់ស្រពន់មួយរំពេច ។ ព្រះអង្គមានព្រះភ័ក្ត្រក្រៀមស្រពោន ព្រះសិតការតបទៅតរុណី

យ៉ាងស្ងួត ។

កេសរវង្សី ឥតយល់ន័យដ៏អាថិកំបាំង ដែលដក់នៅក្នុងលង្វែកព្រះឱវាក្យត្រាទ្បើយ ។ នាងញាក់សេះចូលមកទន្ទឹមព្រះទីនាំងព្រះអង្គហើយក៏បន្ទន់កាយថ្វាយបង្គំ ទើបទូលថា ÷

- ព្រះករុណាជាអម្ចាស់ ! នេះជាបងប្រុសបង្កើតរបស់ខ្ញុំម្ចាស់ គាត់ឈ្មោះឆន្ទោ .......

ព្រះចមពល លុះទ្រង់ជ្រាបថាបុរសកម្លោះរូបស្អាតនេះ ត្រូវជាបងប្រុសបង្កើតរបស់នាងទៅវិញទេ ក៏ទ្រង់បានធូរស្បើយក្នុងព្រះទ័យវិញ ។ ពេលនេះទ្រង់ត្រាស់ទៅកាន់នាងថា ÷

- កេសរវង្សី ! រួចចុះយ៉ាងម៉េចក៏បានជានាំគ្នារត់ចេញពីកណ្ដាប់ដៃខ្មាំងបាន ! អូ ! លោកវិសេសសេនាបានរត់រួចមកជាមួយដែរ !

ព្រះអង្គទ្រង់ត្រាស់ទៅកាន់វិសេសសេនា ។

កេសរវង្សីញញឹមបន្តិច ទើបទូលព្រះករុណាថា ÷

- ព្រះពរ ! ខ្ញុំម្ចាស់ និងលោកអ៊ឹងណោះ បានចេញផុតពីកណ្ដាប់ដៃខ្មាំងក្នុងពេលនេះ ក៏អាស្រ័យលើឥទ្ធិពលរបស់បងឆន្ទោទាំងស្រុងក្រាបទូល ! បើកុំតែបានគាត់ចូលទៅជួយទាន់ពេលវេលា ខ្ញុំម្ចាស់ និងលោកអ៊ឹងណោះត្រូវពេជ្ឈ-ឃាតប្រហារបាត់ទៅហើយ !

- ជីវិតនាង និងជីវិតលោកវិសេសសេនាថ្លៃណាស់ ! ........

ស្ដេចទ្រង់ត្រាស់ដល់ត្រឹមនេះ ក៏ទ្រង់បែរទៅស្នើលោកតេជោក្លាហានថា ÷

- លោកមេទ័ព ! កាលពីយើងនាំគ្នាលើកទ័ពម្តងនេះ គឺមានបំណងនឹងចូលមកដណ្តើមនាងកេសរវង្សី ឥឡូវនាងបានរត់រួចមកហើយ ពេលនេះយើងត្រូវត្រឡប់ទៅបន្ទាយរបស់យើងវិញ .......

- ក្រាបទូល ! សូមទទួលតាមព្រះរាជឱង្ការដឹកលំលើត្បូង ! ......

កងទ័ពបដិវត្តន៍ បង្វែរព្យូហ៍យាត្រាត្រឡប់ក្រោយវិញហើយ ។ ពេលនេះ យើងងាកមកជួបរាមរាជ្យវិញ ។

កាលដែលបានទទួលដំណឹងថា នាងកេសរវង្សី និងលោកវិសេសសេ-នា ត្រូវបានជនមិនស្គាល់ឈ្មោះម្នាក់ ចូលមករំដោះយកទៅបានវិញហើយនោះ រាមរាជ្យក្តៅឈ្លួលក្នុងទ្រូងយ៉ាងខ្លាំង ។

- ហ៊ិះ ពួកយើងក៏កំសាកម្ល៉េះ ! អោយអាក្មេងចូលមកចាក់សំលាប់រំដោះយកអ្នកទោសទៅវិញបាន ! នេះចំជាអាម៉ាស់ខ្លាំងណាស់ ! .......

រាមរាជ្យពោលមួម៉ៅនៅក្នុងតំណាក់ ធ្វើអោយមេទ័ពទាំងអស់ភិតភ័យយ៉ាងខ្លាំង ។

នៅក្នុងបរិយាកាសកំពុងតែចង្អៀតចង្អល់នេះ មានអ្នកនាំសារម្នាក់ជាតិចាម បានចូលយកសារមួយច្បាប់មកអោយរាមរាជ្យៗ ទទួលហើយក៏សួរថា ÷

- នរណាធ្វើសារនេះមកខ្ញុំ ! .......

- ក្រាបទូល ! លោកមេទ័ពវេះស្នាត ! ........

មិនស្តីដូចតទៅទៀតទេ. រាមរាជ្យលាសារនេះ អានដោយទឹកមុខស្រពាប់ស្រពោនអស់មួយរយៈតូចទើបបត់ទុកវិញ ហើយលាន់មាត់ដោយ

ដង្ហើមធំថា ÷

- ហ៊ុះ ! អស់លោកសូមជួយគិតខ្ញុំផង ! ឥឡូវនេះលោកមេទ័ពរេះ-ស្នាត ជាព្រះរាជតំណាងព្រះចៅមហាម៉ាត់អស្សឫច័យ ដែលបានផ្តល់កងទ័ពយ៉ាងច្រើនមកជួយយើងក្នុងរឿងរដ្ឋប្រហារនេះ ចង់ដកទ័ពទៅនគរចម្ប៉ាវិញហើយៗ ទាររអោយយើងសងបណ្ណាការទៅគេជាមាស ៥ ហាប ដូចដែលយើងបានសន្យានឹងគេនោះ ! តើយើងត្រូវគិតដូចម្តេច ! .......

ក្រឡាសូក្រោយពីពិចារណាបន្តិច ក៏តបទៅរាមរាជ្យថា ÷

- រឿងនេះ យើងត្រូវតែប្រគល់ជូនទៅគាត់អោយសមតាមពាក្យសន្យា តែចំពោះរឿងដែលលោកចង់ដកទ័ពទៅនគរចម្ប៉ាវិញនោះ គួរអោយសូមអង្វរអោយលោកផ្អាកបានមួយខែពីរសិនទៅ ព្រោះសព្វថ្ងៃនេះ យើងនៅព្រួយបារម្ភចំពោះកងទ័ពបដិវត្តន៍នៅឡើយ ! .......

- មែនលោកក្រឡាសូ លោកមានយោបល់នេះត្រឹមត្រូវណាស់ ! ..... នែ ! អ្នកនាំសារ (រាមរាជ្យនិយាយទៅអ្នកនាំសាររបស់រេះស្នាត) ចូរអ្នកទៅប្រាប់លោករេះស្នាតថា យើងឥតបំភ្លេចគុណដ៏ធ្ងន់របស់កងទ័ពចាម ដែលបានចូលមកជួយជ្រោមជ្រែងផែនការយើង ឱ្យបានទទួលជោគជ័យនោះទេ ! .... មាស ៥ ហាបយើងយកទៅប្រគល់ជូនលោកមេទ័ពនៅថ្ងៃស្អែកនេះមិនខាន ! ចំណែកខាងយើងវិញដោយសព្វថ្ងៃកងទ័ពបដិវត្តន៍កំពុងតែរៀបចំគំរោងការណ៍ច្បាំងតបនឹងយើង ហើយនឹងការបះបោររបស់អ្នកស្រុកគ្រប់ទីកន្លែង យើងមិនទាន់ដោះស្រាយអោយជ្រះស្រឡះនៅឡើយ ដូច្នេះយើងសូមឱ្យលោករេះស្នាតកុំប្រញាប់ត្រឡប់ទៅនគរចម្ប៉ាវិញណាំលោក ! .......

- ក្រាបទូល ! ...........

ពេលអ្នកនាំសារនេះត្រលប់ទៅវិញ រាមរាជ្យក៏ប្រមូលមេទ័ពធំៗ មានក្រឡាសូជាដើម ធ្វើដំណើរមកកាន់ភ្នំមាស ដើម្បីចូលទៅយកមាសអោយបាន ៥ ហាប ជូនចំពោះកងទ័ពចាម ដែលបានមកជួយច្បាំងដណ្តើមបល្ល័ង្ករាជ្យពីព្រះបាទសាយណ្ណាវ័ន្ន កាលពីរាត្រីរដ្ឋប្រហារនោះ ។

មកដល់ភ្នំមាសត្រង់តំបន់ ដែលគេធ្លាប់ចូលទៅយកមាសហើយ កងទ័ពទាំងអស់ព្រមទាំងរាមរាជ្យ និងមេទ័ពទាំងឡាយបានពើបប្រទះនឹងឧបសគ្គដ៏ចម្លែកមួយ ដែលតាំងពីដើមមកពុំដែលកើតមានទាល់តែសោះ ។

មើលចុះនៅគ្រប់មាត់ច្រកចូលទៅយកមាស គឺត្រង់ដើមពោធិព្រឹក្សដែលព្រះបាទសាយណ្ណាវ័ន្នទ្រង់តំកល់ព្រះរូបព្រះគោមាស គេឃើញសឹង្ហធំៗជាច្រើន ឈរបញ្ចេញចង្កូមដ៏ស្រួចមុតមករកពួកក្បត់ ។

ឆ្ងល់ណាស់រាមរាជ្យងាកទៅសួរក្រឡាសូថា ÷

- លោកក្រឡាសូ ! ម្តេចក៏ត្រង់កន្លែងនេះ មានសឹង្ហអ្វីក៏ច្រើនម្ល៉េះ !

ក្រឡាសូ ក៏ឆ្ងល់ចំពោះហេតុដ៏ប្លែកនេះដែរ គេក៏ឆ្លើយថា ÷

- ទេ ! ខ្ញុំក៏មិនដឹងដែរ ! តែពីដើមគ្មានសត្វសឹង្ហមកនៅនេះទេ !

- បើអីចឹង ! ទាហាននាំគ្នាបាញ់អាសត្វចង្រៃនេះសម្លាប់ចោលភ្លាមទៅ ! ..........

ផ្លែលំពែងជាច្រើនក៏របូតចេញពីដៃទាហាន នៅជួរខាងមុខហើរទៅដោតលើរាងកាយពាឡម្រិគៗ ក៏ក្លាយទៅជាដុំថ្មអស់រលីង ។

- យី ! ចុះវាម៉េចក៏ក្លាយទៅជាថ្មអស់ទៅហើយអីចឹង ! តែពួកយើង

ត្រូវតែទៅក្នុងភ្នំភ្លាម ! (រាមរាជ្យពោល) ។

ទាហានប្រដាប់ដោយអាវុធក៏រត់ចូលទៅក្នុងគុហា ដើម្បីកើបប្រមូលយកមាសតាមបញ្ជារបស់ចៅហ្វាយនាយ ។

តែអនិច្ចា ! គ្រាន់តែវាមកដល់មាត់រូងភ្លាម សឹង្ហទាំងឡាយដែលបានក្លាយខ្លួនជាថ្មក៏ប្រែជារស់ឡើងវិញ មកខាំហែកហួរទាហានទាំងនោះគ្មានប្រណី

រាមរាជ្យឃើញដូច្នេះ ក៏បញ្ជាទាហានដែលមកជាមួយទាំងប៉ុន្មានឱ្យចូលទៅជួយទាហាន ដែលកំពុងរងគ្រោះដោយសារសត្វសាហាវនេះ តែគ្មានសង្ឃឹមសោះ ទាហានវាំងអស់នេះក៏បានក្លាយទៅជាចំណីដ៏ឆ្ងាញ់របស់សត្វព្រៃ ។

យល់ហេតុមិនស្រួល ក្រឡាសួប្រាប់រាមរាជ្យថា ÷

- លោកបើមិនប្រញាប់ថយខ្លួនចេញពីកន្លែងនេះភ្លាមទេ សត្វនឹងមកខាំយើងស៊ីមិនខាន !

រាមរាជ្យ ពុំអាចប្រកែកនឹងយោបល់របស់ក្រឡាសួ គាត់ញាក់សេះបកថយក្រោយប្រញាប់ដោយពោលថា : យី ! ចំជាចម្លែកមែន ! បើយ៉ាងនេះយើងបានមាសពីណាទៅអោយទ័ពចាម ....... វិវរហើយ ! ...... ទាហានទាំងឡាយដែលមានអាយុថ្លៃ បានគេចផុតពីចង្កូមសត្វសឹង្ហ ក៏ដាក់មេផាយតាមក្រោយប្រញាប់ ។

ឆ្លល់ណាស់មកដល់ដំណាក់វិញ រាមរាជ្យបានបញ្ជាន់រូបអ្នកតាទៅក៏បានដឹងថា សឹង្ហទាំងឡាយនេះកើតឡើងពីបារមីនៃព្រះគោមាស ដែលថែរក្សាមាសនៅភ្នំនេះ ។

វេះស្លាត កាលបើពុំបានទទួលនូវរង្វាន់ពីរាមរាជ្យជាមាស ដូចពាក្យ

សន្យាទេ  ក៏កើតសេចក្តីតូចចិត្តចំពោះរាមរាជ្យយ៉ាងខ្លាំង  ដោយគិតថាមិនគួរចាញ់បោកមហាចោរក្បត់ជាតិឯងនេះសោះ ។

វេះស្វាតឈឺចិត្តណាស់ ! យប់មួយជាឱកាសដ៏ប្រសើរសំរាប់គេ វេះ-ស្វាតបានលួចនាំវេហ៍ពលសាកលយោធារបស់គេទាំងអស់ឡើងសំពៅ  ត្រឡប់មកនគរចម្ប៉ាវិញ តែមិនដឹងជាអកុសលអ្វី នៅរាត្រីដែលវេះស្វាតកំពុងនាំវេហ៍ពលលួចបើកសំពៅរត់ចេញពីផែរាជធានីសុវណ្ណភូមិ  ព្រះប្រមុខនៃកងទ័ពបដិ-វត្តន៍បានទ្រង់យល់សុបិន្តឃើញព្រះសុនិន្ទ្រាវ៉ារ្មន  ព្រះអយ្យកោព្រះអង្គយាងមកពន្យល់សព្តិថា ÷

- ម្នាល ! សាយណ្ហាវ៉ារ្មន ! ចៅភ្លេចហើយឬនៅពាក្យរបស់តាដែលបានផ្តាំបិតាចៅ និងចៅ មុននឹងតាចូលទីវង្គតថា ÷

"បើរស់នៅលើលោកក្នុងមួយថ្ងៃដូចសត្វសឹង្ហ  ប្រសើរជាជាងរស់នៅលើលោកអស់មួយជីវិតដូចសត្វចៀម !" ចៅត្រូវកុំភ្លេចទៅយកព្រះខ័នរបស់តានៅភ្នំមាស  ដែលកប់ក្រោមជើងតាខាងស្តាំ  ទៅកាត់ក្បាលពួកក្បត់ជាតិមានរាមរាជ្យជាមេហើយដេញកំចាត់ទ័ពចម្ប៉ាចង្រៃ  ដែលបានលបលួកដៃដ៏ក្រខ្វក់ផ្សំគំនិតជាមួយអាចោរក្បត់រាមរាជ្យ  ប្លន់ព្រះបល្ល័ង្ករាជ្យរបស់ចៅ !

ពេលនោះ  ស្រាប់តែលេចរូបនាងកេសររង្សីមកលុតជង្គង់សំពះអង្វរព្រះរូបសំណាកទូលសួរថា : តើដាវរបស់ខ្ញុំម្ចាស់ទៅណាដែរព្រះអង្គ ?

- ចំណែកដាវរបស់នាងក៏មិនទាន់បាត់ទៅណាទេ ! សព្វថ្ងៃនៅត្រង់ជើងភ្នំមាសឯណោះ ! ចូរនាងចងចាំបណ្តាំខ្ញុំ ជួយគាំទ្រប្រទេសជាតិ និងព្រះមហាក្សត្រនាងផង ។

ឆាកសុបិន្តនិមិត្តមានដំណើរតែប៉ុណ្ណេះ ក៏រលត់បាត់ទៅវិញ ព្រះបាទសាយណ្ហាវ័ន្ន ក៏ទ្រង់តើនចាកព្រះក្រឡាបន្ទំនាពេលនេះដែរ ។ ព្រះភូធរទ្រង់ញាប់ញ័រក្នុងព្រះទ័យណាស់ ក៏យាងទៅដាស់លោកតាហោរាធិបតីត្រាស់ពីរឿងយល់សប្តិនេះ ។

លោកតាហោរាធិបតីត្រេកអរ ចំពោះសុបិន្តនិមិត្តដ៏ល្អនេះណាស់ ក៏តឿនព្រះអង្គថា ÷

- ព្រះករុណាថ្លៃវិសេស ព្រះសុបិន្តនិមិត្តនេះជាមង្គលដ៏ប្រសើរក្រៃលែង ហេតុនេះសូមព្រះអង្គស្តេចយាងទៅរកដាវភ្លាមឡើង ក្រាបទូល ! .......

- ចាំ ! ខ្ញុំត្រេកអរណាស់ អីចឹងលោកតាដាស់គ្នាយើងអោយក្រោកទាំងអស់គ្នាឡើង ហៅលោកមេទ័ពតេជោក្លាហាន, លោកវិសេសសេនា, ឆន្ទោនាងកេសរវង្សី, លោកពិជ័យរចនា អោយចូលមកជួបខ្ញុំនៅទីនេះជាបន្ទាន់ ......

- ក្រាបទូល ! សូមទទួលតាមព្រះរាជឱង្ការដ៏កល់លើត្បូង !

កងទ័ពបដិវត្តន៏ទាំងអស់ ក្នុងរាត្រីនេះ បានភ្ញាក់ពីដំណេកប្រមូលគ្នាកាន់អាវុធគ្រប់ដៃ រង់ចាំស្តាប់បញ្ជាពីមេកងរៀងៗ ក្រុម ។

ចំណែកនៅក្នុងព្រះពន្លាពិសេស ព្រះករុណាទ្រង់ត្រាស់ទៅមេទ័ពដ៏ចំណានរបស់ព្រះអង្គថា ÷

- ពេលនេះប្រាកដជាពេលដ៏ប្រកបដោយឫកពារវេលាល្អរបស់យើងហើយ ខ្ញុំសូមចាត់លោកវិសេសសេនា លោកតាហោរាធិបតី អោយនៅការពារបន្ទាយគោកធ្លកនេះជាមួយទាហាន ១០. ០០០ នាក់ ចំណែកលោកតេជោក្លាហាន, លោកពិជ័យរចនា និងលោកឆន្ទោ ត្រូវនាំទ័ព ៥០០០ នាក់ ចេញទៅ

ឃ្លាំចាំទទួលកងទ័ពចម្ប៉ានៅតាមផ្លូវជើងទឹក រីឯខ្លួនខ្ញុំពេលនេះសុំយកទាហាន ៥០០ នាក់ ជូនខ្ញុំ និងនាងកេសរវង្សី ទៅកាន់ភ្នំមាស ដើម្បីទៅយកព្រះខ័នកេត៌ ពីព្រះអយ្យកោខ្ញុំ និងទៅរកដាវជ័យសិទ្ធិរបស់នាងកេសរវង្សី ដែលត្រូវចោរលួចទៅ ........... ដូច្នេះខ្ញុំសូមផ្ដាំថា បើប្រសិនជាខ្ញុំត្រឡប់មកពីភ្នំមាសមិនទាន់ហើយស្រាប់តែកងទ័ពចាមមកដល់ ពួកយើងត្រូវវាយស្កាត់ព័ទ្ធចាប់វាអោយបាន កុំអោយទៅណារួចអោយសោះ ! ....... ទៅ ! ពេលវេលាមកដល់ហើយ យើងនាំគ្នាចាប់ធ្វើការរៀងខ្លួនទៅ ! .......

មេទ័ពទាំងឡាយ បានក្រាបបង្គំលាព្រះករុណាជាអម្ចាស់ ចាប់បំពេញនាទីរៀង១ ខ្លួន ។ ចំណែកព្រះបាទសាយណ្ហាវ័ន្ត ដោយមាននាងកញ្ញាកេសរវង្សី និងទាហាន ៥០០ នាក់ហែផង ក៏បានយាងទៅកាន់ភ្នំមាសទាំងរាត្រីស្ងាត់ ! ...

យើងបែរមកនិយាយពីដំណើរភៀសខ្លួនរបស់កងទ័ពចម្ប៉ាវិញ ។

ជំនោររាត្របក់មកត្រសៀក១ ហាក់ខិតខំជួយបំបាំងក្ដោងភេត្រាទាំងឡាយ អោយលូនចេញពីផៃនៃរាជធានីបានយ៉ាងស្រួល ។

នៅក្នុងដំណើរនេះរេះស្លាតគិតថា បើសិនជាកងទ័ពរាមរាជ្យដឹងហើយចេញមកដេញតាមនោះ គេនឹងធ្វើការប្រយុទ្ធឥតស្ដាយជីវិតបង់ឡើយ ។

រាត្រីកាលហៀបនឹងផុតកំណត់ត្រួតត្រាភពផែនដីទៅហើយ រស្មីក្រហមព្រឿង១ ក៏ផ្ដើមផុសឡើងជាមួយគ្នានឹងសំលេងមាន់ព្រៃដែលរងាវរំពងក្នុងដងអាធ្វា ។ ក្បួនទ័ពរបស់រេះស្លាតចេះតែខិតចូលមកជិតដល់កន្លែងពួនស្ទាក់របស់កងទ័ពបជិវត្តន៍ហើយ ។ ពេលនេះបើយើងត្រឡប់មកមើល ព្រះបាទសាយណ្ហាវ័ន្ត ឃើញថាទ្រង់យកព្រះខ័នមរតកបានហើយ ចំណែកដាវជ័យសិទ្ធិ

របស់នាងកេសររង្សី ក៏ត្រូវរកឃើញដែរ ដោយនៅពេលដែលមិត្តយើងមកដល់ភ្នំមាស នាយឃ្មីល និងស្មោញដែលវង្វេងផ្លូវក្នុងដងពនាល័យអស់ពេលបីបួនថ្ងៃទើបតែបានមកដល់ទីនោះ ។ ជាគ្រោះអាសន្នរបស់នាយចារបុរសកំហូចនេះ វាក៏បានជួបវាក់នឹងកងទ័ពមិត្តយើង១ ក៏ឥតប្រណី ទុកអោយវារស់ឃើញពន្លឺព្រះអាទិត្យតទៅទៀតឡើយ !

ក្រោមលំអហោមវាតុ ព្រះបាទសាយណ្ហាវ័ន្ទ. នាងកេសររង្សីព្រមទាំងពលបរិពារទាំង ៥០០ នាក់ បានបំផាយព្រះទីនាំងអស្សតរ និងសេះរបស់ខ្លួនត្រលប់មកគោកធ្លកវិញ អោយទាន់ពេលមុនព្រះអារុណរះ ។ ការស្រូតរូតរបស់យើងក៏បានដូចបំណង យើងបានមកដល់គោកធ្លកនៅពេលដែលសំណាញ់នៃអន្ធការ កំពុងប្រែពណ៌ពីខ្មៅទៅជាក្របាមព្រឿង១ លាយលឿង និងស ។

លោកតេជោក្លាហាន. លោកពិជ័យរចនា. នាយឆន្ទោ ព្រមទាំងកងទ័ពបដិវត្តន៍ទាំងអស់ កាលឃើញព្រះនរបតីយាងត្រឡប់មកដល់វិញហើយដោយបានទាំងព្រះខ័នជ័យសិទ្ធិមកផង កេសររង្សីក៏រកឃ្មើដាវជ័យសិទ្ធិរបស់នាងទៀត ក៏នាំគ្នាហោ៊កញ្រៀវទ្រហឹងអឺងអាប់ បណ្តាលអោយកងទ័ពចាមដែលកំពុងតែបើកសំពៅមក កាន់កៀកណាស់ហើយ ឮហើយនឹកស្មានថាតែរាមរាជ្យលើកទ័ពដេញតាមទាន់ ក៏តក់ស្លុតយ៉ាងខ្លាំង ។ មេកងទាំងអស់នាំគ្នារត់មកប្រាប់រេះស្លាតជាមេទ័ពដោយស្មើថា ÷

- តាមសំលេងហោ៊កញ្រៀវនេះ ពិតជាកងទ័ពរបស់រាមរាជ្យលើកមកតាមទាន់យើងជាប្រាកដ ! ....... តើលោកមេទ័ពគិតយ៉ាងណា ? ចំណែកពួកយើងទាំងអស់គ្នាគិតថា សំពៅដែលយើងនាំគ្នាជិះភៀសខ្លួនមកនេះ មិន-

មែនជាសំពៅចម្បាំងទេ ! នេះជាសំពៅជំនួញ ! ........

វេះស្លាតដោយតឹងទ្រូងញាប់ញ័រពេក ក៏សួរទៅមេកងទាំងនោះថា ÷

- ម៉េន ! សំពៅយើងជាសំពៅជំនួញ គ្មានកន្លែងសំរាប់បាញ់ប្រយោល ឬកន្លែងធ្វើសមយុទ្ធដូចជាសំពៅចម្បាំងទេ បើដូច្នេះយើងត្រូវបត់ក្បាលចត ឡើងគោកភ្លាមទើបបាន ព្រោះថាទោះបីយ៉ាងណាក៏យើងអាចបានឈរជើង លើផ្ទៃដីជាជាងក្នុងទឹក ។ មេកងងក់ក្បាល ព្រមទាំងសំរេចយកតាមយោបល់ នេះជាឯកច្ឆន្ទ ហើយវេះស្លាតក៏បញ្ជាអោយភេត្រារបស់ខ្លួនបត់ក្បាលចូលច្រាំង មួយរំពេច ។

ចំណែកនៅលើគោកឯណោះ ក្រោយពីឮដំណឹងពីនាយទាហានម្នាក់ឱ្យ ការណ៍មក កេសរវង្សីប្រញាប់ទៅបង្គំទូលព្រះករុណាថា ÷

- ព្រះករុណា ! ព្រះករុណា ! ទ័ពចាមបើកសំពៅចូលមកច្រើនណាស់ ក្រាបទូល !

- ហ្ន៎ ! ទ័ពចាមចូលមកទៀត ! ចុះអាផៃ និងក្រុមរបស់អាឯងដែល នៅប្រចាំឯឆ្នេរសមុទ្រខាងជើង ចាំអីទៀតនឹងលើកអាវុធឡើង !

- ក្រាបទូល ! ក្រុមកងសម្ងាត់របស់ទូលព្រះបង្គំ ដែលប្រចាំឯឆ្នេរ សមុទ្រខាងជើង កំពុងរង់ចាំប្រយុទ្ធជាមួយពួកអារ័ក្សទឹក ដែលវាតម្រង់មក រកជ្រោយសុវណ្ណភូមិនេះដែរ ក្រាបទូល !

- ពុទ្ធោ ! សត្រូវចូលមកពីគ្រប់ទិសទី ពួកឯងទាំងអស់គ្នាត្រូវទៅ ប្រកាសប្រាប់ប្រជាពលរដ្ឋទាំងស្រីប្រុស អោយក្រោកឡើងកាន់អាវុធគ្រប់ដៃ តស៊ូលុះត្រាជីវិតក្ស័យគ្រប់ៗ គ្នា ! ......... ឯចំណែកនាងកេសរវង្សី និងអស់

លោកមេទ័ពត្រូវទៅជាមួយខ្ញុំ វាយកំចាត់ទ័ពចាមកុំអោយវាចូលមកបាន ។

ព្រះសូរសីហនាទរលត់បាត់ភ្លាម កងទ័ពបដិវត្តន៏យើងមួយផ្នែកនេះ ក៏រៀបចំខ្លួនតាមល្បិចយុទ្ធសាស្ត្រភ្លាមៗ ឥតបង្អង់ក្រោមព្រះរាជាធិបតីភាពនៃ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។

តាមពិតសំពៅទាំងនេះជាសំពៅខ្មាំងហើយ យើងមិនបាច់សង្ស័យអ្វី ទៀតទេ ! ....... អស់លោកសូមវិលទៅកាន់កន្លែងរៀងខ្លួន ពេលណាឮសំលេង ស្នែង យើងត្រូវចាប់ផ្តើមចូលវាយស្នាក់ចាប់ពួកវាអោយបាន ! ........

លោកតេជោក្លាហាន, លោកពិជ័យរចនា, និងនាយឆន្នោបានក្រាប បង្គំលាព្រះករុណា មកកាន់កាប់កងទ័ពរបស់ខ្លួនវិញ ហើយរង់ចាំតែស្នូរស្នែង ដែលបញ្ជាអោយចូលទៅប្រយុទ្ធប៉ុណ្ណោះ ។

សំពៅដ៏ច្រើនរបស់វេះស្លាតបានចូលមកចត នៅមាត់ច្រាំងជាលំដាប់ លំដោយហើយ ។ ជាមួយគ្នានោះទាហានចាមប្រដាប់ដោយអាវុធគ្រប់ដៃ បាន ចេញពីសំពៅនាំគ្នាឡើងមកលើគោកយ៉ាងស្ងៀមស្ងាត់ ។

ព្រះបាទសាយណ្ហាវ័ទ្ធន និងកញ្ញាកេសររង្សីលបទតនឹងមើលឃើញ ដូច្នេះហើយ ក៏ដកខ្លួនចេញពីទីបំបាំងកាយមកវិញ ........ ។

ខណៈនេះវេះស្លាត កាលដែលឃើញកងទ័ពរបស់ខ្លួន ចេញពីសំពៅ អស់ហើយ ក៏នាំដើរឡើងពីច្រាំងមកចំកន្លែងដែលកងទ័ពបដិវត្តន៏បានត្រៀម ខ្លួនរង់ចាំវាជាយូរហើយ ។

ព្រះប្រមុខនៃកងទ័ពបដិវត្តន៏របស់យើង ពេលព័ទ្ធចាប់ពួកចោរ បរទេស ឈ្លានពានមកដល់ហើយ ទ្រង់ក៏បន្លឺសំលេងស្នែងឡើង កងទ័ពរបស់



ព្រះអង្គក៏ចាកពីជម្រក ចូលមកចោមរោមកាប់សម្លាប់ទ័ពរបស់វេះស្លាត អោយវាផ្អើលភិតភ័យ រត់ទីសទាសច្របូកច្របល់យ៉ាងកោលាហល ។

វេះស្លាត ឃើញកងទ័ពម្ចាស់ស្រុកដ៏ច្រើនលើសលប់ពេក យល់ថាពុំអាចតស៊ូជាមួយបាន ក៏បញ្ជាអោយកងទ័ពទម្លាក់អាវុធចុះចាញ់ភ្លាម ។

- ហ៊ឹះ ! វេះស្លាត ! លោកសោះតើដែលបានរួមគំនិតក្បត់ជាមួយរាមរាជ្យមកកួរកកាយផ្ទៃក្នុងនគររបស់ខ្ញុំ ព្រមទាំងប្លន់រំលំបល្លង្ករាជ្យខ្ញុំ ចំណែក

ព្រះចៅមហាម៉ាត់អស្សចំយ ក៏មិនគួរព្រះអង្គក្បត់នឹងចំណងមិត្តភាពរបស់យើង ជាម្ចាស់នគរសុវណ្ណភូមិសោះ ........ ! ឥឡូវនេះ យើងមិនធ្វើទោសពៃរ៍ដល់លោក និងកូនទាហានរបស់លោកទេ តែយើងសូមលោកទៅបន្ទាយរបស់យើង ......!

# ១១

# ព្យុះបដិវត្តន៍

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង កាលទ្រង់នាំរេះស្លាត និងកងទ័ពឈ្លើយរបស់វាមកដល់បន្ទាយគោកធ្លកហើយ ទ្រង់ក៏បញ្ជាឱ្យឃុំឃាំងពួកវាទុកមួយអន្លើសិន រួចហើយទើបព្រះអង្គទ្រង់នាំរេហ៍ពលដែលបានចេញទៅបំពេញបេសកកម្ម ចាប់រេះស្លាតតម្រង់ទៅជ្រោយសុវណ្ណភូមិឯទិសខាងជើង ដើម្បីកំចាត់ពួកអារក្សទឹក ជាមួយប្រជាពលរដ្ឋរបស់ទ្រង់ ដែលរង់ចាំនៅទីនោះ ។

ចម្លែកណាស់ ពន្លឺព្រះសូរ្យសែងនៃព្រះអាទិត្យ ដែលបញ្ចេញចំហាយដ៏ក្តៅពីនាទីមុន ឥឡូវប្រែទៅជាស្រទំុស្រគត់ស្រគំបោសអង្អែលដោយព្រះពាយរំភើយៗ ។

ព្យូហ៍យាត្រារបស់ព្រះរាជា ជិតដល់ឆ្នេរសមុទ្រខាងជើងហើយ ព្រះចមពលគង់លើខ្នងពាជីបោះជំហានទៅមុខយ៉ាងស្វាហាប់ តែរំពេចនោះ នាយផៃដែលជាទាហានសម្ងាត់របស់ទ្រង់រត់យ៉ាងលឿនតម្រង់មក ហើយក្រាបបង្គំទូលថា ÷

- ព្រះករុណា ! អ្នកស្រុកកំពុងជ្រួលច្របល់ណាស់ក្រាបទូល !

- ចុះពួកអារ័ក្សទឹកវាមកដល់ហើយឬនៅទេ ?

- ព្រះករុណាថ្លៃវិសេស ! ពួកអារ័ក្សទឹកដែលប្រជារាស្ត្រភ្ញាក់ផ្អើលនោះមិនទាន់មកដល់ទេ តែគួរឱ្យប្លែកណាស់សំពៅនោះមានតែពីរគត់ ហើយ

មានដោតទង់ជ័យសជាប់ជាមួយផង ។

- យី ! សមានន័យថា សន្តិភាព ចុះអ្នកដែលនៅក្នុងសំពៅនោះ ឯងមានដឹងថាជាសាសន៍ណាទេ ?

- ក្រាបទូល ទូលព្រះបង្គំឥតស្គាល់ដែរ តែអ្នកដែលនៅក្នុងសំពៅនោះទូលព្រះបង្គំឃើញស្លៀកពាក់ជាលឿងទាំងអស់ !

- ចម្លែកណាស់នំ ! តើជាតិសាសន៍អ្វីទៅ ? បើអញ្ចឹងអស់លោកទាំងអស់ (ព្រះអង្គងាកមកនិយាយនឹងកងទ័ព) ខ្ញុំសុំទៅមុនហើយ ព្រោះបើដូចពាក្យនាយថាមែន គេមិនមកជាសត្រូវនឹងយើងទេ គឺមកជាសន្តិភាព បើយើងប្រថុយអោយធ្លោយទៅតាមកំហឹងអ្នកស្រុក ច្បាស់ជាខូចអស់សេចក្តីរៀបរយនៃប្រទេសយើង ។

ទ្រង់ព្រះចិន្តាដូច្នោះ ព្រះបាទសាយណ្ហាវ័ន្ន ញាក់សេះបោះពួយទៅមុខតម្រង់ជ្រោយ ដោយព្រះវិតក្កជាយ៉ាងខ្លាំង ។

ដល់ហើយព្រះចមពល បញ្ជាឱ្យអ្នកស្រុក រម្ងាប់នូវក្តីកំហឹងក្រេវក្រោធទាំងប៉ុន្មាន ចាំស្តាប់ពាក្យបញ្ជារបស់ព្រះអង្គជាខាងក្រោយ ។

សំពៅចូលចតដល់មាត់ច្រាំងហើយ បុរសម្នាក់ហក់លោតមកលើច្រាំងកាន់ក្លាក់សារមួយនូវដៃ ចូលមកក្រាបបង្គំព្រះមហាក្សត្រយើង ! ហើយក្រាបទូលថា ÷

- បពិត្រព្រះសម្មតិទេពនៃដែនសុវណ្ណភូមិ ព្រះករុណារបស់ទូលព្រះបង្គំព្រះនាមធម្មាសោក ប្រើទូលបង្គំអោយយកព្រះរាជសារមកថ្វាយព្រះអង្គ ! ក្រាបទូល !

- អូ ព្រះធម្មាសោក ព្រះករុណាប្រទេសឥណ្ឌានោះឬ ?

- ព្រះករុណាថ្លៃវិសេស !

ព្រះនរបតី ទទួលសារពីរាជបម្រើនោះមក ទើបលាទតអស់មួយខណៈ ហើយលាន់ព្រះសូរសៀងឡើងថា ÷

- ខ្ញុំសប្បាយចិត្តណាស់ ! ដែលព្រះធម្មាលោកមានហឫទ័យជ្រះថ្លា អោយព្រះឧត្តរត្ថេរ និងព្រះសោណត្ថេរ មកផ្សាយព្រះពុទ្ធសាសនាដែលជាសាសនាដ៏មានទស្សនៈនិយមល្អបរិសុទ្ធត្រឹមត្រូវ សូមអ្នកនិមន្តព្រះថេរៈទាំងពីរអង្គនោះមក យើងអនុញ្ញាតអោយមកផ្សព្វផ្សាយលើដែនដីយើងហើយ ។

ត្រេកអរណាស់ នាម៉ឺនរូបនេះក៏ទៅនិមន្តព្រះថេរៈពីរអង្គនោះឡើងមក ។ ប្រជាពលរដ្ឋទាំងអស់ ឃើញព្រះមហាក្សត្ររបស់ខ្លួនក្រាបថ្វាយបង្គំដូច្នោះ យើងទាំងអស់គ្នាក៏ធ្វើគារវកិច្ចគ្រប់ៗ គ្នា ។

ពេលជាបន្ទាប់មក ព្រះមហាវីរក្សត្រយើងពុំបាននៅឋិតថេរជិតព្រះឧត្តរត្ថេ និងសោណត្ថេរបានយូរទេ ព្រោះប្រទេសកំពុងកើតកលិយុគខ្លោចផ្សា។ ព្រះអង្គគ្រាន់តែនិមន្តព្រះសង្ឃពីរអង្គនោះ អោយគង់តាមកន្លែងដ៏សមគួរមួយអន្លើសិន ទើបយាងប្រមូលកងទ័ពទៅវាយកំទេច ពួកក្បត់ដែលដណ្តើមរាជ្យពីព្រះអង្គ ។

ចំណែករាមរាជ្យវិញ ព្រឹកឡើងកាលបើដឹងថាទ័ពចាមទាំងអស់ស្ថិតក្រោមការដឹកនាំរបស់វេះស្លាត ដែលបានចូលមកជួយគេក្នុងការប្លន់បល្ល័ង្ករាជ្យព្រះបាទសាយណ្ហាវ័ន្ទដរាបបានទទួលជោគជ័យ ឥឡូវបានគេចចេញទៅនគរចម្ប៉ាវិញ ដោយការអាក់អន់ស្រពន់ចិត្តនោះ គេព្រួយបារម្ភយ៉ាងខ្លាំង ។

ចំពោះហេតុការណ៍ដ៏អាក្រក់នេះចមជនក្បត់ជាតិ គិតយល់ថា បើព្រះបាទសាយណ្ហាវ័ន្ទទ្រង់ជ្រាប ព្រះអង្គមុខជានឹងលើកទ័ពមកច្បាំងដណ្តើមយកបល្ល័ង្ករាជ្យ របស់ព្រះអង្គវិញមិនខាន ។

កំពុងតែគិតយ៉ាងពិបាកនៅក្នុងចិត្តពីរឿងនេះ សូរសព្ទសន្ធឹកកងទ័ពលើកចូលមក ព្រមដោយសម្រែកហ៊ោកញ្ជ្រៀវដ៏ខ្លាំងក្លា បានកន្ត្រាក់ស្មារតីរាមរាជ្យអោយតក់ស្លុតរន្ធត់ចិត្តរកអ្វីប្រៀបពុំបាន ។

ទាហានម្នាក់រត់ត្រហេបត្រហបចូលមករាយការណ៍ថា ÷

- ព្រះអង្គ ! កងទ័ពបដិវត្តន៍លើកចូលមកព័ទ្ធព្រះបរមរាជវាំងហើយក្រាបទូល !

- ស្អី ! កងទ័ពបដិវត្តន៍ព័ទ្ធវាំងយើងជាប់អស់ទៅហើយ ចុះក្រឡាសូនិងមេងទៀតទៅណាអស់ហើយ ។

រាមរាជ្យពោលដោយញ័រមាត់ ។

- ក្រាបទូលចក្រពត្រក្រឡាសូកំពុងចាត់ចែងទ័ព ទប់ទល់នឹងខ្មាំងជាមួយមេកងទាំងអស់ កុំអោយសត្រូវចូលលុកក្នុងវាំងបាន ........ ។

រាមរាជ្យបែកញើសជោគខ្លួន គេស្ទុះទៅកន្ត្រាក់យកដាវមកកាន់ទើបរត់ឡើងជិះសេះមកដឹកមុខទ័ពយ៉ាងរួសរាន់ ។

ទ្វារទាំងឡាយបិទជិតទាំងអស់ រាមរាជ្យខាំធ្មេញបញ្ចេញទឹកមុខមាំកាចឃោរឃៅ និយាយលើកទឹកចិត្តកងទ័ពដោយសំដីថា ÷

- ជ័យជំនះ នឹងធ្លាក់មកក្នុងកណ្តាប់ដៃពួកយើងជាដាច់ខាត ! កងទ័ព

បដិវត្តន៍ ជាកងទ័ពក្រខ្សត់សម្ភារៈ ពុំអាចវាយលុកយើងបានឡើយ ! បន្ថិចទៀត វានឹងស្លាប់ដោយសារថ្មីដែកងទ័ពដែលនៅខាងក្រៅវាំងរបស់យើងមិនខាន ! ..........

- ទាហានល្ងង់ខ្លៅរបស់រាមរាជ្យឮដូច្នោះ ក៏នឹកត្រេកអរនាំគ្នាហ៊ោកញ្ជ្រៀវយ៉ាងខ្ទរខ្ទារព្រមទាំងស្រែកថា ÷

- ជយោ ! ជយោ ! ព្រះអង្គរាមរាជ្យ ! បរាជ័យកងទ័ពបដិវត្តន៍ !

តែគួរអោយអស់សំណើច កន្ទុយសំលេងហ៊ោដ៏កក្រើកញ័រព្រះធរណីនេះ មិនទាន់រលត់ផុតពីរលកអាកាសធាតុផង ទ្វារព្រះបរមរាជវាំងគ្រប់ច្រកបានរបើកឃ្វាំងឡើង លេចកងទ័ពបដិវត្តន៍រត់ស្រចូលមកដូចកម្លាំងទឹកដែលហូរទម្លាយទំនប់បាន ។

កងទ័ពរាមរាជ្យកាប់ពួកយើងយ៉ាងក្លាហាន រុញច្រានយើងមិនអោយជម្រុលចូលក្នុងវាំងបាន អត់អំពើព្យុះបដិវត្តន៍ដ៏ខ្លាំងក្លាដែលបក់បោកលើកងទ័ពក្បត់លើកនេះ ពុំអាចឱ្យវារកមធ្យោបាយអ្វីឃាត់ឃាំងទប់ទល់វាំងរាបានឡើយ

ដាវជ័យសិទ្ធិទាំងពីរ និងព្រះខ័នជ័យសិទ្ធិរបស់ព្រះប្រមុខកងទ័ពយើងបានបញ្ចេញឥទ្ធិពលយ៉ាងមហស្ចារ្យ ។

រាមរាជ្យឃើញរស្មីដ៏ភ្លឺផ្លេកយ៉ាងប្លែកចេញពីដាវទាំងបី ក៏ភិតភ័យយ៉ាងខ្លាំង ។ គេយល់ថា ជតាអាក្រក់កំពុងសង្កត់រូបកាយគេអោយវិលទៅកាន់បរាជ័យយ៉ាងអាម៉ាស់ ហើយក៏រៀបចំខ្លួនដើម្បីនឹងគេចយករួចអាយុ ។

ពុទ្ធោ ! រាមរាជ្យលើកនេះ ផុងគំនិតគិតអ្វីមិនបានដូចបំណងសោះ ពេលនេះស្រាប់តែព្រះបាទសាយណ្ហាវ័ន្តទ្រង់យាងចូលមកដល់ ។

- ម៉េចរាមរាជ្យ ! យើងជួបគ្នាហើយ ! ឱកាសនេះល្អណាស់ ! ........

រាមរាជ្យមិនតបនឹងព្រះឱង្ការមួយឃ្លានេះទេ វាត្រឡប់ជាលបឆ្មៀតក្នុងពេលយ៉ាងតូចនេះកាប់ព្រះអង្គមួយដាវ បំណងអោយព្រះអង្គក្ស័យតែម្តងតែអស្ចារ្យណាស់ ព្រះនរតីទ្រង់លើកព្រះខ័នជ័យសិទ្ធិរងដាវរបស់រាមរាជ្យបណ្តាលអោយបាក់ជាពីរ ។ ឥតបង្អង់អោយខាតពេល ព្រះអង្គក៏ទ្រង់បណ្តាច់ក្បាលវាអោយរបូតចេញពីក ដល់នូវសេចក្តីស្លាប់យ៉ាងថោកទាប ។

ក្រឡាសូឃើញរាមរាជ្យកំបុតក្បាលស្លាប់ទៅហើយ ក៏រត់រកច្រកចេញ តែមិនដឹងជាថៃជន្យដ៏ថោកទាបអ្វី វារត់ទៅជួបនាងកេសររង្សីទៅវិញ ។ តរុណីយកដាវចុចខ្នងវាជាប់ពីក្រោយហើយប្រាប់ថា ÷

- លោកតា ! កុំអាលរត់ ! ឥឡូវបែរមុខមក យើងប្រឡងដាវនឹងគ្នាម្តងទៀត ! ........

ក្រឡាសូបុកពោះភឹប ! ងាកផាំងមកក៏ឃើញកេសររង្សី ។

- អូ ! នាងឯងទេ ! ល្អហើយពេលនេះនាងភាវនាធមិអោយហើយទៅ អញមិនទុកជីវិតនាងឯងអោយរស់តទៅទៀតទេ ! ........

ពោលចប់ក្រឡាសូក៏យារដាវកាប់នាងផាំង តែនាងគេចផុតទើបពោលកំប្លែងថា : លោកតាកាប់ខ្យល់ហើយ ។

ក្តៅណាស់ ក្រឡាសូក៏កាប់នាងទៀត តែតរុណីមិនទុកវាអោយខាតពេល ក៏យកដាវរបស់នាងរង ទើបចាក់បណ្តោយទៅត្រូវចំទ្រូងវា។ ក៏របូតដាវស្លាប់មួយរំពេច ។

កូនទាហានឃើញមេទ័ពស្លាប់បាត់បង់អស់ហើយ ក៏ទម្លាក់អាវុធសុំចុះ

ចាញ់គ្រប់ៗ គ្នា ។

ក្នុងពេលនេះកងទ័ពបដិវត្តន៍ ក៏ប្រកាសមហាជោគជ័យដោយស្នូរសម្រែកជ័យឃោសនីយ៉ាងខ្ទរខ្ទារ ។

ក្រោមរស្មីព្រះសុរិយា ក្នុងឱកាសដែលបំណងរបស់យើងបានត្រូវចំលងយើងមកដល់កោះត្រើយហើយនោះ យើងមិនដឹងជារកពាក្យអ្វី មកលាតត្រដាងអោយឃើញប្រត្យក្សថាយើងសប្បាយ ! សែនសប្បាយឡើយ ។

ថ្លែងពីប្រជាពលរដ្ឋទាំងអស់ ក្នុងព្រះរាជអាណាចក្រសុវណ្ណភូមិ កាលបើដឹងថា រាមរាជ្យ និងបរិវារបានស្លាប់បាត់បង់ទៅហើយៗ បើនៅសល់ខ្លះបានត្រូវធ្លាក់ខ្លួនក្នុងពន្ធនាគារទៅដែរនោះ ក៏រីករាយយ៉ាងខ្លាំង ។

ព្រលឹងសន្តិភាព ដ៏ក្រអូបបានប្រោះព្រំព្រះរាជណាចក្រសុវណ្ណភូមិទាំងមូល ជាមួយគ្នានឹងបរាជ័យជាស្ថាពររបស់រាមរាជ្យ ។ ព្រះបាទសាយណ្ហាវ័ន្ត ក៏ទ្រង់បានយាងគ្រប់គ្រងរាជសម្បត្តិឡើងវិញ ក្នុងព្រះបរមរាជវាំង ដែលតាំងនៅឯរាជធានីសុវណ្ណភូមិ ។

ជាមួយគ្នានឹងទិវាប្រកាសជោគជ័យ របស់កងទ័ពបដិវត្តន៍នេះ វេះស្លាត និងកងទ័ពចាមទាំងប៉ុន្មាន ដែលយើងចាប់បានជាឈ្លើយត្រូវព្រះប្រិយមហាក្សត្រ ដោះលែងអោយវិលត្រឡប់ទៅកាន់មាតុភូមិវិញ ។

កិច្ចការរាជការបានចាប់ផ្តើមបំពេញសកម្មភាព ដូចដើមវិញហើយតែវរជនទាំងឡាយ ដែលមានគុណបំណាច់យ៉ាងខ្លាំងក្នុងការដឹកនាំកងទ័ពបដិវត្តន៍ ត្រូវបានទទួលឋានន្តរសក្តិបន្ថែមទៀត ។

ចំពោះកញ្ញាកេសររង្សីវិញ ដែលព្រះរាជាដ៏ជាកំពូលភពទ្រង់បានគួច

ព្រះទ័យប្រតិព័ទ្ធស្នេហាយូរមកនោះ ក៏ត្រូវព្រះអង្គស្ដីដណ្ដឹងនាង រៀបចំអភិសេក ទៅតាមព្រះរាជប្រពៃណីជាព្រះអគ្គមហេសីរបស់ព្រះអង្គ ។

ក្រោយពីរៀបចំក្រុងសុវណ្ណភូមិ អោយបានដូចដើមវិញហើយព្រះបាទសាយណ្ហាវ័ន្ន ស្ដេចនឹកទៅដល់ព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរ ដែលទ្រង់និមន្តមកផ្សព្វផ្សាយព្រះពុទ្ធសាសនា ព្រមទាំងព្រះអង្គជឿជាក់ថា ឥទ្ធិពលនៃសុវណ្ណភូមិដែលបានរួចចាកផុតពីហាយនភាពនេះ ក៏ដោយសារឫទ្ធិបារមីនៃព្រះពុទ្ធជាម្ចាស់ ដែលចូលមកប្រោះព្រំដែនដីដ៏ធំទូលាយនេះ ។ ទ្រង់ព្រះចិន្តាដូច្នោះ ព្រះប្រមុខសុវណ្ណភូមិ ក៏ប្រកាសប្រាប់ប្រជានុរាស្ត្រគ្រប់ជនបទឆ្ងាយជិតទាំងអស់ អោយមូលមកស្ដាប់ព្រះធម្មទេសនាដែលព្រះថេរៈទាំងពីរអង្គនេះសំដែងនៅក្នុងព្រះពន្លា នៃព្រះបរមរាជវាំង ។

តាំងពីថ្ងៃនោះមក ដោយប្រព្រឹត្តទៅតាមគន្លងពុទ្ធោវាទប្រជានុរាស្ត្រសុវណ្ណភូមិទាំងមូល រីងរិតតែមានអំណាចឡើងឥតមានប្រទេសណា ហ៊ានប្រកាសសង្គ្រាមជាមួយឡើយ ។

ភ្នំពេញ, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៦៦

អ្នកនិពន្ធ

**នួន សាវឿន**

# ចេញលក់ហើយ !




**មានលក់ដុំ និង លក់រាយ**

នៅតូបលេខ ២៣-២៤ និង ១០២ (ជាន់ឡៅតឿ)

ផ្សារអូរឫស្សី ភ្នំពេញ